សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អាពាហ៍ពិពាហ៍ និងបញ្ហាប្រឈម នៅកម្ពុជាបច្ចុប្បន្ន

ស្រាវជ្រាវពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **មែន មុំ**
**វាសនា ឋាន:**

សាស្ត្រាចារ្យណែនាំ
លោក **ហៀង សាង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំព្រះករុណាអាត្មាភាពឈ្មោះ **មែន មុំ** និងខ្ញុំបាទឈ្មោះ **វាសនា ថាន:** ជាសមណនិស្សិត-និស្សិត ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលកំពុងតែធ្វើការសិក្សាស្រាវជ្រាវសរសេរសារណាថ្នាក់បរិញ្ញាបត្រ នៅក្នុងគោលបំណងដើម្បីបញ្ចប់ការសិក្សា ក្រោមប្រធានបទស្តីពី "**អាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន**"។

ជាដំបូងយើងខ្ញុំទាំងពីរនាក់ សូមឆ្លៀតឱកាសដ៏ប្រពៃនេះសម្តែងនូវគារវកិច្ចលំឱនកាយ វាចាចិត្ត ថ្លែងនូវការដឹងគុណ និងកត្តញ្ញូតាធម៌យ៉ាងខ្ពស់ខ្ពស់បំផុតជូនចំពោះ៖

❖លោកឪពុក **ម៉ូញ មែន** ព្រមទាំងអ្នកម្តាយ **ភក វ៉េត**

❖លោកឪពុក **ពៅ វាសនា** ព្រមទាំងអ្នកម្តាយ **ឆេង សុខឃី**

និងបងប្អូននៃក្រុមគ្រួសាររបស់ខ្ញុំបាទ ទាំងអស់ ដែលលោកបានផ្តល់កំណើត ការអប់រំថែរក្សាបីបាច់ និងជួយផ្គត់ផ្គង់ទាំងបញ្ញាស្មារតី អាហារូបត្ថម្ភគ្រប់បែបយ៉ាងទាំងអស់មកដល់រូបអាត្មាភាព ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម **បណ្ឌិត លុយ ចណ្ណា** ជា**សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ ព្រមទាំង សាស្ត្រាចារ្យទាំងអស់** ដែលបានខិតខំបង្ហាត់បង្រៀន ផ្ទេរចំណេះដឹងល្អៗយ៉ាងច្រើនចំពោះនិស្សិតនិងចំណាយពេលវេលា កម្លាំងកាយចិត្ត ដើម្បីបណ្តុះបណ្តាលយើងខ្ញុំដែលបានសិក្សាថ្នាក់បរិញ្ញាបត្រនៅទីនេះ ។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកសាស្ត្រាចារ្យ **ហៀង សាង** ដែលបានខិតខំយកចិត្តទុកដាក់លះបង់នូវពេលវេលារបស់លោក ក្នុងការជួយណែនាំ និងកែសម្រួល ខ្លឹមសារ អក្ខរាវិរុទ្ធ ពោលគឺផ្តល់នូវគំនិតល្អៗ និងធ្វើការដឹកនាំស្រាវជ្រាវបានផ្តល់នូវអនុសាសន៍ និងការកែតម្រូវ យ៉ាងយកចិត្តទុកដាក់ចំពោះការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ ដែលជាសមណនិស្សិត-និស្សិត ។

ទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមគោរពជូនពរដល់លោកឪពុក អ្នកម្តាយ ព្រមទាំងឯកឧត្តម សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង លោកសាស្ត្រាចារ្យបណ្ឌិតដឹកនាំ ព្រមទាំងលោក លោកស្រី ជាសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

អាពាហ៍ពិពាហ៍ គឺជាការព្រមព្រៀងគ្នារវាងបុរសនឹងនារី រួមរស់ជាមួយគ្នា (រួមសមគ្គសង្វាសជាមួយគ្នា) ដើម្បីបន្តពូជពង្សវង្សត្រកូល ហើយគ្មានភាគីណាមួយអាចរំលាយអាពាហ៍ពិពាហ៍បានតាមទំនើងចិត្តបានឡើយ ។ ទោះបីជាអាពាហ៍ពិពាហ៍ទាំងនោះ កើតឡើងដោយសារមនោសញ្ចេតស្នេហាតាមរយៈការស្រឡាញ់ពេញចិត្តចំពោះគ្នាទៅវិញទៅមកក៏ដោយ អាពាហ៍ពិពាហ៍ដែលមានសុពលភាពឬមានការទទួលស្គាល់ដោយរដ្ឋឬមនុស្សទូទៅបាននោះ គឺត្រូវបង្កើតតាមរយៈបញ្ញត្តិនៃច្បាប់ជាធរមាន ។ អាពាហ៍ពិពាហ៍នេះតែងមានបញ្ហាប្រឈមមួយចំនួនដែលបានកើតឡើងនាពេលបច្ចុប្បន្ននេះ ។ ហេតុនេះហើយ ក្នុងនាមយើងខ្ញុំជានិស្សិតនឹងធ្វើសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**អាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន**"។

ដើម្បីជាការចូលរួមចំណែកយ៉ាងធំធេងបំផុត នៅក្នុងការបណ្តុះបណ្តាលនូវចំណេះដឹង នឹងដើម្បីជួយបង្កើននូវពុទ្ធិដល់សិស្ស-និស្សិតដែលមានបំណងក្នុងការសិក្សាផ្នែកច្បាប់ ។ ហើយក៏ជួយដល់ការ ផលិតនូវធនធានមនុស្សដែលជាកត្តាដ៏សំខាន់បំផុត ក្នុងការកសាងប្រទេសជាតិឱ្យមានការរីកចម្រើនយ៉ាងឆាប់រហ័សផង ។

ចំណេះដឹង គឺជាអំណាចមួយដ៏សំខាន់សម្រាប់មនុស្សម្នាក់ៗ ។ ចំណេះជាអាវុធដ៏មុតស្រួចមួយ ដែលមនុស្សយើងគ្រប់រូបមិនអាចខ្វះបានឡើយ ។ ប្រទេសជាតិមួយ ប្រសិនបើមានធនធានមនុស្សដែលសម្បូរទៅដោយចំណេះដឹងនោះ យើងអាចនិយាយបានថា ប្រទេសជាតិនោះនឹងមានការរីកចម្រើន ជឿនលឿន និងមានការវិវត្តទៅជានិច្ច ។ ធនធានមនុស្សគឺជាកត្តាដ៏សំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍សង្គមជាតិមួយ ជាពិសេសគឺផ្តោតសំខាន់ទៅលើកត្តាយុវជនដែលជាធនធានមិនអាចខ្វះបានឡើយ ។

យើងខ្ញុំយល់ថា ការអានច្រើន ការសិក្សាស្រាវជ្រាវច្រើន ជាផ្នែកមួយនៃការបណ្តុះនូវបញ្ញាបង្កើតនូវគំនិត ហើយមានទុកទំនុកចិត្តលើខ្លួនឯង មានទិសដៅច្បាស់លាស់នូវក្នុងការសម្រេចមហិច្ឆតារបស់ខ្លួនឱ្យដល់គោលដៅ និងបង្កើតសុភមង្គលសម្រាប់ជីវិត ។

ជាទីបញ្ចប់ យើងខ្ញុំមានការរីករាយត្រេកអរ និងទទួលស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះការទិតៀនដើម្បីជាការស្ថាបនារបស់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និស្សិត និងមិត្តៗអ្នកអានទាំងអស់ដោយភក្តីភាព ។

ធ្វើនៅថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២

ត្រូវនឹងថ្ងៃទី ១៨ ខែមីនា ឆ្នាំ ២០១៩

# មាតិកា


មាតិកា ...... i

**សេចក្តីផ្តើម** ...... ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ...... ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ...... ២

៣.គោលបំណងនៃការស្រាវជ្រាវ ...... ២

៤.ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ ...... ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ...... ២

៦.វិធីសាស្រ្តនៃការស្រាវជ្រាវ ...... ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...... ៣

**ជំពូកទី ១**

**សញ្ញាណទូទៅនិងលក្ខខណ្ឌគតិយុត្តនៃអាពាហ៍ពិពាហ៍**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍** ...... ៥

**កថាខណ្ឌទី១៖ និយមន័យអាពាហ៍ពិពាហ៍** ...... ៥

**កថាខណ្ឌទី២៖ ប្រវត្តិនៃអាពាហ៍ពិពាហ៍** ...... ៦

**១.ទំនៀមទម្លាប់ប្រពៃណី** ...... ៦

ក. សម័យនគរភ្នំ ...... ៦

ខ. សម័យចេនឡា ...... ៦

**២.តាមច្បាប់** ...... ៧

ក.សម័យសង្គមរាស្រ្តនិយម ...... ៧

ខ.សម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជា ...... ៧

**កថាខណ្ឌទី៣៖ គោលបំណងនៃអាពាហ៍ពិពាហ៍** ...... ៨

**ផ្នែកទី២៖ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍** ...... ៨

**កថាខណ្ឌទី១៖ លក្ខខណ្ឌធម្មជាតិ** ........ ៨
១.លក្ខខណ្ឌរូបរាងកាយបុគ្គល ........ ៨
២.លក្ខខណ្ឌភេទ ........ ៨
៣.លក្ខខណ្ឌអាយុ ........ ៩
៤.លក្ខខណ្ឌសុខភាព ........ ១០
៥.ការព្រមព្រៀងពីភាគីប្តីប្រពន្ធ ........ ១០
ក. ការព្រមព្រៀងមុនរៀបអាពាហ៍ពិពាហ៍ ........ ១០
+. មេអណ្តើក និងអ្នកចូលថៃចូវ ........ ១០
ខ. ពិធីកំជាប់ពាក្យ ឬការភ្ជាប់ពាក្យ ........ ១០
គ. និយមន័យ ........ ១២
ឃ. អានុភាពនៃកំជាប់ពាក្យ ........ ១២
ង. ការប្តឹងទាមទារសំណងខូចខាត ........ ១២
៦.ការព្រមព្រៀងក្នុងពេលរៀបអាពាហ៍ពិពាហ៍ ........ ១៣
ក. ការយល់ព្រមរបស់គូស្រករ ........ ១៣
ខ. ការព្រមព្រៀងពីឪពុកម្តាយ ........ ១៤
+. ក្នុងករណីនីតិជន ........ ១៤
+. ក្នុងករណីជាអនីតិជន ........ ១៤
គ. ការយល់ព្រមរៀបអាពាហ៍ពិពាហ៍របស់អនីតិជន ........ ១៥
+. ចំពោះកូនមានខាន់ស្លា ........ ១៥
+. ចំពោះកូនឥតខាន់ស្លា ........ ១៥
+. ចំពោះកូនចិញ្ចឹម ........ ១៥
**កថាខណ្ឌទី២៖ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍** ........ ១៦
១.លក្ខខណ្ឌមុនពេលរៀបអាពាហ៍ពិពាហ៍ ........ ១៦
ក. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ........ ១៦
ខ. ការប្រកាសផ្សាយ ........ ១៧
២. លក្ខខណ្ឌក្នុងពេលរៀបអាពាហ៍ពិពាហ៍ ........ ១៧

ក. វត្តមានគូស្រករ..........១៧
ខ. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍..........១៨
គ. សមត្ថកិច្ចមន្ត្រីអត្រានុកូលដ្ឋាន..........១៨
**កថាខណ្ឌទី៣៖ លក្ខខណ្ឌមិនអាចរៀបអាពាហ៍ពិពាហ៍បាន**..........១៨
១.ភេទដូចគ្នា..........១៨
២.អនីតិជន..........១៨
៣.ទ្វេពន្ធភាព..........១៩
៤. ការគោរពវិធវភាព ឬអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី ....២០
៥. អាពាហ៍ពិពាហ៍រវាងញាតិលោហិតឬញាតិពន្ធ..........២០
៦. អសមត្ថភាពផ្លូវកាយ និងស្មារតី..........២១
**កថាខណ្ឌទី៤៖ បណ្តឹងទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍**..........២១
១. សញ្ញាណនៃបណ្តឹងទាស់..........២១
២. អ្នកមានសិទ្ធិប្តឹងជំទាស់..........២២
ក. ជនដែលមានប្រយោជន៍..........២២
ខ. មន្ត្រីអត្រានុកូលដ្ឋាន..........២២
៣. ទម្រង់នៃបណ្តឹងទាស់..........២២
៤. មូលហេតុនៃបណ្តឹងទាស់..........២២
៥. រយៈពេលនៃបណ្តឹងទាស់..........២៣
៦. ការសម្រេចលើបណ្តឹងទាស់..........២៣
៧. បណ្តឹងតវ៉ា..........២៣
**កថាខណ្ឌទី៥៖ អានុភាពនៃអាពាហ៍ពិពាហ៍**..........២៤
**ផ្នែកទី៣ ៖ អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស**២៤
**កថាខណ្ឌទី១៖ ការរៀបអាពាហ៍ពិពាហ៍នៅបរទេស**..........២៤
**កថាខណ្ឌទី២៖ ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា**..........២៥
១. ពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍..........២៥

ក. លក្ខខណ្ឌ....................................................................................................២៥
ខ. ឯកសារ......................................................................................................២៥
គ. ការពិនិត្យ និងការប្រកាសផ្សាយរបស់មន្ត្រីអត្រានុកូលដ្ឋាន ..................២៦
ឃ. ការចុះសំបុត្រអាពាហ៍ពិពាហ៍.............................................................២៧
២. ជនបរទេស និងជនបរទេស ..........................................................................២៧

## ជំពូកទី ២

## បញ្ហាប្រឈមអាពាហ៍ពិពាហ៍នៅកម្ពុជាបច្ចុប្បន្ន

**ផ្នែកទី១៖ បញ្ហាប្រឈមអាពាហ៍ពិពាហ៍**.......................................................២៨
**កថាខណ្ឌទី១៖ បញ្ហាភេទដូចគ្នា** ...............................................................២៨
១.បញ្ហាផ្ទុយនឹងច្បាប់ ..........................................................................................២៨
២.បញ្ហាការរើសអើង............................................................................................៣០
ក.អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាចេញបង្ហាញជាសាធារណៈ................៣២
ខ.របាំងប្រពៃណី ...........................................................................................៣២
**កថាខណ្ឌទី២៖ បញ្ហាអាយុភាគី** ........................................................................ ៣៣
១.បញ្ហាសុខភាពម្ដាយនិងកូន ...............................................................................៣៤
២.សមត្ថភាពក្នុងការបង្ហាញឆន្ទៈ.............................................................................៣៥
៣.អំពើហិង្សាក្នុងគ្រួសារ.......................................................................................៣៦
៤.បញ្ហាការលែងលះ ...........................................................................................៣៨
**កថាខណ្ឌទី៣៖ បញ្ហាការបង្ខិតបង្ខំ**.............................................................៣៨
១.បញ្ហាប្រពៃណីទំនៀមទម្លាប់...............................................................................៤០
២.បញ្ហាចង់បានទ្រព្យ .........................................................................................៤១
៣.ការភ័យខ្លាចនិងការយល់ដឹងតិចតួចរបស់ឪពុកម្ដាយ...........................................៤២
**កថាខណ្ឌទី៤៖ បញ្ហាញាតិនិងញាតិ**.............................................................៤២
១.ទំនាក់ទំនងញាតិ ............................................................................................៤៣
ក. រវាងញាតិលោហិត ......................................................................................៤៣

+.រវាងសាខាញាតិលោហិតក្នុងបីថ្នាក់ ....................................................៤៤
+.សាខាញាតិលោហិតក្នុង៦ថ្នាក់ ..........................................................៤៥
ខ.រវាងញាតិពន្ធ ..........................................................................................៤៦
+.រវាងសាខាញាតិពន្ធក្នុងបីថ្នាក់ ..........................................................៤៧
**កថាខណ្ឌទី៥៖ បញ្ហាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិុល** .............៤៩
១.អាពាហ៍ពិពាហ៍ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ ..................................៤៩
ក.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍......................................................៥០
ខ.ការជូនដំណឹងជាសាធារណៈ ...............................................................៥១
គ.ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍............................................................៥១
ឃ.ការចុះបញ្ជីអាពាហ៍ពិពាហ៍...................................................................៥២
ង.ការសរសេរនិងប្រគល់សំបុត្រអាពាហ៍ពិពាហ៍ .........................................៥៤
២.រៀបការដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍........................................៥៥
ក.រៀបការពីមុនមកតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ...........................៥៦
ខ.បញ្ហាទ្វេពន្ធភាព ...................................................................................៥៧
+.ការចុះសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ប្ដីឬប្រពន្ធចុង ............................៥៩
គ.បញ្ហាការបែងចែកទ្រព្យ .......................................................................៦០
+.ទ្រព្យសម្បត្តិដោយឡែក ....................................................................៦០
+.ទ្រព្យសម្បត្តិរួម ................................................................................៦១
ឃ.បញ្ហាមោឃៈឬការលុបចោល .................................................................៦២
+.បញ្ហាមោឃៈ.....................................................................................៦២
+.ការលុបចោល ...................................................................................៦៣
**កថាខណ្ឌទី៦៖ បញ្ហាចូលសញ្ជាតិដោយអាពាហ៍ពិពាហ៍** ...................................៦៤
១.និយមន័យ...............................................................................................៦៤
២.បញ្ហាចង់បានសញ្ជាតិខ្មែរ..........................................................................៦៤
៣.លក្ខខណ្ឌចូលសញ្ជាតិដោយអាពាហ៍ពិពាហ៍ ...............................................៦៦

៩.ការបាត់សញ្ជាតិខ្មែរ ....................................................................................៦៦
**សេចក្តីសន្និដ្ឋាននិងអនុសាសន៍** ...............................................................................៦៨
**១.សេចក្តីសន្និដ្ឋាន**.........................................................................................................៦៨
**២.អនុសាសន៍**.................................................................................................................៧០
**ឯកសារយោង** ................................................................................................................៧១
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងពិភពផែនដីយើងនេះ ធម្មជាតិបានបង្កើតឱ្យមានមនុស្សសត្វគឺមានប្រុសមានស្រីជាគូនឹងគ្នាហើយស្រឡាញ់ជាធម្មតារបស់មនុស្សសត្វ ដែលជាហេតុនាំឲ្យការបន្តពូជពង្សវង្សត្រកូល ។ ចំពោះការស្រឡាញ់គ្នា ហើយអាចរួមរស់នៅជាមួយគ្នាបង្កើតជាគ្រួសារបាននោះ សម្រាប់មនុស្សយើងមានភាពខុសគ្នាអំពីសត្វ ដើម្បីអាចរស់នៅជាមួយគ្នាបង្កើតជាក្រុមគ្រួសារបានគឺត្រូវប្រព្រឹត្តទៅក្រមសីលធម៌ជាមនុស្សដែលជាទំនៀមទម្លាប់ប្រពៃរបស់ពួកគេដូចជាការសែនចងដៃ ការគោរពអំណាចមេបាទាំងសងខាងជាពិសេសអនុវត្តទៅតាមនីតិវិធីច្បាប់របស់ប្រទេសនីមួយៗ នៃការរៀបអាពាហ៍ពិពាហ៍រវាងបុរសនិងស្រ្តី ។ ចំពោះការរៀបអាពាហ៍ពិពានេះច្បាប់របស់ប្រទេសកម្ពុជាបានចែងពន្យល់ប្រាប់អំពីរបៀបនិងនីតិវីធិនៃការរៀបអាពាហ៍ពិពាហ៍នេះផងដែរ ដូចជាយោងទៅតាមច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ស្តីពីអាពាហ៍ ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងបទដ្ឋានគតិយុត្តនានា ។ ដោយយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារចែងថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឱឡារិកមួយ ធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្តេជ្ញាថាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តខ្លួន ។ អាពាហ៍ពិពាហ៍ដែលនឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងដោយស្របតាមក្បួនខ្នាត ដែលមានចែងនៅក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ។ ទោះបីជាច្បាប់បានចែងអំពីភាពពេញលក្ខណៈនៃអាពាហ៍ពិពាហ៍ក៏ដោយ ចំពោះការរៀបអាពាហ៍ពិពាហ៍មួយចំនួន នៅក្នុងសង្គមខ្មែរបច្ចុប្បន្ននេះ នៅមានការខ្វះខាតមិនមានភាពពេញលក្ខណៈទៅតាមទម្រង់ច្បាប់និងមិនសូវបានអនុវត្តទៅតាមនីតិវិធីនៃច្បាប់ឡើយ ដែលជាហេតុនាំឱ្យមានបញ្ហាប្រឈមកើតឡើងនៃអាពាហ៍ពិពាហ៍ ។

អាស្រ័យហេតុនេះ ក្រុមយើងខ្ញុំបានលើកយកប្រធានបទទាក់ទងទៅនឹង "**អាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន**" មកធ្វើការបកស្រាយ ។ ដោយប្រធាននេះ មានលក្ខណៈពិសេសក្នុងការជួយកាត់បន្ថយរាល់កំហុសឆ្គង ដែលមាននៅក្នុងការអនុវត្តជាក់ស្តែងនាពេលបច្ចុប្បន្ននឹងស្វែងយល់អំពីបញ្ហាប្រឈមនៃអាពាហ៍ពិពាហ៍ ។ ម្យ៉ាងទៀតដើម្បីចូលរួមក្នុងការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាពល្អ និងចែករំលែកចំណេះដឹងដល់ប្រជាជនឱ្យបានយល់ច្បាស់ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តើអ្វីទៅជាបញ្ហាប្រឈមនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ? មូលហេតុអ្វីខ្លះ ដែលនាំឲ្យមានអាពាហ៍ពិពាហ៍និងបញ្ហាប្រឈមកើតឡើង ? តើច្បាប់របស់ប្រទេសកម្ពុជាបានកំណត់លក្ខខណ្ឌអ្វីខ្លះនៃការរៀបអាពាហ៍ពិពាហ៍ ? ដើម្បីឲ្យអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ តើមាននីតិវិធីសម្រាប់អនុវត្តដូចម្ដេចខ្លះ ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ គឺសំខាន់ផ្ដោតទៅលើបញ្ហាប្រឈមនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ។

ដើម្បីចងក្រងជាឯកសារថ្មីមួយ សម្រាប់ជាជំនួយដល់និស្សិត និងអ្នកអានផ្សេងទៀត ដែលមានបំណង ចង់សិក្សាពីបញ្ហាប្រឈមនៃការរៀបអាពាហ៍ពិពាហ៍ នៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។

ម្យ៉ាងចែករំលែកចំណេះដឹងទាំងនេះឱ្យប្រជាជនទាំងអស់ បានយល់ដឹងអំពីបញ្ហាប្រឈមនៃការរៀបអាពាហ៍ពិពាហ៍នៅកម្ពុជាបច្ចុប្បន្ននេះ ព្រមទាំងឲ្យបានយល់ច្បាស់អំពីនីតិវិធីច្បាប់នៃការរៀបអាពាហ៍ ពិពាហ៍នៅសង្គមកម្ពុជាបច្ចុប្បន្នផងដែរ ។

## ៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺបង្ហាញអំពីអាពាហ៍ពិពាហ៍និងបញ្ហាប្រឈមបច្ចុប្បន្ននៅកម្ពុជាតែប៉ុណ្ណោះ ដោយច្បាប់ដែលជាប់ទាក់ទងនឹងអាពាហ៍ពិពាហ៍នេះ គឺមានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រមទាំងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ ច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦ អនុក្រឹត្យស្តីពីអត្រានុកូលដ្ឋានឆ្នាំ២០០០ ជាអាទិ៍។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺមានសារៈសំខាន់ដូចខាងក្រោម៖

ដើម្បីជាចំណេះដឹងសម្រាប់សិស្សានុសិស្ស និស្សិត និងប្រជាពលរដ្ឋទាំងអស់ឲ្យបានយល់ច្បាស់ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនានានៅកម្ពុជាបច្ចុប្បន្ន ។ ដោយសារប្រជាពលរដ្ឋមួយចំនួនមានការយល់ដឹងតិចតួចអំពីបញ្ហាអាពាហ៍ពិពាហ៍ ហើយពួកគាត់ពុំសូវយល់ដឹង

អំពីបញ្ហាច្បាប់ដែលមានចែងជាធរមាន ជាហេតុធ្វើឲ្យពួករៀបអាពាហ៍ពិពាហ៍ ទៅតាមទំនៀមទំលាប់ នេះជាសារៈសំខាន់ដើម្បីកាត់បន្ថយភាពយល់ដឹងរបស់ប្រជាពលរដ្ឋ ។

ដើម្បីបើកបង្ហាញអំពីបញ្ហាប្រឈមនានានៃការរៀបអាពាហ៍ពិពាហ៍ និងនីតិវិធីនៃការអនុវត្តច្បាប់របស់ប្រទេសកម្ពុជាបច្ចុប្បន្ន ។

ដើម្បីទុកជាឯកសារសម្រាប់សិក្សាស្រាវជ្រាវក្នុងបណ្ណាល័យ ដើម្បីជាប្រយោជន៍ដល់និស្សិតជំនាន់ក្រោយៗទៀត និងដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យប្រព័ន្ធច្បាប់នៅព្រះរាជាណាចក្រកម្ពុជាឱ្យបានកាន់តែប្រសើរឡើងទៀតផង ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី "**អាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន**" គឺក្រុមយើងខ្ញុំ បានធ្វើការស្វែងរកឯកសារដែលពាក់ព័ន្ធនានា នៅក្នុងបណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងតាមរយៈអ៊ីនធើណែត មេរៀនឯកសារដែលសិក្សារយៈពេលបួនឆ្នាំ ជាពិសេសច្បាប់និងបទដ្ឋានគតិយុត្តនានាដែលមានចែងជាធរមាន ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវប្រធានបទនេះ យើងខ្ញុំបានបែងចែកជា ២ ជំពូកគឺ

ជំពូកទី១ ចង់បង្ហាញអំពី "**សញ្ញាណទូទៅនិងលក្ខខណ្ឌគតិយុត្តនៃអាពាហ៍ពិពាហ៍**" ដែលក្នុងនោះបរិយាយអំពី និយមន័យនៃអាពាហ៍ពិពាហ៍ ប្រវត្តិនៃអាពាហ៍ គោលបំណងនៃការរៀបអាពាហ៍ពិពាហ៍ លក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍បាន និងលក្ខខណ្ឌដែលមិនអាចរៀបអាពាហ៍ពិពាហ៍បាន ជាពិសេសទៀតនោះគឺនិយាយទាក់ទងទៅនឹងអានុភាពនៃអាពាហ៍ពិពាហ៍ដែលមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ដូចជាការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ជាដើម ។

ជំពូកទី២ ចង់បង្ហាញអំពី "**បញ្ហាប្រឈមអាពាហ៍ពិពាហ៍នៅកម្ពុជាបច្ចុប្បន្ន**" ដែលនៅក្នុងជំពូកនេះនិយាយអំពីបញ្ហាប្រឈមនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ដែលបញ្ហាប្រឈមនៃអាពាហ៍ពិពាហ៍ទាំងនោះមានដូចជា៖ បញ្ហាភេទដូចគ្នា,បញ្ហាអាយុភាគី,បញ្ហាការបង្ខិត

បង្ខំពីឪពុក ម្តាយ អាណាព្យាបាល ឬតតិយជន,បញ្ហាវវាងញាតិនិងញាតិ,បញ្ហាមិនបានចុះបញ្ជី អាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល,បញ្ហាចូលសញ្ជាតិ ជាដើម ។

ការលម្អិតចំពោះខ្លឹមសារទាំងអស់នៃប្រធានបទនេះ នឹងធ្វើការបកស្រាយដូចខាងក្រោមនេះ ៖

# ជំពូកទី១

# សញ្ញាណទូទៅនិង
# លក្ខខណ្ឌគតិយុត្ត
# នៃអាពាហ៍ពិពាហ៍

# ជំពូកទី ១

# សញ្ញាណទូទៅនិងលក្ខខណ្ឌគតិយុត្តនៃអាពាហ៍ពិពាហ៍

## ផ្នែកទី១៖ សញ្ញាណទូទៅនៃអាពាហ៍ពិពាហ៍

### កថាខណ្ឌទី១. និយមន័យអាពាហ៍ពិពាហ៍

នៅក្នុងសង្គមខ្មែរ ពិធីរៀបអាពាហ៍ពិពាហ៍ (ពិធីរៀបមង្គលការ) ជាប្រពៃណីមួយដែលបញ្ញត្តិប្រហែលគ្មាននឹងកាតព្វកិច្ចដែរ ពីព្រោះបុគ្គលណា ដែលព្រមព្រៀងយកគ្នាជាប្តីប្រពន្ធ ត្រូវតែរៀបការទៅតាមដែលច្បាប់បានបញ្ញត្តិទុក ។ ប៉ុន្តែបើបុគ្គលណាគេចវេះពីពិធីនេះ ដោយស្ម័គ្រចិត្តរៀងខ្លួនយកគ្នាជាប្តីប្រពន្ធ នោះនឹងត្រូវចាត់ទុក ជាគ្មានសិរីសួស្តី គ្មានកិត្តិយស ទោះបីក្នុងសង្គមខ្មែរបច្ចុប្បន្នបានអនុម័ត ច្បាប់អនុញ្ញាតឲ្យបុគ្គលទាំងនោះយកគ្នាជាប្តីប្រពន្ធ ដោយផ្តល់អេតាស៊ីវិលទទួលស្គាល់ពួកគេក៏ដោយ។

ខ្មែរយើងតែងតែប្រើពាក្យ អាពាហ៍ពិពាហ៍ ឬ រៀបការ ទាំងក្នុងភាសា និយាយ និងសរសេរ។ ដើម្បីឆ្លើយតបឲ្យត្រូវនឹងចំណងជើងខាងលើស្តីអំពី "ចំណងរៀបអាពាហ៍ពិពាហ៍ខ្មែរ និងច្បាប់ឯកពន្ធភាព" យើងខ្ញុំសូមលើក យកពាក្យ អាពាហ៍ពិពាហ៍ មកពន្យល់សិន មុននឹងឈានទៅដល់ការរៀបរាប់ ពីពិធីផ្សេងៗទៀតក្នុងពិធីរៀបអាពាហ៍ពិពាហ៍ខ្មែរ។

ពាក្យ អាពាហ៍ពិពាហ៍ ត្រូវបានអ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរយើងធ្វើខ្មែរូបនីយកម្មចេញពីពាក្យ **អាវាហ វិវាហ** ដែលជាភាសាបាលី សំស្ក្រឹត។ អាពាហ៍ ពិពាហ៍ ឬ អាវាហ វិវាហ មានន័យថា មង្គលការ គូរបុរសស្ត្រីដែលបាននាំមក ហើយនាំត្រឡប់ទៅវិញ (ពីរលើក)។ អាវាហ (អាពាហ៍) មានន័យថា "នាំមក", វិវាហ (ពិពាហ៍) មានន័យថា "នាំត្រឡប់ទៅវិញ"។ អាវាហៈ (អាពាហ៍) គឺការនាំ កូនស្រីមកខាងលំនៅកូនប្រុស, រីឯការនាំកូនប្រុសត្រឡប់ទៅខាង លំនៅកូនស្រីវិញ ហៅថា វិវាហៈ (ពិពាហ៍)។ ប៉ុន្តែតាមទំនៀមខ្មែរ គឺត្រូវនាំកូនប្រុសមក ខាងលំនៅកូនស្រីមុន ហៅថា អាពាហ៍ (ត្រូវធ្វើពីល្ងាច), លុះដល់វេលាព្រឹក ត្រូវនាំកូនស្រីទៅឯរោងខាងកូនប្រុសវិញ ហៅថា ពិពាហ៍។ មង្គលការដែលបានធ្វើទាំងពីរបែបនេះទើបហៅថាមង្គលការអាពាហ៍ពិពាហ៍[១]។

អាពាហ៍ពិពាហ៍ ជាមូលដ្ឋានរបស់គ្រួសារ ព្រោះបុរស និងស្ត្រីជ្រើសរើសយកគ្នាជាគូស្វាមីភរិយា មានគោលបំណងកសាងគ្រួសារមួយ។ ចំណែកឯគ្រួសារវិញ គឺជាកោសិការបស់សង្គម អនុវត្តភារៈសំខាន់របស់សង្គម គឺភារៈពីការបង្កើត ភារៈពីការអប់រំ និងភារៈពីការកសាងសេដ្ឋកិច្ច។

---

[១] សៀវភៅ "អរិយធម៌ខ្មែរ" ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកវិទ្យាស្ថានភាសាបរទេស សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំ២០១៣

ម្យ៉ាងទៀត អាពាហ៍ពិពាហ៍ ជាចំណងមនោសញ្ចេតនារវាងបុរសម្នាក់ជាមួយស្ត្រីម្នាក់ដោយឈរលើមូលដ្ឋាន និងសមភាព ហើយត្រូវបានច្បាប់ទទួលស្គាល់[២]។

ដូច្នេះ អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ដែលប្ដេជ្ញាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ[៣]។

អាពាហ៍ពិពាហ៍ ជាចំណងអាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី មានន័យថា បុរស ឬស្ត្រីដែលមានវ័យគ្រប់ការតាមច្បាប់កំណត់អាចជ្រើសរើសយកប្ដី ឬប្រពន្ធបានដោយស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំពីអ្នកដទៃឡើយ គឺមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើស។ គេក៏មានសេរីភាពក្នុងការលែងលះដែរ បើយល់ឃើញថា គេពុំអាចរស់នៅ និងកសាងសុភមង្គលគ្រួសារបាន។

**កថាខណ្ឌទី២៖ ប្រវត្តិនៃអាពាហ៍ពិពាហ៍**

ប្រវត្តិអាពាហ៍ពិពាហ៍ ជាដំណើររឿងមួយដែលបានកើតឡើងតាំងពីសម័យបុព្វកាលមកម្ល៉េះដែលគ្មានអ្នកណាម្នាក់បានដឹងរឿងរ៉ាវនេះពិតប្រាកដ និងល្អិតល្អន់នោះទេ។ ប៉ុន្តែអ្វីដែលគ្រប់គ្នាបានដឹងនោះ គឺតាមរយៈចាស់ដែលជាឪពុកម្ដាយ ជីដូនជីតា នឹងស្នាដៃអក្សរសិល្ប៍មួយចំនួនរបស់អ្នកស្រាវជ្រាវ ដែលបានសរសេរចងក្រងជាឯកសារទុកសម្រាប់កូនខ្មែរជំនាន់ក្រោយៗឱ្យបានដឹង។ ទោះបីជា ឯកសារប្រវត្តិសាស្ត្រទាំងនោះមានលក្ខណៈខ្វះចន្លោះយ៉ាងណាក៏ដោយ ក៏វាបានបង្ហាញឱ្យអ្នកអានគ្រប់រូប បានដឹង និងស្គាល់អំពីអាពាហ៍ពិពាហ៍របស់ខ្មែរយើងនាសម័យដើម ដែលបានបន្សល់ទុករហូតមកដល់ពេលបច្ចុប្បន្ននេះ។

**១. ទំនៀមទម្លាប់ប្រពៃណី**

**ក. សម័យនគរភ្នំ**

នៅក្នុងសម័យនគរភ្នំ ជាសម័យសង្គម "មេនិយម" ឬស្ត្រីជាអធិបតី គឺគេទុកស្ត្រីជាធំក្នុងគ្រួសារ និងក្នុងសង្គមជាតិ។ ដូច្នេះស្ត្រីត្រូវទៅដណ្ដឹងប្រុសៗ។

**ខ. សម័យចេនឡា**

នៅក្នុងសម័យចេនឡា គេរាប់ខ្សែខាងម្ដាយ ដោយចាត់ទុកស្ត្រីជាធំដដែល ដូចសម័យនគរភ្នំដែរ។ តែនៅសម័យនេះការជ្រើសរើសគូស្រករ បុរសត្រូវទៅដណ្ដឹងស្ត្រី។ ត្រង់នេះឃើញថា មានការវិវត្តប្លែកពីសម័យនគរភ្នំ ដែលស្ត្រីត្រូវទៅដណ្ដឹងបុរស មុនដំបូងខាងបុរសត្រូវលើកជំនូនទៅជូន

[២] សាស្ត្រាចារ្យ អម សុផាណារ៉ាត ២០១៤-២០១៥ នីតិរដ្ឋប្បវេណី

[៣] មាត្រា ៣ នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

គ្រួសារខាងស្ត្រីដែលខ្លួនពេញចិត្ត។ បន្ទាប់មកខាងស្ត្រីត្រូវជ្រើសរើសថ្ងៃមង្គល ដើម្បីនាំកូនស្រីទៅផ្ទះខាងប្រុសតាមរយៈមេអណ្ដើកម្នាក់ ។ គ្រួសារទាំងសងខាងស្ថិតក្នុងផ្ទះអស់ ៨ថ្ងៃដោយពុំមានចេញទៅណាមកណា ហើយដោយមានដុតចង្កៀងទាំងយប់ទាំងថ្ងៃ។ លុះពិធីមង្គលការចប់សព្វគ្រប់ហើយ កូនប្រុសទទួលមត៌កពីឪពុកម្ដាយបង្កើតរបស់ខ្លួន ហើយចែកផ្ទះទៅនៅដោយ ឡែក។ ដល់ពេលឪពុកម្ដាយស្លាប់ទៅ ពួកកូនដែលនៅលីវអាចទទួលមរតកដែលនៅសល់ទាំងអស់។ ប៉ុន្តែប្រសិនបើកូនទាំងអស់នោះមានប្ដីប្រពន្ធហើយ បានទទួលមរតករួចហើយ នោះទ្រព្យដែលនៅសល់ត្រូវបញ្ជូនទៅក្នុងឃ្លាំងជាតិ។

**២. តាមច្បាប់**

**ក.សម័យសង្គមរាស្ត្រនិយម**

ច្បាប់សម័យសង្គមរាស្ត្រនិយម បានឱ្យតម្លៃលើបុរសធំជាងស្ត្រី នេះដោយសារប្រទេសកម្ពុជានាសម័យនោះប្រកាន់របបរាជាណាចក្រ ដែលស្ដេចមានអំណាចជាធំ ទើបច្បាប់ក៏តែងតម្រូវតាមផ្នត់គំនិតរបស់ថ្នាក់ដឹកនាំ និងតម្រូវតាមស្ថានភាពជាក់ស្ដែង នៃយុគសម័យនោះផង។

**ខ.សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា**

ការរៀបអាពាហ៍ពិពាហ៍ក្នុងសម័យនោះឃើញថា តាមទីស្នាក់ការឃុំនីមួយៗ មានអង្គការសមាគមយុវជន យុវនារី ដែលជាអង្គការមានសមត្ថកិច្ចអនុញ្ញាត ឱ្យរៀបអាពាហ៍ពិពាហ៍ ដោះស្រាយបណ្ដឹងទាស់ ដោះស្រាយលើរាល់ពាក្យបណ្ដឹងលែងលះ (ផ្សះផ្សា និងអនុញ្ញាតឱ្យលែងលះ) ហើយប្រធាន យុវជន យុវនារីគឺមេឃុំ។

សម័យកាលយុត្តិធម៌ឃុំ ស្រុក សង្កាត់ ជាអ្នកផ្សព្វផ្សាយ ដោះស្រាយរឿងរដ្ឋប្បវេណី និងរឿងគ្រួសារ ដើម្បីរក្សានូវសណ្ដាប់ធ្នាប់សង្គម។ តែបើរឿងណាមានលក្ខណៈស្មុគស្មាញទើបបញ្ជូនទៅតុលាការ មានន័យថាគ្រប់រឿងរដ្ឋប្បវេណី និងរឿងគ្រួសារ គេប្រគល់សមត្ថកិច្ចទៅឱ្យយុត្តិធម៌មូលដ្ឋានផ្សះផ្សា ដោះស្រាយឱ្យអស់លទ្ធភាពជាមុនសិន។ បើផ្សះផ្សា និងដោះស្រាយមិនបានសម្រេចទើបធ្វើរបាយការណ៍វាយតម្លៃពីការមិនស្រុះស្រួលគ្នាបញ្ជូនទៅតុលាការ។ ក្នុងករណីនេះ គឺដើម្បីជួយសម្រួលដល់ការងារ ដែលមានចំនួនច្រើនហួសប្រមាណចំពោះតុលាការ។

ចំណែកច្បាប់នាពេលបច្ចុប្បន្ន ដែលយើងខ្ញុំលើកយកមកធ្វើការបកស្រាយនេះ បានឆ្លងកាត់នូវដំណាក់កាលជាច្រើន តាំងពីសម័យបុរាណរហូតមកដល់សម័យទំនើប ហើយដែលបានធ្វើការផ្លាស់ប្ដូរនូវអត្ថន័យ ក៏ដូចជាខ្លឹមសារមួយចំនួន ដើម្បីឱ្យមានលក្ខណៈល្អប្រសើរទៅតាមសម័យកាលនីមួយៗរបស់ប្រទេស។

**កថាខណ្ឌទី៣៖ គោលបំណងនៃអាពាហ៍ពិពាហ៍**

ក្រោយការភ្ជាប់ពាក្យ ការរៀបការត្រូវតែប្រារព្ធធ្វើឡើងតាមប្រពៃណីជាតិ បន្ទាប់ពីបានសុំការអនុញ្ញាតច្បាប់។ ពិធីរៀបអាពាហ៍ពិពាហ៍ជា ពិធីមួយដែលរៀបចំឡើងសម្រាប់ផ្សំផ្គុំមនុស្សប្រុស ស្រីឱ្យក្លាយជាប្តីប្រពន្ធ។

មនុស្សត្រូវតែរៀបអាពាហ៍ពិពាហ៍ដោយហេតុថា៖

- កសាងគ្រួសារដោយមានការទទួលស្គាល់ពីច្បាប់ ប្រពៃណី សង្គម
- បង្កើត និងចិញ្ចឹមបីបាច់ថែរក្សាកូន ដើម្បីបន្តពូជពង្សវង្សត្រកូល
- បំពេញតម្រូវការខាងជីវសាស្ត្រ
- ធ្វើឱ្យអ្នកដែលយើងស្រឡាញ់មានចិត្តសប្បាយរីករាយ ធានាសុវត្ថិភាព សេចក្តីស្រឡាញ់ និងអារម្មណ៍
- រស់នៅដោយខ្លួនឯងមិនពឹងពាក់លើឪពុកម្តាយ
- បង្កើតជាក្រុមគ្រួសារសម្រាប់សុភមង្គលក្នុងជីវិត ។

## ផ្នែកទី២៖ លក្ខខណ្ឌគ្រឹះនៃអាពាហ៍ពិពាហ៍

ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយ ដែលត្រូវតាមទៅច្បាប់នឹងមានអានុភាពបាននោះ បើយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់នូវលក្ខខណ្ឌចាំបាច់មួយចំនួន ដែលត្រូវតម្រូវឱ្យភាគីទាំងសងខាង ត្រូវគោរពជាដាច់ខាត ។ ជារួមមក គឺត្រូវមានលក្ខខណ្ឌទាំងនេះដូចជា ៖

**កថាខណ្ឌទី១៖ លក្ខខណ្ឌធម្មជាតិ**

**១.លក្ខខណ្ឌរូបរាងកាយបុគ្គល**

ដើម្បីឱ្យអាពាហ៍ពិពាហ៍មួយអាចប្រព្រឹត្តទៅបាន លុះត្រាតែគូភាគីដែលជាអនាគតប្តីប្រពន្ធបានបំពេញទៅតាមលក្ខខណ្ឌ ដូចជាត្រូវមានភេទខុសគ្នា ត្រូវមានអាយុពេញលក្ខណ:ច្បាប់ ហើយត្រូវមានសុខភាពល្អផងដែរ។

**២.លក្ខខណ្ឌភេទ**

អនាគតប្តីប្រពន្ធ ចាំបាច់ត្រូវមានភេទផ្ទុយគ្នា ទើបច្បាប់ទទួលស្គាល់។ អាពាហ៍ពិពាហ៍រវាងមនុស្សភេទដូចគ្នា ច្បាប់មិនទទួលស្គាល់ឡើយ ដូច្នេះដើម្បីឱ្យអាពាហ៍ពិពាហ៍មួយស្របច្បាប់ សាមីជនត្រូវមានភេទផ្ទុយគ្នា[៦]។ ប្រសិនបើមានមានបុគ្គលណាដែលមានភេទដូចគ្នា ដែលចង់រៀបការ គឺនៅកម្ពុជាយើងបច្ចុប្បន្នពុំទាន់មានការទទួលស្គាល់ថា ជនដែលរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នា ត្រូវ

[៦] មាត្រា ៦ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

ច្បាប់ទទួលស្គាល់តាមច្បាប់នៅឡើយទេ ដូចនេះភាគីទាំងពីរត្រូវតែមានភេទផ្ទុយគ្នា (បុរស និង ស្ត្រី) ។

### ៣.លក្ខខណ្ឌអាយុ

នៅក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់នូវអាយុជាក់លាក់ ដែលអាចអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន គឺមាត្រា៩៤៨ បានកំណត់ថា បុរស និងនារី ដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជានីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំអាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។ សូមបញ្ជាក់ថា ភាគីណាម្នាក់នឹងបានដល់នីតិភាព នៅពេលដែលគេមានអាយុ១៨ឆ្នាំ ឬក៏ទទួលបាននូវអគ្គាធិនភាព ។ ក្នុងករណីដែលគេទទួលបាននូវអគ្គាធិនភាព គឺមានពីរករណីករណីទី១ គឺតាមដីកាសម្រេចរបស់តុលាការ ដោយផ្អែកតាមពាក្យស្នើសុំរបស់អនីតិជន ដែលបានដល់អាយុ១៦ឆ្នាំ ។ ករណីទី២ គឺតាមរយៈការរៀបអាពាហ៍ពិពាហ៍របស់អនីតិជន[៥]។

យោងតាមច្បាប់ស្តីពី អាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩ ចែងថា អាពាហ៍ពិពាហ៍នឹងចាត់ទុកថាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន គឺបុរសត្រូវមានអាយុចាប់ពី ២០ឆ្នាំឡើង និងនារីត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បានប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល[៦]។

ប្រសិនបើយើងក្រឡេកមកមើលក្រមរដ្ឋប្បវេណីថ្មី ២០០៧ នេះវិញ នោះយើងនឹងឃើញថាវាមានលក្ខណៈខុសគ្នាដោយ បុរស និងនារីដែលមិនទាន់ដល់នីតិភាពអាយុ១៨ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជានីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំអាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ[៧]។

---

[៥]សាស្ត្រាចារ្យ រ៉ុន ពណ្ណារិទ្ធ នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ

[៦]មាត្រា ៥ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

[៧]មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ២០០៧

### ៤.លក្ខខណ្ឌសុខភាព

សុខភាពត្រូវមានការពិនិត្យពីគ្រូពេទ្យ។ ច្បាប់អាពាហ៍ពិពាហ៍ខ្មែរ ពុំបានកំណត់ឱ្យគូភាគីនៃអនាគតប្តី ប្រពន្ធត្រូវតែទទួលការពិនិត្យពីគ្រូពេទ្យនោះទេ។ ដូច្នោះទោះជាគ្មានវិញ្ញាបនបត្របញ្ជាក់ពីគ្រូពេទ្យ ក៏មន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យរៀបការដែរ។ ប៉ុន្តែបើយើងពិនិត្យមើលមាត្រា ៦ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ គឺហាក់ដូចជាតម្រូវឱ្យអនាគតប្តី ប្រពន្ធត្រូវទៅមន្ទីរពេទ្យ ដើម្បីពិនិត្យមើលពីស្ថានភាពខ្លួនឯងថា តើមានជំងឺឬទេ។

### ៥. ការព្រមព្រៀងពីភាគីប្តីប្រពន្ធ

ចំពោះការព្រមព្រៀងនេះ រវាងភាគីប្តីប្រពន្ធ ធ្វើឡើងដោយការស្ម័គ្រចិត្តទាំងបុរស ទាំងនារីដោយខ្លួនឯងពោលគឺគេមានសេរីភាពគ្រប់គ្រាន់ក្នុងការសម្រេចអំពីរឿងនេះ ថាតើពួកគេចង់រៀបអាពាហ៍ពិពាហ៍ដែរឬទេ? ម្យ៉ាងវិញទៀត ពួកគេមានសិទ្ធិពេញលេញក្នុងការជ្រើសរើសគូស្រករដោយភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ។ ឪពុកម្តាយ ក៏ពុំអាចបង្ខិតបង្ខំកូនបានដែរ[៨]។

ការព្រមព្រៀងរបស់អនាគតប្តី ប្រពន្ធចែកចេញជាពីរផ្នែកផ្សេងគ្នាគឺ៖

#### ក. ការព្រមព្រៀងមុនរៀបអាពាហ៍ពិពាហ៍

**+. មេអណ្តើក និងអ្នកចូលចែចូវ**

មេអណ្តើក ឬអ្នកចែចូវនេះ គឺជាមនុស្សណាម្នាក់ដែលមានវ័យចំណាស់ ពូកែនិយាយបញ្ចុះបញ្ចូលឱ្យមេបាខាងស្រីមានការទុកចិត្តលើកូនកំលោះ។ ការចូលចែចូវនេះ គេត្រូវសួរដេញដោលគ្នាពីពូជពង្សវតារថាតើជាមនុស្សល្អឬអាក្រក់? នេះជាការសុំឱ្យមានការព្រមព្រៀងលើកទី១ប៉ុណ្ណោះ។ ពិធីនេះធ្វើឡើងដើម្បីឱ្យឪពុកម្តាយទាំងសងខាងបានស្គាល់គ្នាផង និងភាគីអនាគតប្តីប្រពន្ធបានស្គាល់គ្នាផង។

ពេលភាគីខាងស្រី យល់ព្រមហើយពិធីលើកជំនូន ត្រូវកើតមានឡើងក្រោយពេលនោះគឺប្រហែលជាពីរ ឬបីថ្ងៃ ឬក៏អាចច្រើនជាងនេះ។

#### ខ. ពិធីកំជាប់ពាក្យ ឬការភ្ជាប់ពាក្យ

ប្រពៃណីត្រូវបានគោរពយ៉ាងហ្មត់ចត់បំផុត សូម្បីតែច្បាប់ក៏មិនហ៊ានបំពាន មិនត្រឹមតែមិនហ៊ានបំពាន ប៉ុន្តែបានចែងគាំទ្របង្កើត ប្រពៃណីនោះឱ្យទៅជាច្បាប់ទៀតផង។ នៅក្នុងទំនាក់ទំនងស្នេហារវាងបុរស និងស្ត្រីចាំបាច់ត្រូវធ្វើឡើងតាមនីតិវិធីប្រពៃណីទំនៀមទំលាប់ ហើយនីតិវិធីនេះ

[៨]មាត្រា ៩ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

ត្រូវការប្រើពេលអស់ច្រើនថ្ងៃ ដោយគិតពីថ្ងៃចូលស្ដីដណ្ដឹង ឬភ្ជាប់ពាក្យ និងថ្ងៃរៀបពិធីអាពាហ៍ពិពាហ៍។ មនុស្សភាពច្រើនបានស្គាល់អំពីគុណតម្លៃនៃ ពិធីភ្ជាប់ពាក្យតាមប្រពៃណី ទំនៀមទំលាប់យ៉ាងច្បាស់លាស់ ប៉ុន្តែក៏មានមនុស្សភាគច្រើនដែរ ដែលមិនបានស្គាល់តម្លៃផ្លូវច្បាប់ ឬតម្លៃគតិយុត្តនៃពិធីកំជាប់ពាក្យ ថាតើវាជាអ្វី ឬទិដ្ឋភាពទូទៅនៃកំជាប់ពាក្យ ការទទួលខុសត្រូវនិងនីតិវិធី ដើម្បីទាមទារឱ្យមានការទទួលខុសត្រូវបែបណានៅឡើយ។ យើងនឹងសិក្សាទាំង អស់គ្នា នូវតម្លៃជាផ្លូវច្បាប់ដូចតទៅ ៖

ពិធីកំជាប់ពាក្យ បង្កប់តម្លៃជាប្រពៃណីផង និងមានតម្លៃជាផ្លូវច្បាប់ផងដែរ។ យើងខ្ញុំសូមមិនលើកពិភាក្សាអំពីតម្លៃជាប្រពៃណីទេ ប៉ុន្តែយើងសូមលើកយក តម្លៃជាផ្លូវច្បាប់នៃការបង្កើតកិច្ចសន្យាកំជាប់ពាក្យ និងការរំលាយកិច្ចសន្យាកំជាប់ពាក្យ។

កំជាប់ពាក្យគឺជាកិច្ចសន្យាដែលបង្កើតឡើងដោយ ការព្រមព្រៀងរវាងកូនកំលោះ និងកូនក្រមុំ ឬរវាងអំណាចមេបាទាំងសងខាង ឬតាមប្រពៃណី ហើយពិធីនេះផងដែរ យើងនឹងពិនិត្យទៅលើទិដ្ឋភាពប្រពៃណី និងទិដ្ឋភាពច្បាប់ ។

**-ទិដ្ឋភាពប្រពៃណី**

ជាទូទៅនៅក្នុងប្រពៃណីទំនៀមទម្លាប់ខ្មែរ កំជាប់ពាក្យ ឬ ជាទូទៅត្រូវបានហៅថា «ភ្ជាប់ពាក្យ» គឺជាពីធីបែបប្រពៃណីមួយ ដែលត្រូវបានប្រជានជនខ្មែរអនុវត្តតៗគ្នាតាំងពីបុរាណកាលរហូតមកដល់ពេលបច្ចុប្បន្ននេះ ក្នុងគោលបំណងភ្ជាប់នូវសម្ព័ន្ធភាពរវាងគ្រួសារពីរ មុននឹងឈានដល់ពិធីអាពាហ៍ពិពាហ៍ជាឱឡារឹក។ យើងសម្គាល់ឃើញថា បុរស និងនារី ដែលមានបំណងនឹងរៀបអាពាហ៍ពិពាហ៍ តែងតែរៀបចំនូវពិធីកំជាប់ពាក្យនេះឡើង ដោយហៅជាសាមញ្ញថាពិធីស្ដីដណ្ដឹង ឬ តាមប្រពៃណីហៅថា «ពិធីលើកស្លា» ដែលក្នុងពិធីនេះយើងឃើញថា ភាគីខាងបុរស(កូនប្រុស) រៀបចំជូន ជំនូន បណ្ណាការ ជូនទៅខាងនារី ដោយមានការចូលរួមពីឪពុកម្ដាយ ញាតិមិត្ត បងប្អូនទាំងសងខាង ដើម្បីចូលចៃចូវ។

**-ទិដ្ឋភាពច្បាប់**

យោងតាមមាត្រា៩៤៤ កំជាប់ពាក្យត្រូវបានបង្កើតឡើងតាមការសន្យារវាងបុរស និងនារីថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាថ្ងៃអនាគត ដោយធ្វើពិធីកំជាប់ពាក្យ។ ក្នុងន័យនេះគឺជាកិច្ចសន្យារវាងបុរស និងនារី ដោយឈលើការគោរពយ៉ាងតឹងរឹងនូវឆន្ទៈ ប៉ុន្តែមិនមែនគោរពលើឆន្ទៈរបស់ឪពុកម្ដាយ ឬមេបានោះទេ ប៉ុន្តែជាក់ស្ដែង នៅក្នុងសង្គមខ្មែរ កំជាប់ពាក្យត្រូវបានគោរពតាម

ឆន្ទៈរបស់ឪពុកម្ដាយទៅវិញ ដោយកូនប្រុស កូនស្រីធ្វើជាផ្ដល់កិត្តិយសជូនទៅ ឪពុកម្ដាយរបស់ គេរៀងៗខ្លួនទៅ តាមប្រពៃណី។ ប៉ុន្តែតាមការពិតជាក់ស្ដែងពួកគេបានព្រមព្រៀងគ្នាជាមុនស្រេចទៅហើយ ទើបមានថ្ងៃភ្ជាប់ពាក្យជាផ្លូវការ តាមប្រពៃណីនេះកើតឡើង។

### គ. និយមន័យ

កំជាប់ពាក្យ ជាពិធីតាមទំនៀមទម្លាប់ប្រពៃណី ដែលច្បាប់ទទួលស្គាល់ ដែលតាមរយៈពិធីនេះបុរស និងនារីសន្យាថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានាពេលអនាគត។

កំជាប់ពាក្យគឺជាកិច្ចសន្យាមួយចំពោះគ្រួសារខាងស្រី ក៏ដូចខាងប្រុស ដើម្បីបង្ហាញភ្ញៀវ និងញាតិមិត្ត ជិតឆ្ងាយឱ្យបានដឹងថា គូស្រករទាំងពីរនេះ ព្រមព្រៀងសុខចិត្ត សុខកាយជាមួយគ្នា ដើម្បីរៀបអាពាហ៍ពិពាហ៍នាពេលខាងមុខ[៩] ។

### ឃ. អានុភាពនៃកំជាប់ពាក្យ

កំជាប់ពាក្យធ្វើឱ្យគូដណ្ដឹងខាងប្រុសស្រី ដែលត្រូវរៀបការនៅពេលខាងមុខនោះមានកាតព្វកិច្ចត្រូវគោរព និងស្រឡាញ់ចំពោះគ្នាទៅវិញទៅមករហូតដល់ថ្ងៃរៀបអាពាហ៍ពិពាហ៍។

### ង. ការប្ដឹងទាមទារសំណងខូចខាត

តាមការកត់សំគាល់ នៅក្នុងទំនាក់ទំនងនៃកំជាប់ពាក្យយើងសង្កេតឃើញថា មានគូស្រករមួយចំនួនបានសម្រេចបំណងដល់បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា ហើយរួមរស់ជាគូស្វាមីភរិយាតទៅ ។ ប៉ុន្តែមានករណីខ្លះទៀត បុរសនារីដែលបានប្រារព្ធពីធីកំជាប់ពាក្យហើយ ក៏មិនអាចសម្រេចបាននូវអាពាហ៍ពិពាហ៍ជាមួយគ្នាផងដែរ ដោយត្រូវរំលាយកំជាប់ពាក្យទៅវិញ។

យោងតាមសេចក្ដីព្រាងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បើកំជាប់ពាក្យត្រូវផ្ដាច់ដោយភាគីណាមួយដោយគ្មានហេតុផលនោះភាគីដែលខូចប្រយោជន៍អាចប្ដឹងទាមទារសំណងជំងឺចិត្តពីភាគីដែលផ្ដាច់ពាក្យនោះបាន។ បើខាងស្រីធ្វើការផ្ដាច់កំជាប់ពាក្យដោយគ្មានមូលហេតុអ្វីបន្តិចនោះ ភាគីខាងប្រុសអាចប្ដឹងទាមទារឱ្យសងបណ្ណាការវិញ ព្រមទាំងជំងឺចិត្តផ្សេងៗទៀត បើខ្លួនយល់ឃើញថា ការដែលផ្ដាច់ពាក្យនោះបានធ្វើឱ្យខូចប្រយោជន៍យ៉ាងធ្ងន់ធ្ងរ[១០] ។ ការប្ដឹងសុំជួសជុលការខូចខាតត្រូវ ធ្វើ

---

[៩] ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគទី២ សមិទ្ធផលរបស់ប្រព័ន្ធគម្រោងអភិវឌ្ឍន៍ប្រពន្ធច្បាប់និងតុលាការ
[១០] មាត្រា ៩៤៥ និងមាត្រា ៩៤៦ ក្រមរដ្ឋប្បវេណី ២០០៧

តែក្នុងអំឡុងពេល ១២ ខែ (ក្រមរដ្ឋប្បវេណីចាស់)។ ក្នុងក្រមរដ្ឋប្បវេណីថ្មី២០០៧ គឺអំឡុងពេល ១ ឆ្នាំ គិតចាប់ពីថ្ងៃដែលកំជាប់ពាក្យនោះត្រូវបានរំលាយ[១១]។

មូលហេតុនៃការរំលាយកំជាប់ពាក្យមានខាងក្រោមៈ

**-ការរលាយដោយមូលហេតុសមរម្យ**

មានស្ថានភាពជាច្រើនដែលនាំឱ្យគោលបំណងនៃកំជាប់ពាក្យមិនបានសម្រេច ដែលជាហេតុនាំឱ្យកំជាប់ពាក្យត្រូវបានរំលាយដូចជា ការទទួលមរណៈភាពរបស់ ភាគីម្ខាង ឬទាំងពីរខាង។ ការប្រព្រឹត្តកំហុសធ្ងន់ធ្ងរដោយភាគីម្ខាងទៀតដូចជាលួចទៅមានស្នេហាថ្មី ឬភ្ជាប់ពាក្យជាមួយអ្នកដទៃ ឬដោយចំណងអាពាហ៍ពិពាហ៍ចាស់ មិនទាន់ដាច់ស្រេចជាដើម។ មូលហេតុសមរម្យនេះគឺមិនអាចទាមទារសំណងបានឡើយ។

**-ការរលាយដោយ ការព្រមព្រៀង ដោយគូដណ្តឹងទាំងសងខាង**

ប្រសើរជាងនេះ កិច្ចសន្យាកំជាប់ពាក្យត្រូវបានរលាយដោយការព្រមព្រៀងគ្នាជាអាទិ៍។ បុរសមើលទៅមិនអាចទទួលយកនារីជាប្រពន្ធ ហើយនារីអាចប្រហែលជា មិនអាចទុកចិត្តបុរសជាប្តីបានជាដើម ម្ល៉ោះហើយទាំងនេះសុទ្ធសឹងតែជាមូលហេតុនៃការរំលាយកំជាប់ពាក្យ។ អ្វីដែលគួរកត់សំគាល់ បើតាមកិច្ចសន្យានេះ គឺមានការតែការព្រមព្រៀងរបស់អនាគតប្តីប្រពន្ធទាំងពីរទេដែលអាចព្រមព្រៀងរំលាយកិច្ចសន្យានេះបាន ប៉ុន្តែមេបា ឬឪពុកម្តាយក៏អាចរំលាយបានដោយ ស្របច្បាប់ផងដែរប្រសិនបើទទួលបានការអនុញ្ញាតជាមុនពីកូនរបស់ពួកគាត់រៀងៗខ្លួន។

## ៦.ការព្រមព្រៀងក្នុងពេលរៀបអាពាហ៍ពិពាហ៍

### ក. ការយល់ព្រមរបស់គូស្រករ

ការយល់ព្រមត្រូវតែប្រកាសដោយផ្ទាល់ពីសាមីខ្លួនផ្ទាល់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន និងចុះលិខិតអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។ ការយល់ព្រមត្រូវតែមានលក្ខណៈ ប្រាកដប្រជា និងដោយសតិសម្បជញ្ញៈ។

ការយល់ព្រមដោយប្រាកដប្រជា ក្នុងច្បាប់ខ្មែរពុំបានចែងច្បាស់លាស់ទេ គឺបើមានរឿងក្តីកើតឡើង គឺអាស្រ័យទៅលើចៅក្រមជាអ្នកវិនិច្ឆ័យ។

ការយល់ព្រមដោយសតិសម្បជញ្ញៈ ការយល់ព្រមនេះ ត្រូវតែចេញមកពីជនមិនវិកលចរិត។ ការរៀបអាពាហ៍ពិពាហ៍ក្នុងពេលគ្មានភាពវិកលចរិតនៃបុគ្គលណាម្នាក់ មានន័យថានៅចន្លោះនៃ

---

[១១]មាត្រា ៩៤៧ ក្រមរដ្ឋប្បវេណី ២០០៧

ភាពគវិកលចរិតច្បាប់ចាត់ទុកថាជាត្រឹមត្រូវ ព្រោះអាពាហ៍ពិពាហ៍មានសុពលភាព ដោយមនុស្សវិកលចរិតអាចធ្វើកិច្ចសន្យាបានក្នុងចន្លោះពេលដែលខ្លួនមិនវិកលចរិត។

### ខ. ការព្រមព្រៀងពីឪពុកម្តាយ

ជាប្រពៃណីកូនត្រូវគោរពឪពុកម្តាយ កូនស្ថិតក្រោមការគ្រប់គ្រង ថែរក្សា និងអប់រំរបស់ឪពុកម្តាយ។ ក្នុងបញ្ហារើសគូស្រករ គួរត្រូវបានសម្រេច និងយល់ព្រមពីឪពុកម្តាយ។

#### +. ក្នុងករណីនីតិជន

យោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ឆ្នាំ១៩៨៩ ចំពោះបុរសមានអាយុ២០ឆ្នាំ និងនារីអាយុ១៨ឆ្នាំឡើងទៅអាចរៀបអាពាហ៍ពិពាហ៍បាន ដោយពុំចាំបាច់មានការអនុញ្ញាតពីឪពុកម្តាយ បើទោះជាអាពាហ៍ពិពាហ៍នោះផ្ទុយ ឬមិនផ្ទុយពីឆន្ទៈរបស់ឪពុកម្តាយក៏ដោយ។

ចំណែកនៅក្នុងមាត្រា៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានកំណត់នូវអាយុជាក់លាក់ដែលអាចអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍បាន គឺអាយុ១៨ឆ្នាំ បានកំណត់ថា បុរស និងនារី ដែលមិនទាន់ដល់នីតិភាពមិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។

#### +. ក្នុងករណីជាអនីតិជន

**ជនទទួលបានអត្តាធីនភាព៖** អនីតិជនដែលទទួលបានអត្តាធីនភាព ត្រូវបានចាត់ទុកជានីតិជន[១២] ។ ដូច្នេះអនីតិជនដែលទទួលបានអត្តាធីនភាពនេះមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ដោយមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល។ ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះកើតឡើងរវាងអនីតិជនទទួលបានអត្តាធីនភាព និងអនីតិជន ការរៀបអាពាហ៍ពិពាហ៍នោះត្រូវមានការយល់ព្រមពីឪពុកម្តាយ។ ប៉ុន្តែប្រសិនបើអាពាហ៍ពិពាហ៍នោះកើតឡើងរវាងអនីតិជនដែលទទួលបានអត្តាធីនភាពទាំងសងខាង ឬទាំងពីរពួកគេអាចរៀបអាពាហ៍ពិពាហ៍បាន ទោះបីជាមានការប្រឆាំងពីឪពុកម្តាយក៏ដោយ។

**អនីតិជន និងនីតិជន៖** ក្នុងករណីដែលអាពាហ៍ពិពាហ៍ធ្វើឡើងរវាងអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំ ជាមួយនីតិជន ការរៀបអាពាហ៍ពិពាហ៍នេះត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលទូទៅសម្រាប់អនីតិជនរបស់អនីតិជននោះ[១៣] ។ ក្នុងករណីនេះផងដែរ ប្រសិនបើអ្នកមានអំណាចមេបាណាម្ខាងមិនយល់ព្រមទេ គ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមាន

---

[១២]មាត្រា ៩៥ ក្រមរដ្ឋប្បវេណី ២០០៧

[១៣]មាត្រា ៩៤៨ ក្រមរដ្ឋប្បវេណី ២០០៧

អំណាចមេបាម្ខាងជាការគ្រប់គ្រាន់[១៤]។ ប៉ុន្តែក្នុងករណីនេះអាចធ្វើទៅបានលុះត្រាតែគូស្រករទាំងពីរពិតជាមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាពិតមែន។

**ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ៖** អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ ក្នុងកម្រិតអប្បបរមាដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ[១៥]។ មានន័យថា ជនវិកលចរិតនេះអាចសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯងបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ។

### គ. ការយល់ព្រមរៀបអាពាហ៍ពិពាហ៍របស់អនីតិជន

#### +. ចំពោះកូនមានខាន់ស្លា

បើឪពុក និងម្តាយនៅរស់ ជាគោលការណ៍ច្បាប់ អនីតិជនត្រូវមានការយល់ព្រមពីឪពុកម្តាយទាំងពីរ។

ប៉ុន្តែបើជាគោលការណ៍ បើឪពុក ឬម្តាយមានម្នាក់ស្លាប់ ឬស្ថិតនៅក្នុងស្ថានភាពមិនអាចសម្តែងឆន្ទៈបាននោះការយល់ព្រមតែម្ខាងគឺជាការគ្រប់គ្រាន់។

បើឪពុកម្តាយរបស់អនីតិជនស្លាប់ទាំងអស់ សិទ្ធិនៃការយល់ព្រមឱ្យរៀបអាពាហ៍ពិពាហ៍ធ្លាក់លើបុព្វញាតិរបស់គេ។

#### +. ចំពោះកូនឥតខាន់ស្លា

បើឪពុកម្តាយទទួលស្គាល់កូននោះទាំងអស់គ្នា ការយល់ព្រមត្រូវមានពីឪពុកម្តាយទាំងពីរ ហើយដំណើរការផ្សេងៗកើតមានឡើងដូចគ្នានឹងកូនមានខាន់ស្លាដែរ។

បើមានតែឪពុក ឬមានតែម្តាយទទួលស្គាល់កូននោះ ការយល់ព្រមទុកជាសុពលភាព គឺត្រូវចេញពីឪពុក ឬម្តាយដែលទទួលស្គាល់កូននោះ។

បើកូនឥតខាន់ស្លានោះឪពុក និងម្តាយមិនទទួលស្គាល់ទេ ឬឪពុកម្តាយទាំងពីរស្លាប់ ឬពុំអាចបញ្ចេញឆន្ទៈបាន ការផ្តល់ការយល់ព្រមជាសមត្ថកិច្ចរបស់រដ្ឋអំណាច។

#### +. ចំពោះកូនចិញ្ចឹម

វាមានដំណើរការដូចគ្នានឹងដំណើរការនៃការផ្តល់ការយល់ព្រមទៅឱ្យកូនមានខាន់ស្លាដែរ។

[១៤]មាត្រា ៩៨៣ ក្រមរដ្ឋប្បវេណី ២០០៧

[១៥]មាត្រា ៩៥៤ ក្រមរដ្ឋប្បវេណី ២០០៧

## កថាខណ្ឌទី២៖ លក្ខខណ្ឌទម្រង់នៃអាពាហ៍ពិពាហ៍

### ១. លក្ខខណ្ឌមុនពេលរៀបអាពាហ៍ពិពាហ៍

#### ក. ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍មានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។

ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសារធារណៈការចុះកិច្ចសន្យាអាពាហ៍-ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវកំណត់ទៅតាមនីតិវិធីស្តីពីការចុះបញ្ជីអត្រានុកូល-ដ្ឋាន[១៦]។

**❋ចំពោះការផ្តល់ឯកសារត្រូវមាន៖**

- ការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល ចំពោះអនីតិជន។
- ភស្តុតាងនៃការរំលាយអាពាហ៍ពិពាហ៍មុនមានដូចជា សាលក្រមលែងលះ សាលក្រមស្តីពីការបាត់ខ្លួន ឬសំបុត្រមរណភាព ឬមោឃភាពនៃអាពាហ៍ពិពាហ៍។
- សំបុត្របញ្ជាក់ថាបានគោរពវិធវភាព
- ការអនុញ្ញាតក្នុងករណីដែលគូស្រករមានជាប់ញាតិ និងញាតិពន្ធ
- លិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន ឬពីកន្លែងការងារថាខ្លួនពិតជានៅលីវ(លិខិតនេះហៅថា កិច្ចសន្យាសាមីជនកូនប្រុស ស្រី)
- ពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់កូនប្រុស(ករណីកូនប្រុស និងកូនស្រីមានលំនៅឋានក្នុងឃុំ សង្កាត់ខុសគ្នា)
- ក្រោយពីបានឯកសារនេះហើយ ខាងប្រុសត្រូវយកលិខិតនេះភ្ជាប់មកជាមួយបែបបទសុំរៀបអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់នាលំនៅឋានរបស់នារី។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ពុំអាចទទួលយកបានឡើយ បើបានទទួលស្គាល់ថាអាពាហ៍ពិពាហ៍នោះផ្ទុយនឹងបញ្ញត្តិច្បាប់ ចាប់ពីមាត្រា ៩៤៨ (អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍) រហូតដល់មាត្រា ៩៥៤ (ការរៀបអាពាហ៍ពិពាហ៍របស់ជននៅក្រោមអាណាព្យាបាលទូទៅ) ឬបទដ្ឋានគតិយុត្តផ្សេងទៀត[១៧]។

---

[១៦] មាត្រា ៩៥៥ ក្រមរដ្ឋប្បវេណី ២០០៧

[១៧] មាត្រា ៩៥៦ ក្រមរដ្ឋប្បវេណី ២០០៧

### ខ. ការប្រកាសផ្សាយ

**- គោលបំណង**

ការបិទប្រកាសនេះ មានគោលដៅបង្កលទ្ធភាពដល់ជនដែលមានប្រយោជន៍នៅក្នុងរឿងនេះដឹងឮ ហើយអាចប្តឹងទាស់នឹងអាពាហ៍ពិពាហ៍នោះបាន ប្រសិនបើមានការមិនយល់ព្រម ឬក៏ការរៀបអាពាហ៍ពិពាហ៍នោះប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ហើយត្រូវបានច្បាប់ការពារសិទ្ធិ និងផលប្រយោជន៍ទាំងនោះ។

**- បែបបទប្រកាសផ្សាយ**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងធ្វើនោះផ្សាយជាសាធារណៈនៅលំនៅដ្ឋាន និងនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួននារីមួយច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅឋាន និងបិទនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួនបុរស ១ច្បាប់។

**-ប័ណ្ណប្រកាសត្រូវចុះ**

- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅឋាននៃអនាគតប្តី ប្រពន្ធ។
- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅឋានរបស់ឪពុក ម្តាយ នៃអនាគតប្តីប្រពន្ធ បើឪពុកម្តាយ ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់។
- ត្រូវដាក់រយៈពេលកំណត់ដែលអាចប្តឹងទាស់បាននឹងអាពាហ៍ពិពាហ៍នោះ(គឺរយៈពេល ១០ថ្ងៃ គិតចាប់ពីថ្ងៃបិទប័ណ្ណប្រកាសផ្សាយជាសាធារណៈ)។

**- រយៈពេលប្រកាសផ្សាយ**

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានក្រោយរយៈពេលបិទផ្សាយនេះមានន័យថា បើក្នុងរយៈពេល ១០ថ្ងៃនេះគ្មាននរណាប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍របស់ពួកគេទេ នោះពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន[១៨]។

បើមានបណ្តឹងទាស់ ការរៀបអាពាហ៍ពិពាហ៍នោះមិនអាចប្រព្រឹត្តទៅបានទេ ប្រសិនបើបណ្តឹងទាស់នោះមិនត្រូវដោះស្រាយចប់។

### ២. លក្ខខណ្ឌក្នុងពេលរៀបអាពាហ៍ពិពាហ៍

### ក. វត្តមានគូស្រករ

---

[១៨]មាត្រា ១៣ ក្រមរដ្ឋប្បវេណី ២០០៧

ជាគោលការណ៍ គូស្រករទាំងពីរត្រូវតែមានវត្តមាននៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ។ អាពាហ៍ពិពាហ៍មិនអាចធ្វើទៅបានឡើយ ប្រសិនបើអវត្តមានភាគីបុរស ឬនារី។

**ខ. ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារី។

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ២នាក់ផងដែរ។

**គ. សមត្ថកិច្ចមន្ត្រីអត្រានុកូលដ្ឋាន**

ពេលសាមីខ្លួនជាអនាគតប្តី និងប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី និងប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន។

**កថាខណ្ឌទី៣.លក្ខខណ្ឌមិនអាចរៀបអាពាហ៍ពិពាហ៍បាន**

**១.ភេទដូចគ្នា**

អនាគតប្តីប្រពន្ធ ចាំបាច់ត្រូវមានភេទផ្ទុយគ្នា ទើបច្បាប់ទទួលស្គាល់។ អាពាហ៍ពិពាហ៍រវាងមនុស្សភេទដូចគ្នា ច្បាប់មិនទទួលស្គាល់ឡើយ ដូច្នេះដើម្បីឱ្យអាពាហ៍ពិពាហ៍មួយស្របច្បាប់ សាមីជនត្រូវមានភេទផ្ទុយគ្នា[១៩]។

**២.អនីតិជន**

អាពាហ៍ពិពាហ៍នឹងចាត់ទុកថាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន គឺបុរសត្រូវមានអាយុចាប់ពី ២០ឆ្នាំឡើង និងនារីត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើង។

ក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់ ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បានប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល[២០]។

[១៩]មាត្រា ៦ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

[២០]មាត្រា ៥ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

ប្រសិនបើយើងក្រឡេកមកមើលក្រមរដ្ឋប្បវេណីថ្មី ២០០៧ នេះវិញ នោះយើងនឹងឃើញថាវាមានលក្ខណៈខុសគ្នាដោយ បុរស និងនារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ។ ប៉ុន្តែក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជានីតិជនដែលមានអាយុមិនតិចជាង១៦ឆ្នាំអាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ[២១]។

### ៣.ទ្វេពន្ធភាព

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ[២២]។ ដូច្នេះបុរស ឬស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍រួចហើយ ហើយអាពាហ៍ពិពាហ៍នោះនៅមានសុពលភាពពួកគេមិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីបានទៀតឡើយ។ ប៉ុន្តែក្នុងករណីដែលបុរស ឬស្ត្រីនោះបានលួចទៅរៀបអាពាហ៍ពិពាហ៍ថ្មី ស្របពេលដែលអាពាហ៍ពិពាហ៍ចាស់មិនទាន់បានរំលាយនោះពួកគេនឹងប្រឈមនឹងបទល្មើសនៃច្បាប់ស្តីពីឯកពន្ធភាព[២៣]។

ទាំងបុរសទាំងស្ត្រី មិនអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានទេ ប្រសិនបើចំណងអាពាហ៍ពិពាហ៍មុនមិនទាន់រំលាយ[២៤] ចំពោះបុគ្គលដែលមានចំណងអាពាហ៍ពិពាហ៍រួចហើយ ហើយមករៀបការថ្មីទៀតនោះអាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ[២៥]។

បុរស ឬស្ត្រីអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបាន ក្រោយពីអាពាហ៍ពិពាហ៍រំលាយដោយមូលហេតុ៖

- មរណភាពរបស់សហព័ទ្ធណាមួយ
- មោឃភាពនៃអាពាហ៍ពិពាហ៍
- មានសាលក្រមនៃការលែងលះ

---

[២១]មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី ២០០៧។

[២២]មាត្រា ៩៤៩ ក្រមរដ្ឋប្បវេណី ២០០៧

[២៣]មាត្រា ៩ ច្បាប់ស្តីពីឯកពន្ធភាព ២០០៦

[២៤]មាត្រា៦ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

[២៥]មាត្រា ២៤ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ

- មានសាលក្រមប្រកាសពីការបាត់ខ្លួន (១៥ថ្ងៃ គិតពីថ្ងៃប្រកាសសាលក្រមដែលបញ្ជាក់ថាជននោះបានបាត់ខ្លួនពិតមែន)។

## ៤. ការគោរពថិរវេលាព ឬអំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី

នៅពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរលាយដោយមូលហេតុមរណភាព ការលែងលះ ឬដោយមោឃភាពនៃអាពាហ៍ពិពាហ៍នោះ បុរសអាចរៀបការទៀតនៅពេលណាក៏បាន។ នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល។ ប៉ុន្តែករណីនេះមិនអាចអនុវត្តបានឡើយប្រសិនបើនារីនោះមានផ្ទៃពោះនៅមុនពេលដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬលុបចោល ហើយបានសម្រាលកូន ឬមានការបញ្ជាក់ពីការគ្មានផ្ទៃពោះពីវេជ្ជបណ្ឌិត[២៦]។

ច្បាប់តម្រូវឱ្យនារីរង់ចាំ ១២០ថ្ងៃ ដើម្បីរៀបអាពាហ៍ពិពាហ៍ថ្មី គឺដើម្បីកំណត់បិតុភាពនៃកូនដែលកើតក្នុងឆ្នាំបន្ទាប់ពីការបញ្ចប់អាពាហ៍ពិពាហ៍លើកមុន ។ ប្រសិនបើ ស្ត្រីនោះឆាប់រៀបអាពាហ៍ពិពាហ៍ពេក ហើយកូនដែលកើតមកក្រោយពេលរៀបអាពាហ៍ពិពាហ៍ថ្មីនោះ ធ្វើឱ្យកើតមានបញ្ហាស្តីពីការកំណត់បិតុភាពរបស់កូននោះថា កូនរបស់ប្តីមុន ឬជាកូនរបស់ប្តីក្រោយ។

## ៥. អាពាហ៍ពិពាហ៍រវាងញាតិលោហិតឬញាតិពន្ធ

**-អាពាហ៍ពិពាហ៍រវាងញាតិលោហិត**

នៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ត្រង់មាត្រា ៩៥១ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតបានចែងថា "អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ ផងដែរ។ បញ្ញត្តិនេះក៏ត្រូវបានអនុវត្តផងដែរ នៅក្រោយពេលដែលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ ដោយបញ្ញត្តិនៃមាត្រា ១០១៤ (ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត) មាត្រា ១០១៦ (ការកាត់កាល់នៃស្មុំកូនពេញលេញ) ឬមាត្រា ១០៣២ (អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា)។

ញាតិលោហិត(ញាតិដែលមានឈាមជ័រជាមួយ)៖ ឪពុក និងកូន ឬម្តាយ និងកូន។

សាខាញាតិ(ញាតិដែលបែកចេញជាមែកធាងពីអ្នកបង្កើតរួម)៖ មីង មា និងក្មួយ បងប្អូនបង្កើត បងប្អូនជីដូនមួយ។

**-អាពាហ៍ពិពាហ៍រវាងញាតិពន្ធ**

---

[២៦]មាត្រា ៩៥០ ក្រមរដ្ឋប្បវេណី ២០០៧

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ផង[២៧]។ បុរស និងស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅថ្នាក់ណាក៏ដោយ។ ទោះបីជាញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ច្បាប់មិនអនុញ្ញាតឱ្យញាតិពន្ធខ្សែផ្ទាល់នោះ អាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានដែរ។

ក្នុងករណីពិសេស ប្រសិនបើសហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬទី ៣បាន។ ចំណុចនេះ ច្បាប់បានចែងដើម្បីបន្ថយលក្ខណៈងាយស្រួលដល់សហព័ទ្ធ និងការពារដល់កុមារជាកូនចៅសហព័ទ្ធ ព្រោះបុគ្គលសាខាញាតិដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយនេះ ធ្លាប់មានមនោសញ្ចេតនាស្រឡាញ់រាប់អានដល់កូនរបស់សហព័ទ្ធដែលមានរួចមកហើយ ដូច្នេះការអប់រំ ការចិញ្ចឹមបីបាច់ថែរក្សារបស់សហព័ទ្ធថ្មីនឹងបានល្អ[២៨]។

### ៦. អសមត្ថភាពផ្លូវកាយ និងស្មារតី

-ច្បាប់ហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍៖

-បុគ្គលមានភេទដូចគ្នា

-បុគ្គលមានពលានុភាពនៃលិង្គ

-បុគ្គលមានជំងឺរបេង ឃ្លង់ មហារីក កាមរោគ ដែលមិនទាន់បានព្យាបាលជាសះស្បើយ

-ជនវិកលចរិកមិនដឹងខុសត្រូវ។

## កថាខណ្ឌទី៤៖ បណ្ដឹងទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍

អាពាហ៍ពិពាហ៍ដែលប្រព្រឹត្តទៅផ្ទុយពីលក្ខខណ្ឌដែលត្រូវមានដើម្បីរៀបអាពាហ៍ពិពាហ៍ គឺជាអាពាហ៍ពិពាហ៍ពុំស្របច្បាប់ លើកលែងតែក្នុងករណីពិសេសខ្លះ ដែលច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានកំណត់នៅក្នុងមាត្រា ៥ និងមាត្រា ៨។

### ១. សញ្ញាណនៃបណ្ដឹងទាស់

[២៧]មាត្រា ៩៥២ ក្រមរដ្ឋប្បវេណី ២០០៧

[២៨]មាត្រា ៨ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

បណ្ដឹងទាស់ ជាបណ្ដឹងដែលឪពុកម្ដាយ ឬជនគ្រប់រូបដែលមានប្រយោជន៍ក្នុងរឿងនោះ ដើម្បីធ្វើឱ្យមន្ត្រីអត្រានុកូលដ្ឋានដឹងថា ខ្លួននឹងប្ដឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍បានដោយមានមូលហេតុណាមួយដែលច្បាប់ហាមឃាត់។

**២. អ្នកមានសិទ្ធិប្ដឹងជំទាស់**

**ក. ជនដែលមានប្រយោជន៍**

ជនដែលមានប្រយោជន៍ក្នុងរឿងក្ដីនេះអាចជា៖

- សាមីខ្លួនផ្ទាល់
- បងប្អូនបង្កើត
- ញាតិលោហិត
- សាខាញាតិ
- ជនដែលមានប្រយោជន៍ផ្សេងៗទៀត

សាច់ញាតិរបស់ភាគី ឬជនដែលមានប្រយោជន៍ណាមួយ អាចប្ដឹងជំទាស់អាពាហ៍ពិពាហ៍ក្នុងចន្លោះ ១០ថ្ងៃចាប់តាំងពីការបិទប្រកាសអំពីអាពាហ៍ពិពាហ៍ដែលគ្រោងនឹងរៀបនេះ។ អ្នកប្ដឹងទាស់ត្រូវចុះហត្ថលេខាលើពាក្យរបស់ខ្លួនផ្ទាល់ និងចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីចំណុចដែលខ្លួនប្ដឹងជំទាស់ ហើយបញ្ជូនទៅមេឃុំ ឬចៅសង្កាត់ខាងលំនៅនៃអនាគតប្រពន្ធ។

**ខ. មន្ត្រីអត្រានុកូលដ្ឋាន**

ក្នុងករណីពិសេស មន្ត្រីអត្រានុកូលដ្ឋានអាចប្ដឹងជំទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍នៅពេលដែលដឹងថាបុរស ឬនារីជាអសមត្ថជន ឬមានប្រការណាមួយដែលច្បាប់ហាមឃាត់ដូចជា៖

- អាយុមិនគ្រប់តាមច្បាប់កំណត់
- អសមត្ថភាពខាងផ្លូវកាយ និងស្មារតី។

**៣. ទម្រង់នៃបណ្ដឹងទាស់**

បណ្ដឹងទាស់នឹងយកជាការបាន លុះត្រាតែអ្នកប្ដឹងទាស់ចុះហត្ថលេខាលើពាក្យបណ្ដឹងរបស់ខ្លួន ដោយផ្ទាល់ ហើយចង្អុលបង្ហាញឱ្យបានច្បាស់លាស់អំពីចំណុចដែលខ្លួនប្ដឹងទាស់ រួចហើយបញ្ជូនទៅមេឃុំ ឬចៅសង្កាត់ខាងលំនៅឋាននៃអនាគតប្រពន្ធ។

**៤. មូលហេតុនៃបណ្ដឹងទាស់**

មូលហេតុដែលអាចយកមកប្ដឹងទាស់បានគឺ វាមានប្រការណាមួយដែលច្បាប់ហាមឃាត់ចំពោះអនាគតប្ដីប្រពន្ធដូចជា៖

- អនាគតប្ដីប្រពន្ធមានអាយុក្រោមការកំណត់របស់ច្បាប់។

- អនាគតប្តីប្រពន្ធមានភេទដូចគ្នា ពលានុភាពនៃលិង្គ ជំងឺឃ្លង់ របេង មហារីក កាមរោគ ដែលមិនទាន់ព្យាបាលបានជាដាច់ខាត ជនវិកលចរិត ជនមិនដឹងខុសត្រូវ។
- អនាគតប្តីប្រពន្ធជាប់ចំណងញាតិលោហិត ឬញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់។
- អនាគតប្តីប្រពន្ធជាសាខាញាតិរហូតដល់ថ្នាក់ទី ៣រាប់ទាំងថ្នាក់ទី ៣ផង។

### ៥. រយៈពេលនៃបណ្តឹងទាស់

នៅមុនពេលអនាគតប្តី ប្រពន្ធរៀបអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់បុរស និងនារីត្រូវបិទប័ណ្ណប្រកាសផ្សាយក្នុងរយៈពេលពេល ១០ថ្ងៃ មុនថ្ងៃរៀបអាពាហ៍ពិពាហ៍។ នៅក្នុងរយៈពេល ១០ថ្ងៃ គិតចាប់ពីថ្ងៃបិទប័ណ្ណប្រកាសផ្សាយនេះ ញាតិក្តី ជនដែលមានប្រយោជន៍ក្នុងរឿងនេះក្តី អាចប្តឹងទាស់មិនឱ្យរៀបអាពាហ៍ពិពាហ៍បាន បើឃើញថា ការរៀបអាពាហ៍ពិពាហ៍នោះមានប្រការណាមួយដែលច្បាប់បានហាមឃាត់។

### ៦. ការសម្រេចលើបណ្តឹងទាស់

ក្រោយពេលទទួលបានបណ្តឹងទាស់ មេឃុំ ឬចៅសង្កាត់នេះត្រូវសម្រេចក្នុងរយៈពេល ០៣ថ្ងៃ គិតចាប់ពីថ្ងៃទទួលបណ្តឹងទាស់។

បើអ្នកប្តឹងជំទាស់ ឬអនាគតប្តី ប្រពន្ធ មិនសុខចិត្ត នឹងសេចក្តីសម្រេចនេះ មេឃុំ ឬចៅសង្កាត់ត្រូវបញ្ជូលសំណុំរឿងទៅតុលាការក្នុងរយៈពេល ៥ថ្ងៃយ៉ាងយូរ គិតពីថ្ងៃទទួលសំណុំរឿង។

តុលាការត្រូវសម្រេចសេចក្តីពីបណ្តឹងទាស់ក្នុងរយៈពេល ៧ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលសំណុំរឿង។ បើតុលាការបដិសេធបណ្តឹងទាស់ចោល អនាគតប្តី ប្រពន្ធអាចរៀបអាពាហ៍ពិពាហ៍បាន។ បើតុលាការចាត់ទុកបណ្តឹងទាស់នោះថាត្រឹមត្រូវ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ឈប់មិនឱ្យរៀបអាពាហ៍ពិពាហ៍។

### ៧. បណ្តឹងតវ៉ា

ប្រសិនបើប្រធានឃុំ សង្កាត់ ដែលសម្រេចលើបណ្តឹងទាស់ បានចេញសេចក្តីសម្រេចទាន់ពេលវេលា ហើយដើមបណ្តឹង ឬអនាគតប្តីប្រពន្ធមិនយល់ស្របទៅនឹងសេចក្តីសម្រេចរបស់មន្ត្រីឃុំ សង្កាត់ដែលបានធ្វើសេចក្តីសម្រេចបណ្តឹងទាស់ មន្ត្រីឃុំ សង្កាត់នោះត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។ ពេលនោះតុលាការត្រូវពិនិត្យសំណុំរឿងឡើងវិញ ហើយចេញសេចក្តីសម្រេចក្នុងរយៈពេល ៧ថ្ងៃ គឺគិតពីថ្ងៃបានទទួលសំណុំរឿង។ បើសិនជាបណ្តឹងទាស់ត្រូវបានគាំទ្រ មន្ត្រីអត្រានុកូលដ្ឋាន ពុំអាចអនុញ្ញាតឱ្យធ្វើពិធីរៀបអាពាហ៍ពិពាហ៍បានឡើយ ។ តាមមាត្រា១៩ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ បើសិនជាបណ្តឹងទាស់ត្រូវបានបដិសេធចោលពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តឡើងដោយស្របច្បាប់បាន។

សេចក្ដីសម្រេចរបស់តុលាការមិនអាចប្ដឹងតវ៉ាបានឡើយ។ វាហាក់ដូចជាមិនមានសិទ្ធិប្ដឹងឧទ្ធរណ៍ ឡើយហើយគ្មានយន្តការណាមួយបើកសវនាការឡើងវិញទេ ទោះបីជាមានការខុសឆ្គងធ្ងន់ធ្ងរក៏ដោយ។ ច្បាប់មិនបានចែងអំពីគោលការណ៍ណែនាំណាមួយស្ដីអំពីរបៀបលើកយកអង្គហេតុទៅបង្ហាញនៅតុលាការ និងខ្នាតគំរូនៃភស្តុតាងដែលតុលាការនឹងប្រើក្នុងការសម្រេចថា តើត្រូវអនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ប្រព្រឹត្តទៅបានឬទេ។

**កថាខណ្ឌទី៥ ៖ អានុភាពនៃអាពាហ៍ពិពាហ៍**

នៅពេលរៀបអាពាហ៍ពិពាហ៍ប្ដី ប្រពន្ធអាចប្រើនាមត្រកូលប្ដី ឬប្រពន្ធ ឬអាចប្រើនាមត្រកូលដើមរៀងៗខ្លួនដែលមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍បាន។

ប្ដីប្រពន្ធត្រូវរួមរស់ជីវភាពជាមួយគ្នា ហើយត្រូវសហការ សង្គ្រោះគ្នាទៅវិញទៅមក។ មិនតែប៉ុណ្ណោះ ប្ដី ប្រពន្ធមានសេរីភាពក្នុងការជ្រើសរើសវិជ្ជាជីវៈ ហើយអាចចូលរួមក្នុងសកម្មភាពនយោបាយ វប្បធម៌ សង្គម រៀងៗខ្លួនបាន។

ម្យ៉ាងវិញទៀត ប្រសិនបើអនីតិជនបានរៀបអាពាហ៍ពិពាហ៍ អនីតិជននោះត្រូវបានចាត់ទុកថាបានដល់នីតិភាពដោយអាពាហ៍ពិពាហ៍[២៥]។

## ផ្នែកទី៣៖ អាពាហ៍ពិពាហ៍នៅបរទេស និងអាពាហ៍ពិពាហ៍ជាមួយជនបរទេស

**កថាខណ្ឌទី១៖ ការរៀបអាពាហ៍ពិពាហ៍នៅបរទេស**

ការសុំរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ ឬរវាងពលរដ្ឋខ្មែរ និងជនបរទេសដែលរស់នៅស្របច្បាប់ឯបរទេស ត្រូវប្រព្រឹត្តទៅនៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាននៃស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសដែលគូភាគីមានទីលំនៅ។

ក្នុងករណីដែលអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងពលរដ្ឋខ្មែរ និងអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស បានប្រព្រឹត្តទៅត្រឹមត្រូវតាមទម្រង់នៃអាពាហ៍ពិពាហ៍ដែលមានចែងក្នុងច្បាប់នៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ត្រូវទទួលស្គាល់យកជាការបាននៅព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអាពាហ៍ពិពាហ៍នោះមិនផ្ទុយនឹងបទបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ សំបុត្រអាពាហ៍ពិពាហ៍ ឬសេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍នោះ ត្រូវយកមកចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍នៃស្ថានទូត ឬស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសនៃកន្លែងរៀបអាពាហ៍ពិពាហ៍នោះ ឬបើប្ដីប្រពន្ធមកតាំងលំនៅនៅព្រះរាជាណាចក្រកម្ពុជា

[២៥]មាត្រា ៩៦៨ ក្រមរដ្ឋប្បវេណី ២០០៧

ត្រូវយកមកចុះសៀវភៅអាពាហ៍ពិពាហ៍នៅសាលាឃុំ ឬសង្កាត់ដែលខ្លួនបានរស់នៅ។ ស្ថានទូត ស្ថានអគ្គកុងស៊ុល ឬស្ថានកុងស៊ុល ឬមន្ត្រីអត្រានុកូលដ្ឋាននៅព្រះរាជាណាចក្រកម្ពុជា ត្រូវយក សំបុត្រអាពាហ៍ពិពាហ៍ថតចម្លងផ្លូវការនោះទុក ហើយចម្លងចេញពីសៀវភៅនូវសំបុត្រអាពាហ៍ ពិពាហ៍ថ្មី ឱ្យទៅជននោះយកទៅប្រើប្រាស់[៣០]។

## កថាខណ្ឌទី២៖ ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជា

### ១. ពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍

#### ក. លក្ខខណ្ឌ

អាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឬជនអន្តោប្រវេសន៍ ដែលរស់នៅស្របច្បាប់ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវប្រព្រឹត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាន នៅព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍[៣១]។

#### ខ. ឯកសារ

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំ ឯកសារដូចខាងក្រោម៖

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- ឯកសារថតចម្លង នៃលិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេស មានទិដ្ឋាការចូលប្រទេស កម្ពុជាដែលនៅមានសុពលភាព
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់ខ្លួន (ជនបរទេស)
- លិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស
- លិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់ នៅចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស

[៣០] អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ២០០០ មាត្រា ៣២

[៣១] អនុក្រឹត្យលេខ ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ ២០០៨ មាត្រា ៥

ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ពីភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមានបញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា។

ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះក៏ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍ ដែលខ្លួនរស់នៅដោយមានភ្ជាប់នូវសំណុំឯកសារដូចខាងក្រោមៈ

- ពាក្យសុំរៀបអាពាហ៍ពិពាហ៍
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ
- លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់នៃលំនៅឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ។
- លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ស្របពេលជាមួយគ្នាទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន[៣២]។

## គ. ការពិនិត្យ និងការប្រកាសផ្សាយរបស់មន្ត្រីអត្រានុកូលដ្ឋាន

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានភារកិច្ចពិនិត្យ និងសម្រេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់។

បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារីបានត្រឹមត្រូវតាមគោលការណ៍ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំបណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួនប្រុស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានរបស់សាមីខ្លួនពលរដ្ឋខ្មែរ។

[៣២]អនុក្រឹត្យលេខ ១៨៣ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ ២០០៨ មាត្រា ៩

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល ១០ថ្ងៃ នៅស្ថានទូត ឬស្ថានតំណាងនៃប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅឋានអចិន្ត្រៃយ៍ និងនៅសាលាឃុំ សង្កាត់នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។ ផុតរយៈពេល ១០ថ្ងៃ ប្រសិនបើគ្មានការប្ដឹងតវ៉ា ឬប្ដឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះទើបសាមីខ្លួនបុរស និងនារីអាចរៀបអាពាហ៍ពិពាហ៍បាន។

**ឃ. ការចុះសំបុត្រអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារីចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋាននៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួនពីរនាក់ ស្របទៅតាមទម្រង់បែបបទ និងនីតវិធីនៃការងារអត្រានុកូលដ្ឋាន។

**២. ជនបរទេស និងជនបរទេស**

ជនអន្តោប្រវេសន៍ និងជនបរទេស ដែលរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អាចរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬជនអន្តោប្រវេសន៍នោះបានដោយអនុវត្តតាមច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ដែលមានចែងក្នុងប្រទេសរបស់ខ្លួន តែត្រូវសុំអនុញ្ញាតច្បាប់ពីមន្ត្រីអត្រានុកូលដ្ឋានដោយប្រាប់ពីទីកន្លែង និងពេលវេលា ដែលខ្លួនរៀបអាពាហ៍ពិពាហ៍នោះឱ្យបានច្បាស់។

# ជំពូកទី២

# បញ្ហាប្រឈម អាពាហ៍ពិពាហ៍នៅកម្ពុជាបច្ចុប្បន្ន

# ជំពូកទី ២

# បញ្ហាប្រឈមអាពាហ៍ពិពាហ៍នៅកម្ពុជាបច្ចុប្បន្ន

## ផ្នែកទី០១៖ បញ្ហាប្រឈមនៃអាពាហ៍ពិពាហ៍

នៅក្នុងសម័យបច្ចុប្បន្ននេះ ការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាមានការរីកចម្រើនច្រើនទាក់ទងនឹងវិស័យនៃការអនុវត្តតាមនីតិវិធីនៃច្បាប់ ក៏ប៉ុន្តែមានអាពាហ៍ពិពាហ៍មួយចំនួនផងដែរ ដែលកំពុងមានបញ្ហាប្រឈមដូចជា បញ្ហាភេទដូចគ្នា បញ្ហាអាយុភាគី បញ្ហាការបង្ខិតបង្ខំ បញ្ហាញាតិនិងញាតិ បញ្ហាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ បញ្ហាចូលសញ្ជាតិដោយអាពាហ៍ពិពាហ៍។

### កថាខណ្ឌទី១៖ បញ្ហាភេទដូចគ្នា

ចំពោះភេទគឺជាបញ្ហាប្រឈមមួយនៃអាពាហ៍ពិពាហក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ដោយសារតែមានបុគ្គលមួយចំនួនបានស្រឡាញ់ភេទដូចគ្នាគឺប្រុសស្រឡាញ់ប្រុស ស្រីស្រឡាញ់ស្រីហើយក៏រៀបអាពាហ៍ជាមួយគ្នាដែលជាហេតុនាំឲ្យមានបញ្ហាផ្សេងៗកើតឡើងដូច បញ្ហាផ្ទុយនឹងច្បាប់ ការចង់បង្កើតកូន ការរើសអើងផ្លូវភេទ ។

#### ១.បញ្ហាផ្ទុយនឹងច្បាប់

នៅក្នុងរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាមាត្រា ៤៥ ចែងថាបុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់[៣៣] ។ មានន័យថាចំពោះភេទរបស់ភាគីក្នុងការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវតែជាបុរសនិងស្ត្រី ហើយត្រូវធ្វើឡើងទៅតាមលក្ខខណ្ឌទម្រង់នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា មិនអាចធ្វើឡើងដោយខុសលក្ខខណ្ឌទម្រង់នៃច្បាប់ឡើយ។ ដោយយោងតាមច្បាប់ស្តីពីឯកពន្ធភាពមាត្រា ២ ក៏ចែងដែរថា ប្រជាពលរដ្ឋខ្មែរទាំងពីរដែលមានចំណងរៀបអាពាហ៍អាពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្មគ្រ័ចិត្តប្តីមួយប្រពន្ធមួយ[៣៤] ។ នៅក្នុងមាត្រានេះក៏បានបញ្ជាក់ដែរថា ចំពោះការរៀបអាពាហ៍ពិពាហ៍នោះ ត្រូវតែជាពលរដ្ឋខ្មែរទាំងពីរភេទភាគីទាំងពីរត្រូវមានភេទផ្ទុយគ្នាគឺប្រុសនិងស្រី មិនមែនជាការរៀបអាពាហ៍ ពិពាហ៍ជាមួយភេទដូចគ្នានោះឡើយ ។ ម្យ៉ាងទៀតនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ៩៤៨ ក៏បានចែងដែរថា បុរសនិងនារីដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។ នៅក្នុងន័យនេះក្រម

---

[៣៣] មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

[៣៤] មាត្រា ២ នៃច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ ២០០៦

រដ្ឋប្បវេណី បានកំណត់អំពីភេទរបស់ភាគីដែលត្រូវរៀបអាពាហ៍គឺត្រូវតែមានភេទផ្ទុយគ្នាជាបុរស និងនារី ។ នៅក្នុងមាត្រា ៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារបានចែងថា បុរសនិងនារីដែលមានអាយុពេញលក្ខណៈច្បាប់មានសិទ្ធិពេញលេញក្នុងការសម្រេចអាពាហ៍ពិពាហ៍ ។ នៅក្នុងច្បាប់នេះបានកំណត់និងតម្រូវឲ្យភាគីដែលត្រូវរៀបអាពាហ៍ជាមួយគ្នានោះត្រូវតែជាបុរសនិងនារី[៣៥] ។ ភាគីទាំងពីរមិនត្រូវមានភេទដូចគ្នាទេគឺត្រូវមានភេទផ្ទុយពីគ្នា។

ដោយយោងតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាខាងលើនេះ បង្ហាញឲ្យឃើញថាភាគីដែលត្រូវសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍បាននោះ គឺត្រូវជាបុរសនិងស្ត្រីទើបអាពាហ៍ពិពាហ៍នោះអាចស្របច្បាប់បាន ។ ប៉ុន្តែក្នុងករណីជាក់ស្តែងមានបុគ្គលមួយចំនួន នៅប្រទេសកម្ពុជាបច្ចុប្បន្នបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភេទដូចគ្នាដែលជាហេតុធ្វើឲ្យមានការផ្ទុយនឹងច្បាប់ ។ កត្តាទាំងនេះហើយ ដែលជាហេតុនាំឲ្យមានបញ្ហាប្រឈមកើតឡើងដូចជា បញ្ហាច្បាប់មិនទទួលស្គាល់ការចុះសំបុត្រអាពាហ៍ពិពាហ៍ មិនអាចមានកូនជាមួយគ្នាបាន ការសុំកូន មានបញ្ហាឆ្លងមេរោគ ជាដើម ។

បច្ចុប្បន្ននៅប្រទេសកម្ពុជាសព្វថ្ងៃនេះ មានការស្រឡាញ់ភេទដូចគ្នាច្រើន ដោយពួកគេ បានរួមរស់នៅជាមួយគ្នា ដោយបានរៀបអាពាហ៍ពិពាហ៍ខ្លះ និងអ្នកខ្លះទៀតមិនបានរៀបអាពាហ៍នោះឡើយដោយគិតឃើញថាពួកគេស្រឡាញ់ភេទដូចគ្នាមិនចាំបាច់រៀបអាពាហ៍ពិពាហ៍ក៏បាន ។

ចំពោះអាពាហ៍ពិពាហ៍ នៃការស្រឡាញ់ភេទដូចគ្នាទាំងអស់នេះ នៅពេលដែលមានបញ្ហាផ្សេងៗកើតឡើងដូចជាការបែងចែកទ្រព្យ ការសុំកូន ការលែងលះ ការចង់បានកូនជាដើម នោះច្បាប់មិនធ្វើការដោះស្រាយឲ្យទេពីព្រោះវាជាអាពាហ៍ពិពាហមិនស្របច្បាប់ ជាអនីតិសង្វាស នេះហើយជាបញ្ហាប្រឈមនៃអាពាហ៍ពិពាហ៍ស្រឡាញ់ភេទដូចគ្នា ។

មានរឿងជាក់ស្តែងមួយដែលបានកើតឡើងនៃការស្រឡាញ់ភេទដូចគ្នា ដោយបានរៀបអាពាហ៍ ពិពាហ៍នឹងគ្នានៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ សូមលើអំពីបញ្ហាស្រីស្រឡាញ់ស្រីដូចគ្នា នៅភូមិត្រពាំងឈ្នង់ សង្កាត់សំរោងក្រោម ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ភាគីដើរប្រុសឈ្មោះ វ៉ាត់ សុខន (ស្រីតែងខ្លួនធ្វើជាប្រុស) អាយុ ៣៥ មុខរបរកម្មកររោងចក្រ ។ មានឪពុកឈ្មោះ វង់ សម្បត្តិ អាយុ ៥៨ ឆ្នាំ មុខរបរកសិករ និងម្តាយឈ្មោះ សៀង ស្រួយ អាយុ ៥០ ឆ្នាំ មុខរបរកសិករ រស់នៅក្នុងភូមិស្រុកខាងលើ ចំណែកខាងភាគីខាងស្រីពិតប្រាកដ មានឈ្មោះ ឈាង វី អាយុ ២៥ មុខរបរកម្មកររោងចក្រ មានទីលំនៅ ភូមិស្តុក ឃុំស្វាយចចឹប ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ។ មានឪពុកឈ្មោះថា ម៉ែ

[៣៥] មាត្រា ៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ឆ្នាំ ១៩៨៩

ន ប៊ុក អាយុ ៥២ឆ្នាំមុខរបរកសិករ និងម្តាយឈ្មោះ សារ គង់ អាយុ ៥១ឆ្នាំ មុខរបរកសិករ ។ ភាគីខាងស្រីគាត់បាននិយាយថា គាត់ស្រឡាញ់ ឈ្មោះ វ៉ាត់ សុខន ដោយស្មគ្រចិត្ត ទោះបីជាគាត់មានភេទជាស្រីដូចគ្នាក៏ដោយហើយចង់រួមរស់បង្កើតជាគ្រួសារនៅជាមួយរហូត ។ ដោយយោងតាមមាត្រា៣៥ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ និងមាត្រា៩៤៨នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ព្រមទាំងមាត្រា៩នៃច្បាប់ស្តីពីអាពាហ៍ ពិពាហ៍ និងគ្រួសារ១៩៨៩ មាត្រា ៣,៤ នៃច្បាប់ស្តីពីឯកពន្ធភាព ចែងកំណត់ថាភេទរបស់ភាគីដែលត្រូវរៀបអាពាហ៍ពិពាហ៍ត្រូវមានភេទផ្ទុយគ្នា គឺបុរសនិងនារី ។ ចំពោះភាគីទាំងពីរនោះមិនត្រូវមានភេទដូចគ្នាឡើយ ។ ករណីបើភាគីទាំងពីររៀបអាពាហ៍ពិពាហ៍ជាមួយនឹងភេទដូចគ្នានោះ ឈ្មោះថាជាអនីតិសង្វាស ហើយច្បាប់មិនទទួលស្គាល់ឡើយ ។ នៅពេលដែលបញ្ហានៃការលែងលះទាស់ទែងគ្នានោះច្បាប់មិនធ្វើការដោះស្រាយឲ្យឡើយទាំងនេះហើយជាបញ្ហាប្រឈមនៃអាពាហ៍ពិពាហ៍ស្រឡាញ់ភេទដូចគ្នា ។

## ២.បញ្ហាការរើសអើង

ស្ថិតក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ បុគ្គលគ្រប់រូប រាប់ទាំងមនុស្សស្រីស្រឡាញ់ភេទដូចគ្នា មនុស្សប្រុស ស្រឡាញ់ភេទដូចគ្នា មនុស្សស្រឡាញ់ភេទពីរ និងមនុស្សប្តូរភេទ (ជាប្រភេទមនុស្សស្រឡាញ់ភេទដូចគ្នា) មានសិទ្ធិទទួលបានសិទ្ធិដូចបុគ្គលដទៃទៀតដែរ។ មាត្រា១ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអះអាងថាមនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ ហើយថាមនុស្សម្នាក់ៗមានសិទ្ធិសេរីភាពគ្រប់យ៉ាងដោយមិនប្រកាន់បែងចែកណាមួយ។ គោលការណ៍ទាំងនេះ ស្តីពីសកលភាព ភាពស្មើគ្នា និងការមិនរើសអើង ដែលមានចែងផងដែរ នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិនិងសន្ធិសញ្ញាសិទ្ធិមនុស្ស។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ បញ្ជាក់ជាថ្មីអំពីគោលការណ៍ទាំងនេះ ដោយការទទួលស្គាល់ និងការគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងសន្ធិសញ្ញាអន្តរជាតិ ដោយចែងថាប្រជាពលរដ្ឋខ្មែរគ្រប់រូបមាន "ភាពសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់" ដោយមិនគិតពីឋានៈសង្គមផ្សេងគ្នា ហើយ "**មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេសជាតិ**"[៣៦]។

បើទោះបីជាទំនាក់ទំនងផ្លូវភេទដូចគ្នា មិនត្រូវបានដាក់ជាទោសព្រហ្មទណ្ឌក្តី អ្នកស្រឡាញ់ភេទដូចគ្នាទាំងនោះ មិនត្រូវបានការពារ ឬទទួលស្គាល់ដោយច្បាប់កម្ពុជាដែរ។ ច្បាប់ដែលមានជាធរមានមិនបានហាមឃាត់ជាពិសេសលើការរើសអើង ដោយផ្អែកលើទំនោរផ្លូវភេទ និងអត្តសញ្ញា-

[៣៦] មាត្រា៣៥ នៃរដ្ឋធម្មនុញព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣

ណាយេនឌ័រ ហើយក៏មិនមានដែរនូវការដាក់ទណ្ឌកម្ម ចំពោះអ្នកដែលរំលោភសិទ្ធិមនុស្សរបស់មនុស្សស្រឡាញ់ភេទដូចគ្នា។ ដោយហេតុនេះហើយ ទើបជាញឹកញយ មនុស្សស្រឡាញ់ភេទដូចគ្នា ត្រូវប្រឈមនឹង "ស្លាកស្នាមទុយ៌ស ការរើសអើង និងការផាត់ចេញ កម្រិតខ្ពស់ នៅកន្លែងផ្សេងៗ ដូចជា នៅលំនៅឋាន សាលារៀន កន្លែងធ្វើការ មណ្ឌលសុខភាព និងនៅទីសាធារណៈ។" អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើន ជាពិសេសមនុស្សប្តូរភេទ ជាញឹកញយ មានអារម្មណ៍ថាខ្លួនឯកកោ និងងាយរងគ្រោះ គ្មានជំនាញ ឬគ្មានចំណេះដឹង ដើម្បីទ្រទ្រង់ខ្លួនឯងឡើយ។ កង្វះការទទួលស្គាល់ និងការការពារសិទ្ធិផ្លូវភេទក្រុមភាគតិចនេះ បង្កជាឧបសគ្គដល់បុគ្គលដែលស្រលាញ់ភេទដូចគ្នា ក្នុងការទទួលបានពេញលេញនូវសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងការអភិវឌ្ឍដែលមានការរួមបញ្ចូល នៃព្រះរាជាណាចក្រកម្ពុជា។

កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្ហាញការប្តេជ្ញាចិត្ត និងគំនិតផ្តួចផ្តើម ដើម្បីរួមបញ្ចូលមនុស្ស ស្រឡាញ់ភេទដូចគ្នា ក្នុងផែនការ និងកម្មវិធីផ្សេងៗ។ តាមការសិក្សាស្រាវជ្រាវអំពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ដែលបានធ្វើឡើង ដោយអង្គភាពសម្របសម្រួលគាំពារសង្គម នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទក្នុងឆ្នាំ២០១៣ ហើយផែនការយុទ្ធសាស្ត្រជាតិស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ព្រមទាំង ផែនការសកម្មភាពជាតិលើកទី២ បង្ការទប់ស្កាត់អំពើហិង្សាប្រឆាំងនឹងស្ត្រី ដោះស្រាយជាពិសេសនូវតម្រូវការរបស់មនុស្សដែលស្រឡាញ់ភេទដូចគ្នា ។ អតីតសម្តេចព្រះករុណាព្រះបាទនរោត្តមសីហនុ អ្នកនយោបាយមួយចំនួន និងមន្ត្រីរដ្ឋាភិបាលនៅថ្នាក់សអើងប្រឆាំងនឹងមនុស្សដែលស្រឡាញ់ភេទដូចគ្នា[៣៧]។

ម្យ៉ាងទៀតនៅក្នុងមាត្រា ៥ នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចែងថា រដ្ឋជាភាគីសន្យាហាមឃាត់ និងរាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងសន្យាធានាឲ្យមនុស្សម្នាក់ៗ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយគ្មានការប្រកាន់បែងចែកមានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិ ជាពិសេសក្នុងការអាស្រ័យផល គឺ សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងជ្រើសរើសគូស្រករ[៣៨] ។ ទោះបីជា អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចែងថា រដ្ឋជាភាគីសន្យាហាមឃាត់ និងរាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងសន្យាធានាឲ្យមនុស្សម្នាក់ៗ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយ

[៣៧] http://cambodia.ohchr.org/kh/issues/lgbt-rights-0

[៣៨] មាត្រា ៥ ចំនុច (ឃ) នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

គ្មានការប្រកាន់បែងចែកមាន ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិ ជាពិសេសក្នុងការអាស្រ័យផលគឺ សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងជ្រើសរើសគូស្រករបែបនេះក៏ដោយ ។ សម្រាប់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជាចំពោះភាគី ដែលសិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍បាននោះត្រូវភេទផ្ទុយគ្នាគឺបុរសនិងនារី មិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍នឹងភេទដូចគ្នាឡើយ ហើយទិដ្ឋភាពនៃការអនុវត្តជាក់ស្តែងចំពោះការរៀបអាពាហ៍ពិពាហ៍ នៃការស្រឡាញ់ភេទដូចគ្នា នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន តែងមានបញ្ហាប្រឈមមួយចំនួនដូចមានការរើសអើងភេទជាដើម ។ អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនបានប្រឈមមុខជាមួយនឹងការរំលោភបំពាន និងការរើសអើងនៅផ្ទះ សាលារៀន និងកន្លែងធ្វើការ។ មួយចំនួនទៀតត្រូវបានគ្រួសារបដិសេធ ឬរងសម្ពាធដោយសារការរៀបការតាមប្រពៃណី ដែលធ្វើឲ្យពួកគេពិបាកក្នុងអារម្មណ៍។ អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀតត្រូវបានចាប់បង្ខាំងទុកក្នុងផ្ទះ នៅតាមភូមិ របស់ពួកគេ។

### ក.អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាចេញបង្ហាញជាសាធារណៈ

សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា បានចេញមុខជាសាធារណៈប្រកបដោយមោទនភាពចំពោះខ្លួនឯងផ្ទាល់ ដែលការណ៍នេះមិនធ្លាប់មានពីមុនមកទេ ផ្ទុយស្រឡះពីកាលពីប្រាំឆ្នាំមុន នៅពេលដែលការរើសអើងនិងការធ្វើទុក្ខបុកម្នេញខាងផ្លូវកាយ និងផ្លូវចិត្តជារឿយៗត្រូវបានលាក់បាំង ក្រុមអ្នកស្រឡាញ់ភេទដូចគ្នាបានបង្កើតជាអង្គការក្រៅរដ្ឋាភិបាលនានា ហើយអាជីវកម្មរង្គសាល និងហាងកាហ្វេទាំងឡាយក្នុងក្រុង ដែលមិនរើសអើងអ្នកស្រឡាញ់ភេទដូចគ្នា ទទួលបានជោគជ័យស្របពេលដែលបណ្តាញផ្សព្វផ្សាយ និងវិស័យកម្សាន្តពាក់ព័ន្ធនឹងអ្នកស្រឡាញ់ភេទដូចគ្នាក៏កំពុងចាប់ផ្តើមរីកលូតលាស់ផងដែរ[៣៩]។

### ខ.របាំងប្រពៃណី

ដោយសារកម្ពុជាជាប្រទេសអភិរក្សនិយមមួយ ប្រជាជនកម្ពុជាពីដើមឡើយតែងយល់ឃើញថា ការស្រឡាញ់ភេទដូចគ្នាជាអ្វីមួយដែលខុសពីធម្មជាតិ និងជាការគំរាមកំហែងមួយទៅលើសណ្តាប់ធ្នាប់សង្គម បន្ទាប់ពីសង្គ្រាមរាំរ៉ៃប្រមាណ ៣០ឆ្នាំកន្លងមកនេះ ដែលបានបង្កការប៉ះពាល់យ៉ាងខ្លាំងទៅលើគ្រឹះសង្គម។ អ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនបានប្រឈមមុខជាមួយនឹងការរំលោភបំពាន និងការរើសអើងនៅផ្ទះ សាលារៀន និងកន្លែងធ្វើការ។ មួយចំនួនទៀតត្រូវបានគ្រួសារបដិសេធ ឬរងសម្ពាធដោយសារការរៀបការតាមប្រពៃណី ដែលធ្វើឲ្យពួកគេពិបាកក្នុងអារម្មណ៍។ អ្នកស្រឡាញ់ភេទដូចគ្នាដទៃទៀតត្រូវបានចាប់បង្ខាំងទុកក្នុងផ្ទះ នៅតាមភូមិ របស់ពួកគេ។

---

[៣៩] ទស្សនាវដ្តី Q CAMBODIA 24 មីនា 2017

លោកស្រ៊ុន ស្រ៊នបាននិយាយថា របាយការណ៍ពីការរំលោភបំពានសិទ្ធិមនុស្ស និងការរើសអើងមានតិចតួច ពីព្រោះអ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួនជ្រើសរក្សាទុកជម្រើសផ្លូវភេទរបស់ខ្លួនជាការសម្ងាត់ ជាជាងផ្តល់ដំណឹងទៅកាន់អាជ្ញាធរ។ ប៉ុន្តែលោកបាននិយាយថា ការណ៍នេះបានផ្លាស់ប្តូរ ដោយមនុស្សមួយចំនួន ដែលបើកចំហក្នុងនាមជាអ្នកស្រឡាញ់ភេទដូចគ្នា បានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ។ «ទាក់ទងទៅនឹងអំពើហិង្សា ទាំងផ្លូវកាយ និងផ្លូវចិត្តទៅកាន់ពួកគេ គឺមានការកើនឡើងដែរ។ ខ្ញុំឃើញថា ការហ៊ានចេញមុខបង្ហាញថា ខ្លួនឯង ជាមនុស្សស្រីចរិតប្រុស ឬប្រុសចរិតស្រីគឺមានការចេញមុខច្រើន តែអំពើហិង្សា និងសម្ពាធដែលឪពុកម្តាយដាក់មក ដូចជាការនាំទៅឲ្យគ្រូខ្មែរព្យាបាល គឺនៅតែកើតមាន»[៤០] ។

**កថាខណ្ឌទី២៖ បញ្ហាអាយុភាគី**

អាយុរបស់ភាគីគឺជាបញ្ហាប្រឈមមួយ នៃអាពាហ៍ពិពាហ៍នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ដោយសារតែមានបុគ្គលមួយចំនួនបានរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេងខ្ចីពេក ដែលជាហេតុនាំឲ្យមានការប្រឈមកើតឡើងដូចជា មានបញ្ហាសុខភាពម្តាយនិងកូនក្នុងផ្ទៃ សមត្ថភាពក្នុងការបង្ហាញឆន្ទៈ សតិបញ្ញាស្មារតីមានការយល់ដឹងតិចតួច ការសម្រេចចិត្តធ្វើអ្វីមួយមិនច្បាស់ អំពើហិង្សាក្នុងគ្រួសារ ការលែងលះ។ ហេតុនេះទើបច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍បានជានីតិជន ក្នុងវ័យអាយុ ១៨ឆ្នាំឡើងទៅ ក៏ប៉ុន្តែបើភាគីម្ខាងជាអនីតិជន មានអាយុ ១៦ ឆ្នាំ បើមានការយល់ដឹងខ្ពស់ឬមានសមត្ថភាពក្នុងឆន្ទៈបាន បុគ្គលដែលជាអនីតិជននោះ មានបំណងរៀបអាពាហ៍ពិពាហ៍ច្បាប់អនុញ្ញាតឲ្យអ្នកដែលអំណាចមេបា ឬអ្នកអាណាព្យាបាលយល់ព្រមគឺអាចរៀបអាពាហ៍ពិពាហ៍បាន ឬក៏ក្នុងករណីដែលឪពុកម្តាយឬ អំណាចមេបាឬ អ្នកអាព្យាបាលហាមឃាត់ដោយមានមូលហេតុមិនត្រឹមត្រូវ អនីតិជនអាចស្នើសុំទៅតុលាការ ដើម្បីរៀបអាពាហ៍ពិពាហ៍បាន [៤១]។

នៅក្នុងច្បាប់របស់ប្រទេសកម្ពុជា បានចែងកំណត់អំពីលក្ខខណ្ឌដែលត្រូវរៀបអាពាហ៍ពិពាហ៍ចំពោះបុរសនិងស្ត្រីដែលចង់រៀបអាពាហ៍ពិពាហ៍ ត្រូវតែមានអាយុពេញលេញតាមការកំណត់របស់ច្បាប់ ។ នៅក្នុងមាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ចែងថា បុរសនិងស្រីមានសិទ្ធិរៀប

[៤០] https://khmer.voanews.com/a/cambodian-lgbt-comes-out-of-the-shadows/3779177.html

[៤១] មាត្រា ៩៥៣ នៃក្រមរដ្ឋប្បវេណី

អាពាហ៍ពិពាហ៍បាន ត្រូវមានអាយុចាប់ពី ១៨ ឡើងទៅដូចគ្នា[៤២] ដោយមិនបែងចែករវាងបុរសនិងស្ត្រីឡើយ ដោយហេតុថាបុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់[៤៣] ។ ដោយសារមនុស្សក្នុងសម័យបច្ចុប្បន្នមានការយល់ដឹងច្រើន ទើបក្រមរដ្ឋប្បវេណីតម្រូវឲ្យបុរសនិងស្ត្រីមានចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅដូចគ្នា ចំពោះច្បាប់ចាស់វិញបានកំណត់ថាគឺបុរសត្រូវមានអាយុចាប់ពី ២០ឆ្នាំឡើង និងនារីត្រូវមានអាយុចាប់ពី ១៨ឆ្នាំឡើងទើបអាចរៀបអាពាហ៍ពិពាហ៍បាន ។ ប៉ុន្តែក្នុងករណីពិសេស បុរសដែលមានអាយុមិនទាន់ដល់ ២០ឆ្នាំ និងនារីដែលមានអាយុមិនទាន់ដល់ ១៨ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍ស្របច្បាប់បានប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល[៤៤]។ ការកំណត់អាយុក្នុងការរៀបអាពាហ៍ពិពាហ៍នេះដើម្បីឲ្យត្រឹមត្រូវតាមគោលការណ៍ច្បាប់ និងអនុលោមទៅតាមសតិស្មារតីនិងសមត្ថភាពការបង្ហាញឆន្ទៈរបស់ភាគី ទោះបីជាមានការកំណត់អាយុក្នុងការរៀបអាពាហ៍ពិពាហ៍បែបនេះក៏ដោយ ប៉ុន្តែមានបុគ្គលមួយចំនួនបានដំឡើងអាយុឲ្យគ្រប់១៨ឆ្នាំ ដើម្បីរៀបអាពាហ៍ពិពាហ៍ជាមួយភាគីទាំងដែលខ្លួនកំពុងតែមានវ័យនៅក្មេងខ្ចីពេក ដែលជាហេតុនាំឲ្យមានបញ្ហាប្រឈមកើតឡើងនៅក្នុងសង្គម ។

### ១.បញ្ហាសុខភាពម្តាយនិងកូន

សុខភាពជាគឺជាអាយុជីវិតរបស់មនុស្សមានសុខភាពល្អគឺស្មើនឹងមានអ្វីៗទាំងអស់ បើប្រសិនណា សុខភាពមិនល្អហើយទោះបីមានទ្រព្យសម្បត្តិច្រើនយ៉ាងណាក៏ដោយមិនប្រសើរថ្លៃថ្លាឡើយ ។ ហេតុនេះមនុស្សយើងគប្បីថែរក្សាសុខភាពនោះឲ្យល្អទើបជីវិតរបស់យើងមានសេចក្តីសុខចម្រើន។ បច្ចុប្បន្ននៅក្នុងសង្គមកម្ពុជា បញ្ហាសុខភាពក៏តែងកើតមានផងដែរចំពោះបុគ្គលមួយចំនួនដែលបានរៀបពាហ៍ពិពាហ៍នៅវ័យក្មេងពេក ដែលជាហេតុនាំឲ្យមានបញ្ហាប្រឈមកើតឡើងដូចជា **ម្តាយឈឺច្រើនកម្លាំងមិនសូវគ្រប់គ្រាន់ ការថែរក្សាទារកក្នុងផ្ទៃពុំសូវដឹតដល់ គភ៌ដែលនៅក្នុងផ្ទៃនោះមិនគ្រប់ខែ លំបាក់ក្នុងការប្រសូតិកូនប្រឈមនឹងការវះកាត់ បញ្ហារលូតកូនច្រើន** ជាដើម ទាំងនេះហើយជាមូលហេតុនាំឲ្យមានបញ្ហាប្រឈមនៃអាយុមិនទាន់គ្រប់ ដើម្បីរៀបអាពាហ៍ពិពាហ៍ ដោយសារនៅវ័យក្មេងពេក ។

---

[៤២]មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណី

[៤៣]មាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

[៤៤]មាត្រា ៥ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

## ២.សមត្ថភាពក្នុងការបង្ហាញឆន្ទៈ

សមត្ថភាពក្នុងការបង្ហាញឆន្ទៈ គឺជាលក្ខណៈសម្បត្តិ ដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាមផ្លូវច្បាប់ នៃសកម្មភាពរបស់ខ្លួន(សមត្ថភាពខាងឆន្ទៈ)[៤៥]។ នៅក្នុងមាត្រា ១៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថាជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅលើអនីតិជន[៤៦] ជននៅក្រោមអាណាព្យាបាលទូទៅ[៤៧] និងជននៅក្រោមហិតូបត្ថម្ភ[៤៨] ។ ម្យ៉ាងវិញទៀតនៅក្នុងមាត្រា ១៨ នៃក្រមរដ្ឋប្បវេណីដដែលបានចែងថា សកម្មភាពដែលដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែចំពោះសកម្មភាពដែលទទួលសិទ្ធិដូចជាប្រទានកម្ម ការទទួលទ្រព្យសម្បត្តិ ឬឲ្យរួចផុតពីកាតព្វកិច្ចដូចជាការលើកលែងបំណុលគឺការជំពាក់បំណុល ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដូចជាអាហារកិច្ចការទិញចំណីសម្រាប់បរិភោគជាដើម សកម្មភាពទាំងនេះមិនអាចលុបចោលបានឡើយ[៤៩] ។ ម្យ៉ាងវិញទៀតនៅក្នុងរឿងអាពាហ៍ពិពាហ៍នេះ ក៏ក្រមរដ្ឋប្បវេណីបានចែងកំណត់អំពីសមត្ថភាពក្នុងការបង្ហាញឆន្ទៈផងដែរថា ក្នុងករណីដែលអនីតិជន បានទទួលបានអគ្គាធីនភាព អនីតិជនដែលទទួលបានអគ្គាធីនភាពនោះ ត្រូវបានចាត់ទុកជានីតិជន[៥០]។ ដូច្នេះអនីតិជនដែលទទួលបានអគ្គាធីនភាពនេះមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ ដោយមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលទេ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍នោះកើតឡើងរវាងអនីតិជនទទួលបានអគ្គាធីនភាព និងអនីតិជន ការរៀបអាពាហ៍ពិពាហ៍នោះត្រូវមានការយល់ព្រមពីឪពុកម្តាយ ។ ប៉ុន្តែប្រសិនបើអាពាហ៍ពិពាហ៍នោះកើតឡើងរវាងអនីតិជនដែលទទួលបានអគ្គាធីនភាពទាំងសងខាង ឬទាំងពីរ ពួកគេអាចរៀបអាពាហ៍ពិពាហ៍បានទោះបីជាមានការប្រឆាំងពីឪពុកម្តាយក៏

[៤៥] សទ្ទានុផ្នែកក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[៤៦] អនីតិជន សំដៅលើជនដែលមានអាយុក្រោម ១៨ ឆ្នាំ

[៤៧] សំដៅលើជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។

[៤៨] សំដៅលើជនដែលមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។

[៤៩] មាត្រា ១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[៥០] មាត្រា ៩៥ ក្រមរដ្ឋប្បវេណី ២០០៧

ដោយ ។ ក្នុងករណីដែលអាពាហ៍ពិពាហ៍ធ្វើឡើងរវាងអនីតិជនដែលមានអាយុមិនតិចជាង ១៦ឆ្នាំជាមួយនីតិជន ការរៀបអាពាហ៍ពិពាហ៍នេះត្រូវមានការយល់ព្រមពីឪពុកម្ដាយ ឬអាណាព្យាបាលទូទៅសម្រាប់អនីតិជនរបស់អនីតិជននោះ[៥១] ។ ក្នុងករណីនេះផងដែរ ប្រសិនបើអ្នកមានអំណាចមេបាណាម្នាងមិនយល់ព្រមទេនោះ ដោយគ្រាន់តែមានការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបាម្នាងជាការគ្រប់គ្រាន់[៥២]។ ប៉ុន្តែក្នុងករណីនេះអាចធ្វើទៅបានលុះត្រាតែគូស្រករទាំងពីរពិតជាមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាពិតមែន។ **ចំពោះជននៅក្រោមអាណាព្យាបាលទូទៅ** អាចរៀបអាពាហ៍ពិពាហ៍បានក្នុងករណីដែលមានសមត្ថភាពបង្ហាញឆន្ទៈ នៅក្នុងកម្រិតអប្ប-បរមាដែលចាំបាច់ដើម្បីរៀបអាពាហ៍ពិពាហ៍។ ក្នុងករណីនេះមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ[៥៣]។ មានន័យសេចក្ដីថា ជនវិកលចរិតនេះអាចសម្រេចចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯងបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅឡើយ។ ទោះបីជាមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈអាចសម្រេចចិត្តក្នុងការរៀបអាពាហ៍ ពិពាហ៍បានក៏ពិតមែន ប៉ុន្តែវានឹងមានបញ្ហាប្រឈមមួយចំនួនដូចជា ការយល់ដឹងនៅមានកម្រិត អាចមានការឆបោកពីសំណាក់ភាគីម្ខាងទៀត ការរស់នៅប្រកបរបរចិញ្ចឹមជីវិតក្នុងការរកប្រាក់កម្រៃតែងមានការលំបាក ព្រោះការគិតនិងការវិនិច្ឆ័យមិនគ្រប់គ្រាន់ ព្រមទាំងមានវិបត្តិផ្នែកបញ្ញាស្មារតី ។ បញ្ហាប្រឈមម្យ៉ាងទៀតគឺទាក់ទងទៅនឹងសកម្មភាពក្នុងការបង្ហាញឆន្ទៈដោយខ្លួនឯង ក្នុងសកម្មភាពផ្សេងៗក្រៅពីសកម្មភាពដែលទទួលសិទ្ធិ ឬការរួចផុតពីកាតព្វកិច្ច ឬសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។ គ្រប់សកម្មភាពទាំងឡាយណាដែលអនីតិជនធ្វើឡើងដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនទេ សកម្មភាពទាំងនោះអាចលុបចោលបាន[៥៤]។

### ៣.អំពើហិង្សាក្នុងគ្រួសារ

[៥១]មាត្រា ៩៤៨ ក្រមរដ្ឋប្បវេណី ២០០៧

[៥២]មាត្រា ៩៤៣ ក្រមរដ្ឋប្បវេណី ២០០៧

[៥៣]មាត្រា ៩៥៤ ក្រមរដ្ឋប្បវេណី ២០០៧

[៥៤]មាត្រា ១៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

អំពើហិង្សាក្នុងគ្រួសារ គឺសំដៅលើអំពើហិង្សាដែលកើតមាន និងអាចកើតមានទៅលើ ប្ដី ឬប្រពន្ធ កូនក្នុងបន្ទុក ជនទាំងឡាយរស់នៅក្រោមដំបូលផ្ទះ និងក្នុងបន្ទុកគ្រួសារ[៥៥] ។ ចំពោះសេចក្ដីសុខសុភមង្គលនៅក្នុងគ្រួសារមួយដែលអាចកើតឡើងបាន ដោយអាស្រ័យលើការចេះយល់ចិត្តគ្នាទៅវិញទៅមក រវាងប្ដីនិងប្រពន្ធ មានន័យថាប្ដីនិងប្រពន្ធនោះត្រូវមានភាពអត់ធន់ខន្តី សច្ចៈការទៀងត្រង់ចំពោះគ្នានឹងគ្នា វិរិយៈសេចក្ដីព្យាយាមប្រកបមុខរបរចិញ្ចឹមជីវិតដោយសុចរិត មេត្តាការស្រឡាញ់រាប់អានគ្នាដោយមាន សង្គហធម៌គឺការសង្គ្រោះចំពោះគ្នាទៅវិញទៅមក ទោះបីជាបងប្អូនសាច់ញាតិលោហិតទាំងអស់ស្រឡាញ់ស្មើៗគ្នាសំខាន់បំផុតនោះគឺមានសុជីវធម៌ សីលធម៌ និងគុណធម៌ក្នុងការរស់នៅ។ សម្រាប់អាពាហ៍ពិពាហ៍មួយចំនួននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន អំពើហិង្សាតែងកើតមានជារឿយៗ ដោយសារបញ្ហានៃការយល់ដឹងផង បញ្ហានៃអាយុក្នុងការរៀបអាពាហ៍ពិពាហ៍ដោយប្ដីប្រពន្ធខ្លះខ្វះការអត់ធន់ខន្តីចំពោះគ្នានឹងគ្នាផង ការរស់នៅខ្វះសុជីវធម៌និងក្រមសីលធម៌ជាដើម ដែលជាហេតុនាំឲ្យមានអំពើហិង្សាក្នុងគ្រួសារ ។

អំពើហិង្សារួមមាន ការប៉ះពាល់ដល់ជីវិត ការប៉ះពាល់ដល់បូរណភាពរូបកាយ ការធ្វើទារុណកម្ម ឬការធ្វើអំពើឃោរឃៅ ខាងឈ្លានពានខាងផ្លូវភេទ[៥៦] ។ ការប៉ះពាល់ដល់ជីវិតរួមមាន មនុស្សឃាតដោយគិតទុកជាមុន មនុស្សឃាតដោយអចេតនា មនុស្សឃាតដោយអចេតនាបណ្ដាលមកពីអំពើចេតនាផ្សេងទៀតនៃជនល្មើស[៥៧]។ អំពើប៉ះពាល់ដល់បូរណភាពរូបកាយ ការបំពារបំពានលើរូបកាយដោយប្រើអាវុធ ឬឥតអាវុធមានរបួស ឬគ្មានរបួស ការធ្វើទារុណកម្ម ឬធ្វើអំពើឃោឃៅ[៥៨]។ អំពើធ្វើទារុណកម្ម ឬអំពើឃោរឃៅរួមមាន ការធ្វើទុក្ខបុកម្នេញបង្កឲ្យមានឈឺចុកចាប់ផ្លូវចិត្ត សតិអារម្មណ៍បញ្ញាស្មារតីដល់រូបវន្តបុគ្គលក្នុងគ្រួសារ ការធ្វើឲ្យប៉ះទង្គិចលើផ្លូវចិត្តនិងលើរូបកាយដែលប្រព្រឹត្តទៅហួសពីសីលធម៌ និច្បាប់កំណត់[៥៩]។ ការឈ្លានពានខាងផ្លូវភេទរួម

[៥៥] មាត្រា ២ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

[៥៦] មាត្រា ៣ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

[៥៧] មាត្រា ៤ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

[៥៨] មាត្រា ៥ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

[៥៩] មាត្រា ៦ នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

មាន ការប្រើហិង្សាសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស និងការធ្វើអាស្រូវភាស[៦០]។ យ៉ាងណាមិញ ភាគីដែលបានរៀបអាពាហ៍ពិពាហ៍មានអាយុនៅក្មេងវ័យពេកថែមទាំងការយល់ដឹងយល់ក៏តិច គ្មានការអត់ធ្មត់តស៊ូខន្តី ទាំងនេះហើយជាហេតុនាំឲ្យមានបញ្ហាប្រឈមគឺ អំពើហិង្សាក្នុងគ្រួសារកើតឡើង ។

**៤.បញ្ហាការលែងលះ**

ការលែងលះ គឺជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងប្តីនិងប្រពន្ធហើយព្រមព្រៀងប្តេជ្ញាថាឈប់រស់នៅជាមួយគ្នាទៀត ។ ម្យ៉ាងទៀតជាការរំលាយចំណងអាពាហ៍ពិពាហ៍ដោយសាលក្រមរបស់តុលាការផ្តាច់ចំណង់អាពាហ៍ពិពាហ៍របស់សហព័ទ្ធ ។ អាយុរបស់ភាគីនៃការរៀបអាពាហ៍-ពិពាហ៍ ជាមូលហេតុនាំឲ្យមានបញ្ហាប្រឈមការលែងលះ កើតឡើងផងដែរ ដោយសារការរស់នៅរវាងប្តីនិងប្រពន្ធមិនមានភាពចុះសម្រុងគ្នា ការយល់ដឹងបានតិចនាំឲ្យមានអំពើហិង្សាកើតឡើង ការមើលងាយមើលថោកគ្នា គិតមិនបានវែងឆ្ងាយ ចិត្តឆែងឆាវច្រើន មិនចេះអត់ទ្រាំនឹងការងារចិញ្ចឹមជីវិត ឆាប់ជឿតាមគេ ប្រចណ្ឌច្រើនជាដើម។

**កថាខណ្ឌទី៣.បញ្ហាការបង្ខិតបង្ខំ**

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នអាពាហ៍ពិពាហ៍មួយចំនួន តែងកើតឡើងដោយសារការមិនស្ម័គ្រចិត្តឬមិនមានឆន្ទៈក្នុងការរៀបអាពាហ៍ពិពាហ៍របស់ភាគីឡើយ ពីព្រោះដោយមានការបង្ខិតបង្ខំពីសំណាក់ ឪពុកម្តាយឬអ្នកអាណាព្យាបាល ដោយពួកគេយល់ឃើញថាឪពុកម្តាយជាអ្នកគុណចិញ្ចឹមបីបាច់ថែរក្សាបង្កើតឲ្យមានអាយុជីវិតក្នុងការរស់នៅ ក៏ពួកគេរៀបអាពាហ៍ពិពាហ៍តាមការបង្គាប់បញ្ជារបស់ឪពុកម្តាយដើម្បីតម្រូវចិត្តនិងឲ្យម្តាយឪពុកមានការសប្បាយ តែឆន្ទៈគឺសេចក្តីពេញចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនមិនចង់ឡើយ ។ ទោះបីជាមានពិធីនៃការរៀបអាពាហ៍ពិពាហ៍រួចរាល់ហើយក៏ដោយប៉ុន្តែច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា មិនទទួលស្គាល់ថាជាអាពាហ៍ពិពាហ៍ស្របច្បាប់ឡើយ ព្រោះថាបុរសឬស្ត្រី ដែលបានសម្រេចចិត្តថានឹងរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានោះ ត្រូវគោរពទៅតាមលក្ខខណ្ឌទម្រង់របស់ច្បាប់ដែលមានចែងមានន័យថាគឺត្រូវឈរលើគាលការណ៍ស្មគ្រ័ចិត្ត ដោយគ្មានការបង្ខិតបង្ខំពីឪពុកម្តាយឬអ្នកអាណាព្យាបាល និងតតិយជនដទៃទៀត ភាគីដែលនឹងរៀបអាពាហាពិពាហ៍នោះត្រូវមានឆន្ទៈពេញចិត្ត និងស្មគ្រ័ចិត្តដោយខ្លួនឯង ទើបអាពាហ៍ពិពាហ៍នោះចាត់ទុកថាស្របច្បាប់និងត្រឹមត្រូវតាមច្បាប់បាន ចំពោះអាពាហ៍ពិពាហ ដោយមានការបង្ខិតបង្ខំត្រូវហាមឃាត់ដាច់ខាត ។

[៦០] មាត្រា ៧ នៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ

ចំពោះគោលការណ៍បង្ហាញឆន្ទៈនិងការស្មគ្រ័ចិត្តនៃការរៀបអាពាហ៍ពាហ៍ទាំងនេះ ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ៤៥ វាក្យខណ្ឌទី០៤ ចែងថា អាពាហ៍ពិពាហ៍ ត្រូវធ្វើឡើងតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ[៦១]។ មានន័យថារាល់ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍របស់ប្រទេសកម្ពុជា ត្រូវតែធ្វើឡើងតាមគោលការណ៍ស្ម័គ្រចិត្តនិងមានឆន្ទៈពេញចិត្តរបស់ភាគីទាំងសងខាង ភាគីម្ខាងៗមិនអាចបង្ខំភាគីម្ខាងទៀតដើម្បីឲ្យរៀបអាពាហ៍ពិពាហ៍ផ្ទុយនឹងឆន្ទៈរបស់ពួកគេបានឡើយ ហើយតតិយជនក៏មិនអាចបង្ខំឲ្យ ភាគីណាមួយរៀបអាពាហ៍ពិពាហ៍ផ្ទុយនឹងការស្ម័គ្រចិត្តរបស់គេបានដែរ ។

ចំពោះករណីដែលបុគ្គលគ្មានឆន្ទៈ ដើម្បីរៀបអាពាហ៍ពិពាហ៍នេះ ដោយមានការបង្ខិតបង្ខំពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល និងតតិយជនផ្សេងទៀតនោះ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រង់ ៩៥៨ កថាខណ្ឌទី០១ ចែងចែងថា ប្រសិនបើគ្មានឆន្ទៈរៀបអាពាហ៍ពិពាហ៍ រវាងភាគី ដោយសារការភាន់ច្រឡំលើមនុស្ស ការបង្ខំនិងមូលហេតុផ្សេងៗទៀត អាពាហ៍ពិពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ[៦២] ដូចនេះអាពាហ៍ពិពាហ៍ទាំងឡាយណា ដែលធ្វើឡើងដោយមានការបង្ខំពីឪពុកម្តាយឬអ្នកអាណា-ព្យាបាល និងតតិយជនផ្សេងទៀត ត្រូវចាត់ទុកថាផ្ទុយនឹងច្បាប់ ភាគីម្ខាងៗត្រូវតែមានឆន្ទៈពេញចិត្តក្នុងការរៀបអាពាហ៍ពិពាហ៍ទើបអាពាហ៍បែបនេះមានលក្ខណៈគ្រប់គ្រាន់ត្រឹមត្រូវតាមច្បាប់។

ម្យ៉ាងវិញទៀត ក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ ត្រង់មាត្រា ០៤ ក៏បានចែងកំណត់ដែរថា បុរសនិងស្ត្រីដែលមានអាយុពេញលក្ខណៈច្បាប់ និងមានសិទ្ធិពេញលេញក្នុងការសម្រេចអាពាហ៍ពិពាហ៍ ។ ភាគម្ខាងមិនអាចបង្ខំឆន្ទៈភាគីម្ខាងទៀតបានឡើយ ។ គ្មាននរណាម្នាក់អាចបង្ខំបុគ្គលណាម្នាក់ឲ្យរៀបឬរារាំងមិនឲ្យរៀបអាពាហ៍ពិពាហ៍បានឡើយ ។ បើអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់នេះ[៦៣] ។ ក្នុងច្បាប់នេះបានបង្ហាញអំពីសិទ្ធិរបស់ភាគីម្នាក់ៗដែលអាចសម្រេចចិត្តដោយខ្លួនឯងបាន ដោយមិនមានការបង្ខំឬរារាំងអំពីតតិយជនឬឪពុកម្តាយឬអាណាព្យាបាល មិនឲ្យមានការរៀបអាពាហ៍ពិពាហ៍នោះឡើយ គឺភាគីម្ខាងៗមានឆន្ទៈពេញចិត្តនិងការស្មគ្រ័ចិត្តដោយខ្លួនឯងបាន ដើម្បីនឹងជ្រើសរើសគូស្រករប្រចាំជីវិតរបស់ពួកគេ ។

---

[៦១] មាត្រា ៤៥ នៃរដ្ឋធម្មធនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣

[៦២] មាត្រា ៩៥៨នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧

[៦៣] មាត្រា ០៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩

ទោះបីជា ច្បាប់បានចែងអំពីគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈក្នុងការសម្រេចចិត្តរបស់ភាគីម្ខាងៗ ដើម្បីនឹងរៀបអាពាហ៍ពិពាហ៍យ៉ាងនេះក៏ដោយ ក៏មានឪពុកម្តាយឬអាណាព្យាបាលឬតតិយជនមួយចំនួនបានបង្ខិតបង្ខំនិងរារាំងមិនឲ្យភាគីទាំងនោះមានឆន្ទៈឬស្ម័គ្រចិត្តដោយខ្លួនរបស់ពួកគេឡើយ។ ប៉ុន្តែមានកូនមួយចំនួនបានយល់ព្រមសម្រេចចិត្តតាមឪពុកម្តាយឬអាណាព្យាបាល ដោយពួកគេយល់ឃើញថា ឪពុកម្តាយជាអ្នកមានគុណផង ជាអ្នកមានបទពិសោធន៍ច្រើន ក្នុងរឿងគ្រួសារផងត្រូវតែធ្វើអ្វីៗទៅតាមគាត់ប្រាប់ ។ មូលហេតុដែលឪពុកម្តាយឬអាណាព្យាបាល ឬតតិយជនផ្សេងៗទៀតហាមមិនឲ្យភាគីម្ខាងៗមិនអាចបង្ហាញឆន្ទៈឬស្មគ្រ័ចិត្តដោយខ្លួនឯងបាន ហើយព្រមទាំងមានការបង្ខិតបង្ខំឬមានការរារាំងមិនឲ្យរៀបអាពាហ៍ពិពាហ៍នោះ ដោយសារមានកត្តាមួយចំនួនដូចជា ប្រពៃណីទំនៀមទម្លាប់ ទ្រព្យសម្បត្តិ ចរិតលក្ខណៈនិងការយល់ដឹងរបស់ភាគី ការភ័យខ្លាចជាដើម។

## ១.បញ្ហាប្រពៃណីទំនៀមទម្លាប់

នៅប្រទេសកម្ពុជា ជាប្រពៃណីដែលឪពុកម្តាយជាអ្នកចាត់ចែងទុកដាក់អាពាហ៍ពិពាហ៍ឲ្យកូនចៅរស់ខ្លួន ។ មានសុភាសិតខ្មែរមួយថា **នំមិនធំជាងនាឡិ** ។ នេះមានន័យថា កូនប្រុសស្រី គ្មាន សិទ្ធិអំណាចធ្វើសេចក្តីសម្រេចធំជាងឪពុកម្តាយខ្លួនទេ ។ នៅប្រទេសកម្ពុជា អាពាហាពិពាហ៍មិនមែនព្រមព្រៀងតែបុគ្គលទេ ប៉ុន្តែមានការចូលរួមទាំងគ្រួសារទាំងមូលទៀតផង ។ ការចូលរួមរបស់គ្រួសារមានន័យពីរយ៉ាង ទី០១ ការចូលរួមទទួលខុសត្រូវនាពេលបច្ចុប្បន្ន(ការពិនិត្យមើលចរិតមនុស្សទ្រព្យសម្បត្តិ) ពីព្រោះខ្លួនស្គាល់និងដឹងជាងកូន ។ ទី០២ ការចូលរួមទទួលខុសត្រូវនៅពេលអនាគត (ប្រសិនបើកូនស្រីមកផ្ទះវិញ)ពួកគាត់ចិញ្ចឹមនៅពេលក្រោយពេលកូនលែងលះគ្នាគឺពួកគាត់មិនបោះបង់ចោលកូនទេ[៦៤] ។

ទំនៀមទម្លាប់ប្រពៃណីអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាពីដើមមក ច្រើនតែអនុវត្តទៅតាមប្រពៃណីទំនៀមទម្លាប់របស់ខ្លួន ។ នៅពេលដែលបុរសនិងស្ត្រីសម្រេចចិត្តរើសគូស្រករដើម្បីនឹងរៀបអាពាហ៍ពិពាហ៍ត្រូវតែធ្វើទៅតាមការបង្គាប់បញ្ជារបស់ឪពុកម្តាយជាមុនសិន ទើបអាចរៀបការបាន ពួកគេមិនមានសិទ្ធិគ្រប់គ្រាន់ដើម្បីសម្រេចចិត្តដោយខ្លួនឯងបានទេ ដោយសារសង្គមខ្មែរយល់ឃើញថាការរៀបអាពាហ៍ពិពាហ៍វាជារឿងសំខាន់ណាស់ ដូចនេះកូនប្រុសស្រីមិនអាចសម្រេចចិត្តដោយខ្លួនឯងបានទេ គឺត្រូវតែមានការយល់ពីឪពុកម្តាយជាមុខសិន ។ ដោយមានពាក្យចាស់បុរាណលោកពោលថា ម្តាយទុកឪពុកដាក់ ឬនំមិនធំជាងនាឡិ ។

---

[៦៤] ឥន យឿន នីតិគ្រួសារនិងអាពាហ៍ពិពាហ៍ភាគ០១

ការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់ដោយមានការសម្រេចចិត្តពីឪពុកម្តាយឬគ្រួសារជាអ្នកទុកដាក់ឲ្យនោះមានកូនប្រុសស្រីមួយចំនួនត្រូវធ្វើតាមឪពុកម្តាយដោយបង្ខំចិត្ត តែធាតុពិតពួកគេមិនចង់រៀបអាពាហ៍ពិពាហ៍ទាំងដែលខ្លួនមិនពេញចិត្តនោះទេ ដោយសារពួកគាត់តែងតែប្រកាន់ខ្ជាប់នូវទំនៀមទំម្លាប់បែបនេះហើយ ទើបជាហេតុនាំឲ្យមានអាពាហ៍ពិពាហ៍ខ្លះមិនទទួលបាននូវសុភមង្គលក្នុងគ្រួសារឡើយដោយសារតែកូនប្រុសស្រីទាំងនោះ មិនបានស្ម័គ្រព្រមព្រៀងដោយខ្លួនឯងទាំងមិនបានយល់ចិត្តគ្នាទៀតផង ដោយសារការអនុវត្តទៅតាមទំនៀមទម្លាប់នៃការបង្ខិតបង្ខំនិងមានសម្រេចចិត្តពីគ្រួសារនេះហើយ ទើបមានអាពាហ៍ពិពាហ៍និងបញ្ហាប្រឈមមួយចំនួនតែងកើតមាននៅប្រទេសកម្ពុជាបច្ចុប្បន្នដូចជាការទាស់ទែងគ្នា ការលែងលះជាដើម ។

**២.បញ្ហាចង់បានទ្រព្យ**

ភាគីបុរសនិងស្ត្រីដែលសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ ត្រូវឈរលើគោលការណ៍ស្ម័គ្រចិត្តនិងមានឆន្ទៈស្រឡាញ់ពេញចិត្តដោយខ្លួនឯងផ្ទាល់ ដោយគ្មានការបង្ខិតបង្ខំ ឬរារាំងពីឪពុកម្តាយអាណាព្យាបាលឬតតិយជនឡើយ[៦៥] ។ ទោះបីជាអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយមានការស្ម័គ្រចិត្តនិងមានឆន្ទៈពីភាគីក៏ដោយ ប៉ុន្តែពេលខ្លះភាគីដែលរៀបអាពាហ៍ពិពាហ៍នោះពុំមានការស្ម័គ្រឬមានឆន្ទៈដោយខ្លួនឯងទេ ដោយសារឪពុកម្តាយខ្លះចង់បានទ្រព្យសម្បត្តិពីភាគីម្ខាងទៀត ទើបសម្រេចចិត្ត បង្ខិតបង្ខំ ឲ្យកូនរៀបការជាមួយអ្នកមានទ្រព្យសម្បត្តិជាមនុស្សដែលកូនរបស់ខ្លួនមិនពេញចិត្ត ថែមទាំងមិនបានស្រឡាញ់ទៀតផង ។

ដោយសារតែភាពចង់មានចង់បានពេក ធ្វើឱ្យឪពុកម្តាយខ្លះលួងលោមនិងបង្ខិតបង្ខំកូនឲ្យរៀបការដោយសារតែឃើញភាគីម្ខាងទៀតជាអ្នកមានទ្រព្យសម្បត្តិច្រើន ។ ទោះបីជាឪពុកម្តាយមានចិត្តមេត្តាករុណាចំពោះកូនចង់ឲ្យកូនរៀបការឆាប់មានបានយ៉ាងណាក៏ដោយ ប៉ុន្តែមិនត្រូវបង្ខិតបង្ខំចិត្តកូនប្រុសស្រីនោះទេ បើឪពុកម្តាយស្រឡាញ់កូនប្រុសស្រីពិតប្រាកដមែន គួរតែរៀបអាពាហ៍ពិពាហ៍ឲ្យកូនដោយមានការស្ម័គ្រចិត្តត្រឹមត្រូវ នោះទើបគ្រួសារមានសុភមង្គលសេចក្តីសុខចម្រើន ។

អាពាហ៍ពិពាហ៍ដែលធ្វើឡើងដោយការបង្ខិតបង្ខំគ្មានការស្ម័គ្រចិត្តពីកូនប្រុសស្រី ដើម្បីតែភាពចង់មានចង់បានទ្រព្យសម្បត្តិដោយគ្មានការស្មគ្រ័ចិត្តនេះហើយ ជាហេតុនាំឲ្យបញ្ហាប្រឈមកើតឡើង ។

---

[៦៥]មាត្រា ៤ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ និងមាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

### ៣.ការភ័យខ្លាចនិងការយល់ដឹងតិចតួចរបស់ឪពុកម្តាយ

តាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ការរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើងដោយមានការស្ម័គ្រចិត្តនិងមានការបង្ហាញឆន្ទៈពិតប្រាកដពីភាគីម្ខាងៗ ទើបអាពាហ៍ពិពាហ៍ត្រូវបានចាត់ទុកថាស្របច្បាប់និងត្រឹមត្រូវតាមច្បាប់កំណត់ ។ បច្ចុប្បន្នមានអាពាហ៍ពិពាហ៍មួយចំនួនកើតឡើងដោយសារការបង្ខិតបង្ខំកូនដើម្បីឲ្យរៀបអាពាហ៍ពិពាហ៍ទាំងដែលកូនរបស់ខ្លួននៅវ័យក្មេងផង មានការយល់ដឹងតិចតួចផង ណាមួយកំពុងតែជាប់សិក្សារៀនសូត្រទៀត មូលហេតុដែលនាំឲ្យឪពុកម្តាយបង្ខិតបង្ខំកូនឲ្យរៀបការទាំងដែលកូនកំពុងតែសិក្សារៀនសូត្រដូចនេះ ពីព្រោះដោយសារតែឪពុកម្តាយខ្លះមានការភិតភ័យខ្លាចកូនរបស់គាត់ចាស់ជ្រុលមិនអាចនឹងរៀបការបាន ម្យ៉ាងទៀតគាត់គិតថាខ្លួនគាត់ចាស់ហើយ កូនប្រុសស្រីត្រូវតែរៀបអាពាហ៍ពិពាហ៍ដើម្បីបំពេញរបស់ឪពុកម្តាយ ។ មានគ្រួសារខ្លះទៀតបានបញ្ឈប់ការសិក្សារៀនសូត្ររបស់កូនស្រី ដោយគាត់គិតថា មនុស្សស្រីទោះបីជារៀនដល់ថ្នាក់ណាក៏ដោយ ក៏នៅតែក្លាយជាប្រពន្ធរបស់គេដដែរហើយមានឋានៈត្រឹមតែជាស្ត្រីមេផ្ទះប៉ុណ្ណោះ ទើបពួកគាត់បង្ខំចិត្តឲ្យកូនរបស់គាត់រៀបការតែម្តង ។

ចំពោះអាពាហ៍ពិពាហ៍ ដែលបង្កើតឡើងដោយការបង្ខិតបង្ខំ ឬមានការរារាំងដល់ភាគីម្ខាងៗមិនឱ្យរៀបអាពាហ៍ពិពាហ៍នោះ ការធ្វើបែបនេះឈ្មោះថាផ្ទុយនឹងច្បាប់ផង ត្រូវចាត់ទុកថាមោឃភាពផង ពីព្រោះភាគីម្ខាងៗមិនបានសម្រេចចិត្តនិងស្ម័គ្រចិត្តរៀបអាពាហ៍ពិពាហ៍ដោយខ្លួនឯង ។ អាពាហ៍ពិពាហ៍ ដែលបង្កើតឡើងដោយការបង្ខិតបង្ខំនេះឯង តែងនាំមកនូវបញ្ហាប្រឈមដល់ការលែងលះ ដោយសារភាគីដែលរៀបអាពាហ៍ពិពាហ៍ទាំងនោះមិនបានស្ម័គ្រចិត្តហើយក៏គ្មានឆន្ទៈដើម្បីនឹងរៀបអាពាហ៍ពិពាហ៍នោះដែរ ដូចនេះអាពាហ៍ពិពាហ៍គ្មានសុភមង្គលសេចក្តីសុខចម្រើនឡើយ ។

### កថាខណ្ឌទី៤៖ បញ្ហាញាតិនិងញាតិ

ចំណងអាពាហ៍ពិពាហ៍ដែលកើតមានឡើងរវាងញាតិនិងញាតិ តែងកើតមានបញ្ហាប្រឈមមួយ ចំនួននៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ព្រោះការរៀបអាពាហ៍ពិពាហ៍ធ្វើឡើងដោយសារការផ្សំផ្គុំរៀបចំទុក ដាក់ពីឪពុកម្តាយ ដោយពេលខ្លះពុំមានការបង្ហាញឆន្ទៈពីកូនឡើយ ម្យ៉ាងទៀតដោយឪពុកម្តាយយល់ឃើញថា ការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងញាតិរបស់ខ្លួន ធ្វើឱ្យទ្រព្យសម្បត្តិកេរមរតក នៅមូលក្នុងត្រកូលតែមួយដដែលមិនបាត់បង់ទៅកាន់ត្រកូលទៀតឡើយ ទាំងនេះហើយជាហេតុនាំឲ្យបញ្ហានៃការលែងលះ ព្រមទាំងផ្ទុយនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាផង ។

នៅក្នុងក្រមរដ្ឋប្បវេណី ២០០៧ ត្រង់មាត្រា ៩៥១ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតបានចែងថា "**អាពាហ៍ពិពាហ៍មិនអាចធ្វើបានឡើយ រវាងញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី៣ ផងដែរ។**

ម្យ៉ាងទៀត **អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ផង**[៦៦] ។ ទោះបីជាទំនាក់ទំនងញាតិពន្ធ ត្រូវបានបញ្ចប់ ដោយការលែងលះ ដោយសារមរណភាពរបស់សហព័ទ្ធម្ខាង ឬដោយសារការកាត់កាល់ស្មុំកូនកូនពេញលេងក៏ដោយ ។

ដោយផ្អែកតាមអត្ថន័យនៃមាត្រា ៩៥១ និងមាត្រា ៩៥២ នៃក្រមរដ្ឋប្បវេណីខាងលើនេះបានកំណត់ថាបុគ្គលដែលមានទំនាក់ទំនងញាតិក្នុងថ្នាក់ខ្លះ ត្រូវបានហាមឃាត់មិនឲ្យធ្វើការរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាឡើយ ។

### ១.ទំនាក់ទំនងញាតិ

ញាតិ សំដៅដល់ ញាតិលោហិតក្នុង ៦ ថ្នាក់ សហព័ទ្ធ និងញាតិពន្ធក្នុង ៣ ថ្នាក់ ។

ថ្នាក់ញាតិ គឺជាឯកត្តាបង្ហាញអំពីរូបភាពនៃទំនាក់ទំនងញាតិ ។ ប្រសិនបើលេខលំដាប់ញាតិកាន់តែតូច ទំនាក់ទំនងញាតិ ក៏កាន់តែជិតស្និទ្ធដែរ ។

#### ក.ខែ្សញាតិលោហិត

**ញាតិលោហិត** សំដៅដល់ បុគ្គលដែលមានទំនាក់ទំនងសាច់លោហិតពីកំណើតជាមួយបុគ្គលម្នាក់ទៀត (ហៅថា ញាតិលោហិតពីកំណើត) ។ ឧទាហរណ៍ៈ ឪពុកម្តាយ កូន ចៅ ឬចៅទួតជាដើម ។

**ញាតិលោហិតខ្សែផ្ទាល់** សំដៅដល់ ញាតិដែលមានសាច់ឈាមជាមួយគ្នា ហើយកើតតគ្នាពីមួយទៅមួយទៀតតាមលំដាប់ ដូចជា ឪពុកម្តាយ កូន ចៅ ឬចៅទួត ជាដើម ។

ហាមឃាត់រៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិតផ្ទាល់ ទោះបីជាក្រោយពេលដែលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ដោយការបញ្ចប់ញាតិ ជាមួយឪពុក ម្តាយបង្កើតដោយសារស្មុំកូនពេញលេញ ឬ ដោយសារការកាត់កាល់ស្មុំកូនពេញលេញ ឬដោយសារការកាត់កាល់ ស្មុំកូនធម្មតាក៏ដោយ[៦៧] ។

---

[៦៦] មាត្រា ៩៥២ ក្រមរដ្ឋប្បវេណី ២០០៧

[៦៧] មាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឧទាហរណ៍៖ នៅពេលដែល ដានី មានអាយុ ៧ ឆ្នាំ ឪពុកម្តាយបង្កើតរបស់ដានី បានឱ្យដានី ទៅអ្នកដទៃចិញ្ចឹមតាមរយៈ សុំកូនពេញលេញ ។ ក្នុងករណីបែបនេះ ទំនាក់ទំនងញាតិរវាង ដានី និង ឪពុកម្តាយបង្កើតត្រូវបញ្ចប់តាមមាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណី ។ ទោះបីជាយ៉ាងនេះក្តី នៅពេល ដែល កញ្ញា ដានី ធំពេញវ័យគឺនាងមិន អាចរៀបការជាមួយ នឹងឪពុកបង្កើតរបស់នាងបានឡើយ ។

ឧបមាថា ក្រោយមក ទំនាក់ទំនងរវាងកញ្ញា ដានី និងឪពុកម្តាយចិញ្ចឹមរបស់នាងត្រូវបាន កាត់ផ្តាច់តាមរយៈការកាត់កាល់ ។ ដូចនេះ នាងនិងឪពុកម្តាយចិញ្ចឹមរបស់នាងលែងជាញាតិនឹងគ្នា ទៀតហើយ ។ ទោះជាយ៉ាងនេះក៏ដោយ គឺនាងមិនអាចរៀបការជាមួយនឹងអតីតឪពុកចិញ្ចឹមរបស់ នាងបានឡើយ ។

ឧទាហរណ៍៖ នៅពេលដែលកញ្ញាចន្ថា មានអាយុ ២០ ឆ្នាំ នាងបានព្រមព្រៀងបង្កើត សុំកូន ធម្មតា ជាមួយនឹងលោក ដារ៉ា អាយុ ៥០ ឆ្នាំ ។ ក្នុងករណីនេះ កញ្ញា ចន្ថា ត្រូវមានទំនាក់ទំនងផ្លូវ ច្បាប់ជាមួយនឹងឪពុកម្តាយបង្កើតរបស់នាងផង និងត្រូវមានទំនាក់ទំនងផ្លូវច្បាប់នឹងលោក ដារ៉ា ផង ដែរ។ លុះក្រោយមក ក៏មានការកាត់កាល់ទំនាក់ទំនងសុំកូនធម្មតារវាងកញ្ញា ចន្ថា និងលោក ដារ៉ា ។ នេះមានន័យ ថារវាងកញ្ញា ចន្ថា និងលោក ដារ៉ា លែងជាឪពុកចិញ្ចឹម និងកូនទៀតហើយ ។ ទោះបីជាយ៉ាងនេះក្តី កញ្ញា ចន្ថា គឺមិនអាចរៀបការជាមួយនឹងលោក ដារ៉ា បានជាដាច់ខាត[៦៨] ។

### +.រវាងសាខាញាតិលោហិតក្នុងបីថ្នាក់

សាខាញាតិ (ញាតិដែលបែកចេញជាមែកធាងពីអ្នកបង្កើតរួម)៖ មីង មា និងក្មួយ បងប្អូនបង្កើត បងប្អូនជីដូនមួយ។ ម្យ៉ាងទៀត សាខាញាតិ គឺជាញាតិដែលចែកចេញជាមែកធាងពីបុព្វជនដូចគ្នា មានដូចជា បងប្អូនបង្កើត (សាខាញាតិលោកហិតថ្នាក់ទី០២) មាមីងក្មួយ (សាខាញាតិលោហិតថ្នាក់ ទី០៣) បងប្អូនជីដូនមួយ (សាខាញាតិលោហិតថ្នាក់ទី០៤)។

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយ រវាងញាតិលោហិតខ្សែផ្ទាល់ ឬសាខាញាតិលោហិតក្នុង បីថ្នាក់ រាប់ទាំងថ្នាក់ទីបីផង[៦៩]។ ដោយផ្អែកតាមមាត្រា ៩៥១ នៃក្រមរដ្ឋប្បវេណីនេះ ច្បាប់ហាមប្រាម មិនអនុញ្ញាតឲ្យសាខាញាតិលោហិតរៀបការជាមួយគ្នាបានទេ ។

ទោះបីជាក្រោយពេលដែលទំនាក់ទំនងញាតិ ត្រូវបានបញ្ចប់ដោយការបញ្ចប់ញាតិជាមួយ ឪពុក ម្តាយបង្កើតដោយសារសុំកូនពេញលេញ ឬដោយសារការកាត់កាល់សុំកូនពេញលេញ ឬ ដោយសារការកាត់កាល់សុំកូនធម្មតាក៏ដោយ ។

[៦៨] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ

[៦៩]មាត្រា ៩៥១ ក្រមរដ្ឋប្បវេណី ២០០៧ (បងប្អូនបង្កើត =សាខាញាតិថ្នាក់ទី២, មាមីង និងក្មួយ =សាខាញាតិថ្នាក់ទី៣)

**+.សាខាញាតិលោហិតក្នុង៦ថ្នាក់**

នៅក្នុងសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី បានពន្យល់អំពីការគណនាថ្នាក់ញាតិនេះយកតាមលំនាំពួករ៉ូម៉ាំង ។

មាត្រា៩៣៨នៃក្រមរដ្ឋប្បវេណីបានរាប់ទំហំញាតិលោហិត ៦ ថ្នាក់ដោយបានរាប់ដូចតទៅ ៖

៦. ជីប៉ា (ញាតិថ្នាក់៦)

៥. ជីលា (ជីដូនលា ឬជីតាលា) (ញាតិថ្នាក់៥)

៤. ជីលួត (ជីដូនលួត ឬជីតាលួត)(ញាតិថ្នាក់៤)

៣. ជីទួត (ជីដូនទួត ឬជីតាទួត (ញាតិថ្នាក់៣)

២. ជីដូនឬជីតា (ញាតិថ្នាក់២)

១. ឪពុកឬម្តាយ (ញាតិថ្នាក់១)

ការគណនាអំពីញាតិ ដែលបានរៀបរាប់នៅក្នុងវចនានុក្រមខ្មែររបស់ព្រះពុទ្ធសាសនាបណ្ឌិត្យ បោះពុម្ព ឆ្នាំ១៩៦៧ ដែលរៀបរាប់អំពីថ្នាក់នៃញាតិ មានចំនួនរហូតដល់ទៅ ៧ ថ្នាក់ ទាំងបុព្វញាតិខ្សែផ្ទាល់ និងបច្ឆាញាតិខ្សែផ្ទាល់ ដែលមានដូចជា ៖

| | |
|---|---|
| ៧ ចុងគល់ឬចុងកុល(ឪពុកឬម្តាយរបស់ជីប៉ា) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៧) |
| ៦ ជីប៉ា (ឪពុកឬម្តាយរបស់ជីលា) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៦) |
| ៥ ជីលា (ឪពុកឬម្តាយរបស់ជីលួត) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៥) |
| ៤ ជីលួត (ឪពុកម្តាយរបស់ជីដូនឬជីតា) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៤) |
| ៣ ជីទួត (ឪពុកម្តាយរបស់ជីដូន ឬជីតា) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៣) |
| ២ ជីតា ឬ ជីដូន | (ញាតិខ្សែផ្ទាល់ថ្នាក់ទី២) |
| ១ ឪពុក ឬ ម្តាយ | (ញាតិខ្សែផ្ទាល់ថ្នាក់ទី១) |
| ១ កូន | (ញាតិខ្សែផ្ទាល់ថ្នាក់ទី១) |
| ២ ចៅប្រុស ឬ ចៅស្រី | (ញាតិខ្សែផ្ទាល់ថ្នាក់ទី២) |
| ៣ ចៅទួត (កូនរបស់ចៅ | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៣) |
| ៤ ចៅលួត(កូនរបស់ចៅទួត) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៤) |
| ៥ ចៅលា(កូនរបស់ចៅលួត) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៥) |
| ៦ ចៅប៉ា (កូនរបស់ចៅលា) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៦) |
| ៧ ចៅចុងកុល (កូនរបស់ចៅប៉ា) | (ញាតិខ្សែផ្ទាល់ថ្នាក់ទី៧) |

ចុងគល់ ឬ ចុងកុល សំដៅដល់ញាតិខ្សែខាងលើ ដោយរាប់តាមលំដាប់លំដោយទៅលើថា ជីដូន, ជីទួត, ជីលួត, ជីលា, ជីប៉ា, ចុងគល់ ឬ ចុងកុល ។ ជីប៉ា គឺអាចមានអ្នកដែលមានអាយុត្រឹម ១៣០ឆ្នាំ ហើយដែលនៅរស់ ប៉ុន្តែចុងគល់ឬ ចុងកុល គឺលុះត្រាតែអ្នកដែលមានអាយុប្រហែលគ្នា ១៤០ឆ្នាំ ទៅ១៥០ឆ្នាំ ទៅទើបអាចមានបុព្វញាតិដល់ចុងគល់ ឬចុងកុល ដែលអាចរស់នៅក្នុងជំនាន់ជាមួយគ្នាបាន[៧០]។

**ខ.រខាខញាតិពន្ធ**

ញាតិពន្ធ សំដៅដល់ ចំណងគតិយុត្តរវាងសហព័ទ្ធម្ខាងនិងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀត ឬហៅថាសាច់ថ្លៃ ។ ឧទាហរណ៍៖ បងថ្លៃ ប្អូនថ្លៃ ឪពុកម្តាយក្មេក និងកូនប្រសា ជីតា ជីដូនក្មេក និងចៅប្រសា ។

ញាតិពន្ធខ្សែផ្ទាល់ សំដៅដល់ ញាតិលោហិតខ្សែផ្ទាល់ខាងសាច់ថ្លៃ ដែលកើតតពីមួយទៅមួយតាមលំដាប់ដូចជា ជីដូនជីតាក្មេក ឪពុកម្តាយក្មេក កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត[៧១] ។

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ផង[៧២] ។ ទោះបីជាទំនាក់ទំនងញាតិពន្ធ ត្រូវបានបញ្ចប់ ដោយការលែងលះដោយសារមរណភាពរបស់សហព័ទ្ធម្ខាង ឬដោយសារការកាត់កាល់ស្មុំកូនពេញលេញក៏ដោយ ។

ឧទាហរណ៍៖ លោក សំខាន់ បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងនឹង កញ្ញា ។ ប៉ុន្តែក្រោយមក លោក សំខាន់ ក៏បានទទួលមរណភាព ។ ទោះបីជាយ៉ាងនេះក៏ដោយ នាង កញ្ញា នៅតែមិនអាចរៀបការជាមួយនឹងឪពុករបស់លោក សំខាន់ បានឡើយ ពីព្រោះថានាង កញ្ញា និងឪពុករបស់លោក សំខាន់ គឺជាឪពុកក្មេកនិងកូនប្រសា (គឺញាតិពន្ធនៃខ្សែផ្ទាល់ថ្នាក់ទី០១) ។

ឧទាហរណ៍៖ កញ្ញា ធីតា គឺជាកូនស្មុំពេញលេញរបស់លោកស្រី ចិន្តា ។ បន្ទាប់មកកញ្ញា ធីតា បានរៀបការជាមួយនឹងលោក បញ្ញា ។ លុះក្រោយមកមួយរយៈ ទំនាក់ទំនងរវាងលោកស្រី ធីតា និងម្តាយចិញ្ចឹមរបស់នាង(លោកស្រីចិន្តា) ត្រូវបានកាត់ផ្តាច់ដោយសារការកាត់កាល់ ហើយលោកស្រី ធីតា ក៏បានលែងលះជាមួយនឹងលោក បញ្ញា ផងដែរ ។ ក្នុងករណីនេះ លោកស្រី ធីតា លែងជាកូន

[៧០]ឥន យឿន នីតិគ្រួសារនិងអាពាហ៍ពិពាហ៍ភាគ០១

[៧១] ឥន យឿន នីតិគ្រួសារនិងអាពាហ៍ពិពាហ៍ភាគ០១

[៧២]មាត្រា ៩៥២ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

សុំរបស់លោកស្រី ចិន្តា ទៀតហើយ ។ ទោះបីជាយ៉ាងនេះក្តី លោកបញ្ញា មិនអាចរៀបការជាមួយនឹងលោកស្រី ចិន្តា ដែលជាអតីតម្តាយក្មេកបានឡើយ[៧៣] ។

**+.រវាងសាខាញាតិពន្ធក្នុងបីថ្នាក់**

មាត្រា៩៣៨នៃក្រមរដ្ឋប្បវេណីបានរាប់ទំហំញាតិពន្ធក្នុង ៣ ថ្នាក់ដោយបានរាប់ដូចតទៅ ៖

១-ឪពុកម្តាយក្មេក និងកូនប្រសា (ញាតិពន្ធថ្នាក់ទី០១)

២-ជីដូនជីតាក្មេក និងចៅប្រសា (ញាតិពន្ធថ្នាក់ទី០២)

៣-ជីដូនជីតាទួតក្មេក និងចៅប្រសាទួត (ញាតិពន្ធថ្នាកទី០៣) ។

អាពាហ៍ពិពាហ៍ពុំអាចធ្វើបានឡើយរវាងញាតិពន្ធនៃខ្សែផ្ទាល់ និងរវាងសាខាញាតិពន្ធនៅក្នុង ៣ថ្នាក់ រាប់ទាំងថ្នាក់ទី ៣ផង[៧៤]។ បុរស និងស្ត្រីដែលស្នើសុំរៀបអាពាហ៍ពិពាហ៍នឹងគ្នា មិនត្រូវជាប់ចំណងញាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះបីជានៅថ្នាក់ណាក៏ដោយ។ ទោះបីជាញាតិពន្ធខ្សែផ្ទាល់បានបញ្ចប់ទំនាក់ទំនងញាតិពន្ធហើយក៏ដោយ ច្បាប់មិនអនុញ្ញាតឱ្យញាតិពន្ធខ្សែផ្ទាល់នោះ អាចរៀបអាពាហ៍ពិពាហ៍នឹងគ្នាបានដែរ។

ក្នុងករណីពិសេស **ប្រសិនបើសហព័ទ្ធណាមួយស្លាប់ សហព័ទ្ធដែលនៅរស់អាចរៀបអាពាហ៍ពិពាហ៍ជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬទី ៣បាន**[៧៥]។ ចំណុចនេះ ច្បាប់បានចែងដើម្បីបន្ថយ លក្ខណៈងាយស្រួលដល់សហព័ទ្ធ និងការពារដល់កុមារជាកូនចៅសហព័ទ្ធ ព្រោះបុគ្គលសាខាញាតិដែលបានរៀបអាពាហ៍ពិពាហ៍ក្រោយនេះ ធ្លាប់មានមនោសញ្ចេតនាស្រឡាញ់រាប់អានដល់កូនរបស់សហព័ទ្ធដែលមានរួចមកហើយ ដូច្នេះការអប់រំ ការចិញ្ចឹមបីបាច់ថែរក្សារបស់សហព័ទ្ធថ្មីនឹងបានល្អ[៧៦]។

ឧទាហរណ៍៖ កញ្ញាធីតា បានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងលោក សំខាន់ ។ កញ្ញា ធីតា មានប្អូនស្រីបង្កើតម្នាក់ឈ្មោះ ណារី ។ ក្រោយមក អ្នកទាំងពីរបានលែងលះគ្នា ។ ហេតុដូចនេះ ទំនាក់ទំនងញាតិពន្ធរវាងលោក សំខាន់ និងកញ្ញា ណារី (សាខាញាតិពន្ធថ្នាក់ទី០២) គឺបានរលត់ទៅហើយ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏លោកសំខាន់ មិនអាចរៀបការជាមួយនឹងកញ្ញា ណារី បានដែរ ។ ក៏

[៧៣] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ

[៧៤] មាត្រា ៩៥២ ក្រមរដ្ឋប្បវេណី ២០០៧

[៧៥] បងថ្លៃនិងប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី០២), ពូសាច់ថ្លៃ និងក្មួយ (សាខាញាតិពន្ធថ្នាក់ទី០៣)

[៧៦] មាត្រា ៨ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ

ប៉ុន្តែ នៅក្នុងសម្មតិកម្មដដែលនេះ ប្រសិនបើលោកស្រី ធីតា បានស្លាប់បាត់បង់ជីវិតវិញ គឺលោក សំខាន់ អាចរៀបការជាមួយនឹងកញ្ញា ណារី បាន ។

ឧទាហរណ៍ៈ កញ្ញា **ធីតា** បានរៀបការជាមួយនឹងលោក **សំខាន់** ។ កញ្ញា **ធីតា** មានក្មួយស្រីម្នាក់ ឈ្មោះកញ្ញា **ដារី** (បានន័យថា **លោក សំខាន់ និងកញ្ញា ដារី គឺជាសាខាញាតិពន្ធថ្នាក់ទី៣ៈ ពូសាច់ថ្លៃ និងក្មួយ**) ។ ដូច្នេះ ប្រសិនបើលោកស្រី **ធីតា** បានលែងលះជាមួយលោក **សំខាន់** នោះលោក **សំខាន់** គឺមិនអាចរៀបការជាមួយនឹងកញ្ញា **ដារី** បានទេ ក៏ប៉ុន្តែបើក្នុងករណីដែលលោកស្រី **ធីតា** ស្លាប់បាត់បង់ជីវិតវិញ គឺលោក **សំខាន់** ប្រាកដជាអាចរៀបការជាមួយនឹងកញ្ញា **ដារី** បាន[៧៧]។

យ៉ាងណាមិញ ការបំពានលក្ខខណ្ឌអាពាហ៍ពិពាហ៍ទាក់ទិននឹងទំនាក់ទំនងញាតិ គឺជាបទល្មើស ស្មន់ ស្របតាមមាត្រា ៦ ចែងថា បុរសឬស្ត្រី ដែលជាប់ចំណងជាញាតិលោហិត ឬពាតិពន្ធក្នុងខ្សែផ្ទាល់គ្រប់ថ្នាក់ ទោះចំណងនោះមានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ឬសាច់ញាតិចិញ្ចឹមក្តី បានរួមសេវនកិច្ចជាមួយគ្នា ។

បុរសនិងស្ត្រីដែលជាប់ចំណងសាខាញាតិនឹងគ្នា ទោះសាខាញាតិនោះ មានខាន់ស្លាក្តី ឥតខាន់ស្លាក្តី ចិញ្ចឹមក្តី រួមម្តាយក្តី រួមឪពុកក្តី រួមម្តាយឪពុកក្តី ជាញាតិលោហិតក្តី ឬជាញាតិពន្ធក្តី រហូតដល់ថ្នាក់ទី៣ រាប់ទាំងថ្នាក់នេះផង បានរួមសេវនកិច្ចនឹងគ្នា ។

មិនចាត់ទុកថាមានពិរុទ្ធពីបទស្មន់ទេ ប្រសិនបើសហាព័ទ្ធណាម្នាក់ស្លាប់ ហើយសហាព័ទ្ធដែលនៅរស់រួមសេវនកិច្ចជាមួយសាខាញាតិពន្ធថ្នាក់ទី២ ឬថ្នាក់ទី៣[៧៨]។

ចំណែកក្នុងមាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាពដដែល បានចែងឲ្យផ្តន្ទាទោសចំពោះជនណាដែលបានប្រព្រឹត្តល្មើសក្នុងមាត្រា៦ នៃច្បាប់ស្តីពីឯកពន្ធភាព គឺ(ទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ឆ្នាំ និងឬពិន័យពី ២ សែនរៀល ដល់ ១លានរៀល) ។ ប៉ុន្តែផ្ទុយទៅវិញ បើផ្អែកតាមមាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌចាត់ទុកថាជាបទ រួមភេទរវាងញាតិលោហិត ឬញាតិពន្ធ ទៅវិញ (ទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ១ឆ្នាំ និងឬពិន័យពី ១ សែនរៀល ដល់ ២លានរៀល)[៧៩]។

---

[៧៧] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាង ស៊ីណាត នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ

[៧៨] មាត្រា ៦ នៃច្បាប់ស្តីពីឯកពន្ធភាព

[៧៩] មាត្រា ១០ នៃច្បាប់ស្តីពីឯកពន្ធភាព និងមាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌ

នៅក្នុងកថាខណ្ឌទី០២ មាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌចែងថា មិនចាត់ទុកជាបទល្មើសរួមភេទរវាងញាតិលោហិត ឬញាតិពន្ធទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមភេទជាមួយសាខាញាតិពន្ធ ថ្នាក់ទី២ ឬថ្នាក់ទី៣[៨០]។

ជារួមការរៀបអាពាហ៍ពិពាហ៍រវាងញាតិនិងញាតិ នាំឱ្យមានបញ្ហាប្រឈមមួយចំនួនដូចជា អំពើល្មើសច្បាប់សាហាយស្មន់ អំពើអសន្តិសុខក្នុងគ្រួសារ អាពាហ៍ពិពាហ៍មិនគង់វង្សឋិតថេរ ដោយសារផ្ទុយច្បាប់ ការបែងចែកទ្រព្យមានភាពស្មុគស្មាញច្រើន អំពើផិតក្បត់នាំឲ្យមានការលែងលះ ការប្រចណ្ឌដោយភាពច្រណែន បញ្ហាឃាតកម្មក្នុងគ្រួសារ ។

**កថាខណ្ឌទី៥៖ បញ្ហាមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ឬអេតាស៊ីវិល**

ការរៀបអាពាហ៍ពិពាហ៍ភាគច្រើននៅកម្ពុជាបច្ចុប្បន្ន ជាពិសេសនៅតាមជនបទ បានធ្វើទៅដោយគ្រាន់តែរៀបចំពិធី ទៅតាមប្រពៃណីទំនៀមទម្លាប់តែប៉ុណ្ណោះ ក៏ប៉ុន្តែពុំបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវទៅតាមច្បាប់នោះទេ ចំណងអាពាហ៍ពិពាហ៍ដែលមានត្រឹមតែពិធីរៀបការតាមទំនៀមទម្លាប់ប្រពៃ ដោយគ្មានការចុះសំបុត្រអាពាហ៍ពិពាហ៍បែបនេះ មិនមានសុពលភាពតាមផ្លូវច្បាប់នោះទេ មានន័យថាបើទោះជាគូស្វាមីភរិយានេះ រស់នៅជាមួយគ្នាដែលមានការទទួលស្គាល់ពីសង្គមថាជាប្ដីប្រពន្ធរៀបការពេញមុខពេញមាត់ហើយក៏ដោយ ក៏ប៉ុន្តែតាមផ្លូវច្បាប់អ្នកទាំងពីរកំពុងតែរស់នៅដោយគ្មានចំណងអាពាហ៍ពិពាហ៍នោះទេ ។ អាពាហ៍ពិពាហ៍បែបនេះអាចនឹងបង្កជាបញ្ហាស្មុគស្មាញច្រើន ជាពិសេសនៅពេលដែលមានការលែងលះ ឬក៏នៅពេលដែលភាគីណាមួយលប់លួចទៅមានប្ដីឬប្រពន្ធផ្សេងមួយទៀតដោយឥតមានច្បាប់ណាហាមឃាត់បាន ហេតុដូចនេះហើយទើបច្បាប់តម្រូវឱ្យភាគីប្ដីប្រពន្ធដែលត្រូវរៀបអាពាហ៍ពិពាហ៍នោះ ទៅចុះសំបុត្រអាពាហ៍-ពិពាហ៍ឱ្យបានត្រឹមត្រូវតាមផ្លូវច្បាប់[៨១]។

**១.អាពាហ៍ពិពាហ៍ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍**

ដោយយោងតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្ដីពីអត្រានុកូលដ្ឋានបានចែងថា អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលគ្នាជាប្ដី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារី។

[៨០]បងថ្លៃនិងប្អូនថ្លៃ (សាខាញាតិពន្ធថ្នាក់ទី០២), ឰសាច់ថ្លៃ និងក្មួយ (សាខាញាតិពន្ធថ្នាក់ទី០៣)

[៨១]សម្លេងវិទ្យុបារាំង RFI

កិច្ចសន្យានេះ ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍ ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ២នាក់ផងដែរ[៨២]។

ម្យ៉ាងវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា អាពាហ៍ពិពាហ៍នឹងមានអានុភាព **ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។**

ចំពោះការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសារធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវកំណត់ទៅតាមនីតិវិធីស្តីពីការចុះបញ្ជីអត្រា-នុកូលដ្ឋាន[៨៣]។

### ក.ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍

ដោយយោងតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ចំពោះចែងថាបុរសនារីដែលមានបំណងរៀបអាពាហ៍តាមផ្លូវច្បាប់ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅឋានសាមីខ្លួនខាងនារី ចំពោះឯកសារក្នុងការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ត្រូវមានៈ

- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត
- ការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល ចំពោះអនីតិជន។
- ភស្តុតាងនៃការរំលាយអាពាហ៍ពិពាហ៍មុនមានដូចជា សាលក្រមលែងលះ សាលក្រមស្តីពីការបាត់ខ្លួន ឬសំបុត្រមរណភាព ឬមោឃភាពនៃអាពាហ៍ពិពាហ៍។
- សំបុត្របញ្ជាក់ថាបានគោរពវិធវភាព
- ការអនុញ្ញាតក្នុងករណីដែលគូស្រករមានជាប់ញាតិ និងញាតិពន្ធ
- លិខិតបញ្ជាក់ពីមន្ត្រីអត្រានុកូលដ្ឋាន ឬពីកន្លែងការងារថាខ្លួនពិតជានៅលីវ(លិខិតនេះហៅថា កិច្ចសន្យាសាមីជនកូនប្រុស ស្រី)
- ពាក្យសុំរៀបអាពាហ៍ពិពាហ៍របស់កូនប្រុស (ករណីកូនប្រុស និងកូនស្រីមានលំនៅឋានក្នុងឃុំ សង្កាត់ខុសគ្នា)

---

[៨២] មាត្រា ៣០ នៃ អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

[៨៣] មាត្រា ៩៥៥ ក្រមរដ្ឋប្បវេណី ២០០៧

- ក្រោយពីបានឯកសារនេះហើយ ខាងប្រុសត្រូវយកលិខិតនេះភ្ជាប់មកជាមួយបែបបទសុំរៀបអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់នាលំនៅឋានរបស់នារី។

**ខ.ការជូនដំណឹងជាសាធារណៈ**

មន្ត្រីអត្រានុកូលដ្ឋាន ត្រូវបិទប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ដែលគ្រោងនឹងធ្វើនោះផ្សាយជាសាធារណៈនៅលំនៅឋាន និងនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួននារីមួយច្បាប់។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ២ច្បាប់ទៀតត្រូវផ្ញើទៅជូនមន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់ខាងបុរស ដើម្បីយកទៅបិទផ្សាយនៅលំនៅដ្ឋាន និងបិទនៅសាលាឃុំ ឬសង្កាត់នៃសាមីខ្លួនបុរស ១ច្បាប់។

**-ប័ណ្ណប្រកាសត្រូវចុះ**

- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅឋាននៃអនាគតប្តី ប្រពន្ធ។
- នាមត្រកូល នាមខ្លួន អាយុ មុខរបរ និងលំនៅឋានរបស់ឪពុក ម្តាយ នៃអនាគតប្តី ប្រពន្ធ បើឪពុកម្តាយ ឬម្តាយស្លាប់ ត្រូវដាក់ថាស្លាប់។
- ត្រូវដាក់រយៈពេលកំណត់ដែលអាចប្តឹងទាស់បាននឹងអាពាហ៍ពិពាហ៍នោះ(គឺរយៈពេល ១០ថ្ងៃ គិតចាប់ពីថ្ងៃបិទប័ណ្ណប្រកាសផ្សាយជាសាធារណៈ)។

**-រយៈពេលប្រកាសផ្សាយ**

ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ត្រូវបិទផ្សាយក្នុងរយៈពេល ១០ថ្ងៃ អាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបានក្រោយរយៈពេលបិទផ្សាយនេះមានន័យថា បើក្នុងរយៈពេល ១០ថ្ងៃនេះគ្មាននរណាប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍របស់ពួកគេទេ នោះពិធីរៀបអាពាហ៍ពិពាហ៍អាចប្រព្រឹត្តទៅបាន[៩៤]។

**គ.ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍**

អាពាហ៍ពិពាហ៍នឹងចាត់ទុកជាត្រឹមត្រូវតាមលក្ខណៈច្បាប់បាន លុះត្រាតែបុរស និងនារីដែលស្ម័គ្រចិត្តទទួលគ្នាជាប្តី ប្រពន្ធ ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានខាងលំនៅឋានរបស់នារី។ កិច្ចសន្យានេះ **ត្រូវចុះក្នុងសៀវភៅអាពាហ៍ពិពាហ៍** ហើយត្រូវចុះហត្ថលេខាដោយមន្ត្រីអត្រានុកូលដ្ឋាន និងផ្តិតមេដៃ ប្តី ប្រពន្ធ និងសាក្សីគ្រប់អាយុការចំនួន ២នាក់ផងដែរ[៩៥]។

[៩៤]មាត្រា ១៣ នៃក្រមរដ្ឋប្បវេណី ២០០៧

[៩៥]មាត្រា ៣០ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

ពេលសាមីខ្លួនជាអនាគតប្តី និងប្រពន្ធ មករាយការណ៍សុំចុះសៀវភៅអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅអាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគល់ឱ្យសាមីខ្លួនប្តី ប្រពន្ធ នូវសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម ១សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន[៨៦]។

## ឃ.ការចុះបញ្ជីអាពាហ៍ពិពាហ៍

នៅពេលមានសាមីខ្លួនប្តីប្រពន្ធមកសុំចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងសំបុត្រអាពាហ៍ពិពាហ៍ និងបន្ទាប់ពីពិនិត្យលិខិតស្នាមឃើញថា ត្រឹមត្រូវទៅតាមកំណត់សព្វគ្រប់ហើយមន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ចំនួន ០២ ច្បាប់ មានខ្លឹមសារដូចគ្នាទាំងស្រុងនៅសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ភ្លោះ ។

របៀបសរសេរចុះបញ្ជីអាពាហ៍ពិពាហ៍ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ដែលបានចុះលេខនិងចុះឆ្នាំរួចហើយមានដូចខាងក្រោម៖

-ខេត្ត ក្រុង, ស្រុក ខណ្ឌ, ឃុំ សង្កាត់៖ របស់សាមីខ្លួនរស់នៅ ។

-លេខ៖ ត្រូវសរសេរបញ្ជីអាពាហ៍ពិពាហ៍ ដោយសរសេរជាលេខខ្មែរ ។

-សៀវភៅអាពាហ៍ពិពាហ៍លេខ៖ ត្រូវសសេសរលេខសៀវភៅដូចលេខដែលចុះខាងក្របមុខនៃសៀវភៅអាពាហ៍ពិពាហ៍ដែលកំពុងសរសេរ ។

-ឆ្នាំ ត្រូវសសេសរដូចឆ្នាំដែលចុះខាងក្របមុខ នៃសៀវភៅអាពាហ៍ពិពាហ៍ដែលកំពុងសរសេរ។

-នាម គ្រកូល និងនាមខ្លួន និងនាមគ្រកូល និងនាមខ្លួន ជាអក្សរឡាតាំង ។

-សញ្ជាតិ និង ថ្ងៃខែ ឆ្នាំ កំណើត៖ ត្រូវសរសេរឈ្មោះថ្ងៃជាអក្សរខ្មែរ ទីជាលេខខ្មែរ ខែអក្សរខ្មែរ និងឆ្នាំជាលេខខ្មែរ។

-ទីកន្លែងកំណើត៖ ត្រូវសរសេរឈ្មោះភូមិ ឃុំ ឬ សង្កាត់ ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ប្រទេស ។

-មុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍៖ ត្រូវសរសេរមុខរបរពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ។

-ទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍៖ ត្រូវសរសេរទីលំនៅពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ។

-លេខអត្តសញ្ញាណប័ណ្ណ៖ ករណីមិនមានសាមីអាចមកស្នើសុំចុះជាខាងក្រោយបាន ។

-ចុះបញ្ជីអាពាហ៍ពិពាហ៍លើកទី៖ ត្រូវសរសេរចំនួនលើកទីប៉ុន្មានជាអក្សរ ។

[៨៦]មាត្រា ៣១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

-ថ្ងៃខែឆ្នាំចុះបញ្ជីអាពាហ៍ពិពាហ៍៖ ត្រូវសរសេរថ្ងៃជាអក្សរ ទីជាលេខខ្មែរ ខែជាអក្សរ ឆ្នាំជាលេខ ។

-ទីកន្លែងចុះបញ្ជីអាពាហ៍ពិពាហ៍៖ ត្រូវសរសេរឈ្មោះសាលាឃុំ ឬសង្កាត ក្រុង ឬស្រុក ឬខណ្ឌ រាជធានី ឬខេត្ត ដែលប្តីប្រពន្ធទៅសុំចុះបញ្ជីអាពាហ៍ពិពាហ៍ ។

-លេខនិងថ្ងៃ ខែ ឆ្នាំ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍៖ ត្រូវសរសេរលេខប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ និងថ្ងៃទី ជាលេខ ខែជាអក្សរ និងឆ្នាំជាលេខ ។

-នាមត្រកូល និងនាមខ្លួនឪពុកម្តាយ និងសញ្ជាតិ

-នាមត្រកូល និងនាមខ្លួនឪពុកម្តាយ ជាអក្សរឡាតាំង

-រស់ ឬស្លាប់៖ បើនៅរស់ត្រូវឆូតចោលពាក្យ ស្លាប់ បើស្លាប់ឆូតចោលពាក្យ រស់ ។

-ថ្ងៃខែឆ្នាំកំណើត , មុខរបរបច្ចុប្បន្ន, ទីលំនៅបច្ចុប្បន្ន ។

-សម្រាប់សាក្សីត្រូវសរសេរ៖ នាមត្រកូល និងនាមខ្លួន, ភេទ, សញ្ជាតិ ,ខែឆ្នាំកំណើត ,មុខរបរបច្ចុប្បន្ន, ទីលំនៅបច្ចុប្បន្ន , លេខអត្តសញ្ញាណប័ណ្ណរបស់សាក្សី[៨៧] ។

នៅពេលសរសេរបំពេញក្នុងខ្ទង់ខាងលើនេះបំពេញចប់សព្វគ្រប់ហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់ឲ្យសាមីខ្លួនពិនិត្យមើល បើសិនជាសាមីខ្លួនចេះអក្សរ ប៉ុន្តែបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីអត្រានុកូលដ្ឋានត្រូវអានឱ្យសាមីខ្លួនប្តីប្រពន្ធ និងសាក្សីទាំងពីរនាក់ស្តាប់គ្រប់ចំនុចទាំងអស់ បើឃើញ ថាត្រឹមត្រូវ និងឯកភាពហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវអនុវត្តដូចខាងក្រោម ៖

-ស្នាមមេដៃរបស់ប្តីប្រពន្ធ សាក្សី សាក្សី៖ ត្រូវផ្តិតមេដៃស្តាំរបស់ប្តី របស់ប្រពន្ធ របស់សាក្សីម្នាក់ៗនៅពីក្រោម និងសរសេរនាមត្រកូល និងនាមខ្លួនពីក្រោមស្នាមមេដៃរបស់ខ្លួន ។

-ធ្វើនៅថ្ងៃទី ខែឆ្នាំ៖ ត្រូវសរសេរឈ្មោះនៃឃុំ ឬសង្កាត់ទីកន្លែងដែលធ្វើអត្រានុកូលដ្ឋាន និងចុះថ្ងៃទីជាលេខខ្មែរ ខែជាអក្សរខ្មែរ និងឆ្នាំជាលេខខ្មែរ ។ ឧទាហរណ៍៖ ធ្វើនៅបាក់ខែង ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១២ ។

-មន្ត្រីអត្រានុកូលដ្ឋាន៖ ត្រូវសរសេរពីក្រោមពាក្យមន្ត្រីអត្រានុកូលដ្ឋានថា មេឃុំ ឬចៅសង្កាត់ ។

-ហត្ថលេខា និងត្រា៖ ត្រូវចុះហត្ថលេខមន្ត្រីអត្រានុកូលដ្ឋានក្រោមឋានៈនាទី សរសេរនាមត្រកូល និងនាមខ្លួន ឬបោះត្រាឈ្មោះអ្នកចុះហត្ថលេខា ពីក្រោមហត្ថលេខា រួចបោះត្រាឃុំ ឬសង្កាត់

[៨៧]សេចក្តីពិស្តារមានក្នុងឧបសម្ព័នខាងក្រោយ

ពីលើផ្នែកខាងឆ្វេងមួយភាគបីនៃហត្ថលេខា និងបោះត្រាឲ្យត្រង់តួអក្សរ (ត្រាបើទឹកពណ៌ក្រហម)[៨៨]។

### ខ.ការសរសេរនិងប្រគល់សំបុត្រអាពាហ៍ពិពាហ៍

ក្រោយពេលសរសេរចុះបញ្ជីទាំងពីរ នៃសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ទាំងពីររួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរចូលទៅក្នុងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹក ដោយប្រុងប្រយ័ត្នកុំឱ្យខុសពីខ្លឹមសារក្នុងបញ្ជីអាពាហ៍ពិពាហ៍ ដោយដកស្រង់យកចំណុចសំខាន់ៗពីបញ្ជីអាពាហ៍ពិពាហ៍មានដូចជា៖ រាជធានី ខេត្ត ,ក្រុង ស្រុក ខណ្ឌ, ឃុំ សង្កាត់,លេខនៃបញ្ជីអាពាហ៍ពិពាហ៍, សៀវភៅអាពាហ៍ពិពាហ៍លេខនៃបញ្ជីអាពាហ៍ពិពាហ៍, ឆ្នាំនៃបញ្ជីអាពាហ៍ពិពាហ៍, នាមត្រកូលប្តីប្រពន្ធ, នាមខ្លួនប្តី ប្រពន្ធ, នាមត្រកូលនិងនាមខ្លួនប្តី ប្រពន្ធជាអក្សរឡាតាំង ,សញ្ជាតិ, ថ្ងៃខែឆ្នាំកំណើតប្តីប្រពន្ធ ,ទីកន្លែងកំណើតប្តីប្រពន្ធ ,មុខរបរនិងទីលំនៅប្តីប្រពន្ធពេលចុះបញ្ជីអាពាហ៍ពិពាហ៍ ,ថ្ងៃខែឆ្នាំចុះអាពាហ៍ពិពាហ៍, ទីកន្លែងចុះអាពាហ៍ពិពាហ៍ ,នាមត្រកូលនិងនាមខ្លួនឪពុកម្តាយនិងអក្សរឡាតាំង ,សញ្ជាតិ ,ថ្ងៃខែឆ្នាំកំណើត, ធ្វើនៅ ថ្ងៃទីខែឆ្នាំ, ហត្ថលេខានិងត្រាឈ្មោះមន្ត្រីអត្រានុកូលដ្ឋាន។

ចំពោះការប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹកក្រោយពីសរសេរចុះហត្ថលេខានិងបោះត្រាលើបញ្ជីទាំងពីរ និងសំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើមមួយសន្លឹករួចហើយ ទើបមន្ត្រីអត្រានុកូលដ្ឋានត្រូវប្រគល់សំបុត្រអាពាហ៍ពិពាហ៍ច្បាប់នេះ ឲ្យទៅសាមីខ្លួនប្តីប្រពន្ធនិងណែនាំឲ្យរក្សាទុកដាក់ឲ្យបានគង់វង្ស ដើម្បីជៀសវាងការបាត់បង់ ព្រោះពុំអាចធ្វើសំបុត្រអាពាហ៍ពិពាហ៍ជាលើកទីពីរបានទេ[៨៩]។

ក្នុងករណីដែលសាមីខ្លួនប្តី ប្រពន្ធបានស្នើសុំធ្វើសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ដើមមន្ត្រីអត្រានុកូលដ្ឋានត្រូវចេញសេចក្តីចម្លងតាមការស្នើរសុំរបស់សាមីខ្លួន[៩០]។

មន្ត្រីអត្រានុកូលដ្ឋានត្រូវជម្រាបសាមីខ្លួនថា សំបុត្រអាពាហ៍ពិពាហ៍ច្បាប់ដើម គឺជាឯកសារផ្ទាល់ខ្លួនតែមួយច្បាប់ប៉ុណ្ណោះ មិនត្រូវយកទៅប្រើប្រាស់ដោយភ្ជាប់ជាមួយឯកសារណាមួយនោះ

[៨៨]កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន

[៨៩]កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន

[៩០]មាត្រា ៣១ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

ទេ ដូច្នេះគួរធ្វើសេចក្តីចម្លងដូច្នេះគួរធ្វើសេចក្តីចម្លងអាពាហ៍ពិពាហ៍ឲ្យហើយ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ ។

នៅពេលចុះសៀវភៅអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ និងធ្វើសំបុត្រអាពាហ៍ពិពាហ៍ មន្ត្រីអត្រានុកូលដ្ឋានត្រូវសរសេរដោយផ្អែកតាមខ្លឹមសារនៃសំបុត្រកំណើតនិងសំបុត្របញ្ជាក់កំណើត ។

ឧទាហរណ៍៖ នៅផ្នែកឪពុក នៅត្រង់នាមត្រកូលនិងនាមខ្លួន នៃសំបុត្រកំណើត បានសរសេរថា **មិនស្គាល់** ត្រូវសរសេរថា **មិនស្គាល់** ដូចគ្នានេះដែរ នៅផ្នែកឪពុករបស់សាមីខ្លួន ត្រង់ខ្ទង់ នាមត្រកូលនិងនាមខ្លួន នៃបញ្ជីអាពាហ៍ពិពាហ៍និងសំបុត្រអាពាហ៍[៥១]។

ការរៀបអាពាហ៍ពិពាហ៍ដោយអនុវត្តទៅតាមនីតិវិធីនៃ **ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខ មន្ត្រីអត្រានុកូលដ្ឋាន** បែបនេះទើបឈ្មោះថា ជាអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់។

### ២.រៀបការដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា អាពាហ៍ពិពាហ៍នឹងមានអានុភាពដោយ **ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន។**

ចំពោះការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសារធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ត្រូវកំណត់ទៅតាមនីតិវិធីស្តីពីការចុះបញ្ជីអត្រា-នុកូលដ្ឋាន[៥២]។

ទោះបីជាច្បាប់មានចែងជាធរមានយ៉ាងនេះក៏ដោយ ប៉ុន្តែចំពោះទិដ្ឋភាពជាក់ស្តែងនៃការរៀបអាពាហ៍ពិពាហ៍មួយចំនួននៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ការរៀបអាពាហ៍ពិពាហ៍ដោយគ្រាន់តែមានពិធីទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួនតែប៉ុណ្ណោះ ដោយពួកគេមិនបានធ្វើទៅតាមនីតិវិធីនៃច្បាប់ដូចជា **ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍** ឡើយ។

[៥១]កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន
[៥២]មាត្រា ៩៥៥ ក្រមរដ្ឋប្បវេណី ២០០៧

ការរៀបអាពាហ៍ដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រូវចាត់ទុកថាជាអាពាហ៍ពិពាហ៍ផ្ទុយនឹងច្បាប់ផង ជាអាពាហ៍ពិពាហ៍មោឃៈផង ។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងថា ប្រសិនបើភាគីប្តីនិងប្រពន្ធ **មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ទេ** អាពាហ៍ពិពាហ៍នោះនឹងត្រូវចាត់ទុកជាមោឃៈ[៩៣]។

## ក.រៀបការពីមុនមកតែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍

ចំពោះភាគីប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ពីមុនមកយូរហើយ តែពួកគាត់ពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ដោយសារតែពេលនោះពួកគាត់ពុំសូវយល់ដឹងអំពីច្បាប់ផង និងដោយសារតែពុំទាន់មានអនុក្រឹត្យស្តីពីពីអត្រានុកូលដ្ឋានផង ក្នុងករណីនេះ បើភាគីប្តីប្រពន្ធមានបំណងចង់មានសំបុត្រអាពាហ៍ពិពាហ៍ គឺពួកគាត់អាចស្នើសុំទៅមន្ត្រីអាត្រានុកូលដ្ឋាន ដើម្បីធ្វើសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍បាន ។

ដោយយោងតាមអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋានចែងថា ពលរដ្ឋខ្មែរដែលបានរស់នៅជាមួយគ្នាក្នុងស្ថានភាពជាប្តីប្រពន្ធ នៅមុនពេលដែលមានអនុក្រឹត្យអត្រានុកូលដ្ឋានថ្មីនេះចូលជាធរមាន ហើយមិនទាន់បានចុះសៀវភៅអាពាហ៍ពិពាហ៍ សាមីខ្លួនទាំងរូបអាចសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍បានតាមគំរូណែនាំថ្មីនៅសាលាឃុំឬសង្កាត់ដែលខ្លួនរស់នៅជាប់លាប់បច្ចុប្បន្ន ដោយមានសាក្សីចំនួន ០២ រូប ជានីតិជននិងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ[៩៤]។

នៅពេលមានសាមីខ្លួនប្តីនិងប្រពន្ធ មកសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នោះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍ រួចហើយត្រូវប្រគលឲ្យសាមីខ្លួនប្តីប្រពន្ធ នូវសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ច្បាប់ដើម ០១ សន្លឹក និងចេញសេចក្តីចម្លងតាមការស្នើសុំរបស់សាមីខ្លួន ដោយមានហត្ថលេខារបស់មន្ត្រីអត្រានុកូលដ្ឋានឃុំ ឬសង្កាត់[៩៥]។

នៅពេលសាមីភាគីប្តីប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ពីមុនមកហើយ ប៉ុន្តែពុំទាន់បានសុំចុះសៀវភៅអាពាហ៍ពិពាហ៍នៅឡើយ លុះដល់ពេលក្រោយមក ពួកគាត់ក៏បានទៅសុំចុះសៀវភៅ

[៩៣]មាត្រា ៩៥៨ ក្រមរដ្ឋប្បវេណី ២០០៧

[៩៤]មាត្រា ៤៥ ថ្មីនៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

[៩៥]មាត្រា ៤៦ ថ្មីនៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

បញ្ជាក់អាពាហ៍ពិពាហ៍ នៅទីកន្លែងរបស់មន្ត្រីអត្រានុកូលដ្ឋានរួចហើយ អាពាហ៍ពិពាហ៍របស់ពួកគាត់ត្រូវបានចាត់ទុកថាជាអាពាហ៍ពិពាហ៍ស្របច្បាប់ត្រឹមត្រូវតាមច្បាប់ ។

ទោះបីជាភាគីប្តីប្រពន្ធដែលរៀបអាពាហ៍ពិពាហ៍ទៅតាមពិធីប្រពៃទំនៀមទម្លាប់ ដោយមានការចូលរួមពីចាស់ទុំបងប្អូនញាតិមិត្តជឹងពួ និងការទទួលស្គាល់ពីសង្គមមនុស្សច្រើនថាជាការរៀបអាពាហ៍ពិពាហ៍ដោយត្រឹមត្រូវយ៉ាងណាក៏ដោយ ប្រសិនបើភាគីប្តីប្រពន្ធមិនបានទៅចុះសៀវភៅអាពាហ៍ពិពាហ៍ ឬសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានទេ អាពាហ៍ពិពាហ៍នេះត្រូវចាត់ទុកថាជាមោឃៈគ្មានលក្ខណៈស្របច្បាប់ឡើយ ។

ចំពោះអាពាហ៍ពិពាហ៍ដែលគ្មានការចុះសៀវភៅអាពាហ៍ពិពាហ៍ ឬសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានបែបនេះ ក្នុងករណីដែលសហព័ទ្ធប្តីឬប្រពន្ធចង់ទៅរៀបអាពាហ៍ពិពាហ៍ជាមួយភាគីផ្សេងទៀតនោះច្បាប់ពុំបានការពារដល់ភាគីទាំងពីរនោះឡើយ ។ មានន័យថា ទោះបីជាប្តីឬប្រពន្ធ ចង់រៀបអាពាហ៍ពិពាហ៍ប៉ុន្មានដងក៏បាន ចង់យកប្តីឬប្រពន្ធច្រើនក៏បាន មិនមានច្បាប់ណាហាមឃាត់ដល់ភាគីទាំងពីរឡើយ ។ ដោយសារមូលហេតុថាភាគីទាំងពីរមិនមានសំបុត្រអាពាហ៍ពិពាហ៍គ្រប់គ្រាន់តាមផ្លូវច្បាប់ ដើម្បីបញ្ជាក់ថាខ្លួនពិតជាបានរៀបការរួចហើយ ទើបធ្វើឱ្យភាគីទាំងពីរអាចរៀបការច្រើនដង ឬយកប្តីប្រពន្ធច្រើនក៏បាន ។

ការរៀបអាពាហ៍ពិពាហ៍ដោយគ្មានការចុះសៀវភៅអាពាហ៍ពិពាហ៍ ឬសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានបែបនេះ វានឹងនាំឱ្យបញ្ហាប្រឈមកើតឡើងដូចជា បញ្ហាទ្វេពន្ធភាព បញ្ហាបែងចែកទ្រព្យសម្បត្តិ បញ្ហាការលុបចោល ។

### ខ.បញ្ហាទ្វេពន្ធភាព

បញ្ហាទ្វេពន្ធភាពនឹងកើតមានឡើង ក្នុងករណីដែលភាគីប្តីប្រពន្ធបានរៀបអាពាហ៍ពិពាហ៍រួចហើយ តែភាគីប្តីប្រពន្ធមិនទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋាន ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍មួយ ដែលសហព័ទ្ធប្តីឬប្រពន្ធអាចនឹងរៀបការច្រើនដងហើយយកប្តីឬប្រពន្ធពីរឬច្រើនបាន ។

ក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជាត្រង់ជំពូកទី៣ អំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ត្រង់មាត្រា ៤៥ ចែងថា បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍និងគ្រួសារ ។ អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

ទោះបីជារដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល បានហាមឃាត់មិនឲ្យបុរស ឬស្ត្រី មានប្តីឬប្រពន្ធ ២ ឬ៣ ដូចនេះក៏ដោយ ប៉ុន្តែការរៀបអាពាហ៍ពិពាហ៍ជាក់ស្តែងមានភាគប្តីឬប្រពន្ធខ្លះ បានលួចទៅរស់

នៅហើយរៀបការជាមួយបុរសឬស្ត្រីផ្សេងមួយទៀត ដោយសារតែអាពាហ៍ពិពាហ៍ទាំងនោះមិនបានធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ដោយគ្មានការចុះសៀវភៅអាពាហ៍ពិពាហ៍ ឬសុំចុះសៀវភៅបញ្ជាក់អាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋាន ទើបជាហេតុនាំឲ្យបញ្ហាទ្វេពន្ធភាពកើតមានឡើង ដោយប្តីឬប្រពន្ធអាចរៀបការបានច្រើនដង ។

នៅក្នុងច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ២០០៦ ចែងថា ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្តីពីរ[៥៦] ។ ក្នុងករណីដែលបុរសនិងស្ត្រីបានរៀបអាពាហ៍ពិពាហ៍ហើយតែមិនទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋាន បើភាគីបុរសនិងស្ត្រីបានទៅរៀបការជាថ្មីជាមួយបុរសឬស្ត្រីផ្សេងទៀតនោះ មិនមានពិរុទ្ធក្នុងបទទ្វេពន្ធភាពឡើយ ។

ដោយក្នុងច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ ២០០៦ ចែងថា ត្រូវចាត់ទុកថាមានពិរុទ្ធភាពក្នុងបទទ្វេពន្ធភាព បុរសឬស្ត្រីណាដែលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយនៅឡើយ ហើយទៅចុះអាពាហ៍ពិពាហ៍ថ្មីមួយទៀត[៥៧]។ ម្យ៉ាងទៀតក្នុងច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ ២០០៦ ត្រង់មាត្រា ៧ ចែងថា ត្រូវចាត់ទុកថា ផិត គឺការរួមសេវនកិច្ចរវាងបុរសដែលមានចំណងអាពាហ៍ពីមុនមិនទាន់រលាយជាមួយស្ត្រីដទៃក្រៅពីប្រពន្ធរបស់ខ្លួន ឬការរួមសេវនកិច្ចរវាងស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍មិនទាន់រលាយជាមួយបុរសដទៃក្រៅពីប្តីរបស់ខ្លួន ។

ត្រូវចាត់ទុកមានពិរុទ្ធក្នុងបទផិត គឺបុរសណាដែលមានចំណងអាពាហ៍ពីមុនមិនទាន់រលាយហើយទៅរួមសេវនកិច្ចជាមួយស្ត្រីផ្សេងទៀត ។ ស្ត្រីណាដែលមានចំណងអាពាហ៍ពីមុនមិនទាន់រលាយ ហើយទៅរួមសេវនកិច្ចជាមួយប្រុសផ្សេងទៀត[៥៨]។ សម្រាប់ចំណងអាពាហ៍ពិពាហ៍ដែលមានអានុភាពទៅតាមលក្ខខណ្ឌរបស់ច្បាប់បាននោះ ទាល់តែសាមីភាគីប្តីនិងប្រពន្ធបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ ប៉ុន្តែបើសាមីភាគីប្តីនិងប្រពន្ធមិនបានទៅចុះសំបុត្រអាពាហ៍ទេ នោះគ្មានចំណងអាពាហ៍ពិពាហ៍តាមច្បាប់ឡើយ ។ ប្រសិនណាបើ ប្តីឬប្រពន្ធបានទៅរៀបការជាថ្មីជាមួយនឹងបុរសឬស្ត្រីផ្សេងទៀតនោះគឺគ្មានពិរុទ្ធក្នុងបទផិតតាមមាត្រា ៧ នៃច្បាប់ស្តីពីឯកពន្ធភាពឡើយ ។

មានន័យថា ការរៀបអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវស្របតាមច្បាប់ ទាល់តែភាគីប្តីប្រពន្ធ ត្រូវតែទៅចុះសំបុត្រអាពាហ៍ពិពាហ៍ បើមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទេ មិនមានចំណង

[៥៦]មាត្រា ៤ ច្បាប់ស្តីពី ឯកពន្ធភាព ២០០៦

[៥៧]មាត្រា ៤ ច្បាប់ស្តីពី ឯកពន្ធភាព ២០០៦

[៥៨]មាត្រា ៤ ច្បាប់ស្តីពី ឯកពន្ធភាព ២០០៦

អាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយ ភាគីប្តីឬប្រពន្ធក៏គ្មានសិទ្ធិប្តឹងដល់ភាគីណាមួយដែលបានទៅរៀបអាពាហ៍ពិពាហ៍ជាថ្មីជាមួយបុរសឬស្ត្រីផ្សេងៗនោះឡើយ ។

នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ចែងថា បុគ្គលដែលមានសហព័ទ្ធប្តីឬប្រពន្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ[៩៩] ។ ក្រមរដ្ឋប្បវេណីថ្មីនេះ មិនអនុញ្ញាតឱ្យសហព័ទ្ធ ប្តីឬប្រពន្ធរៀបអាពាហ៍ពិពាហ៍ជាថ្មីបានឡើយ បើកាលណាចំណងអាពាហ៍ពិពាហ៍ពីមុនពុំទាន់បានរលាយទេ មានន័យថា ពេលភាគីប្តីឬប្រពន្ធរៀបអាពាហ៍ពិពាហ៍ហើយទៅបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នោះចំណងអាពាហ៍ពិពិពាហ៍នឹងកើតមានឡើង ប៉ុន្តែបើភាគីបុរសនិងស្ត្រីរៀបអាពាហ៍ពិពាហ៍ហើយមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទេ គ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយ ។ ដូចនេះភាគីប្តីឬប្រពន្ធអាចទៅរៀបការជាថ្មីជាមួយនឹងបុរសឬស្ត្រីផ្សេងទៀតក៏បានដែរ ។

## +.ការចុះសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ប្តីឬប្រពន្ធចុង

ចំណងអាពាហ៍ពិពាហ៍ ដែលមានអានុភាពទៅតាមលក្ខខណ្ឌរបស់ច្បាប់បាន ទាល់តែសាមីភាគីប្តីនិងប្រពន្ធបានទៅចុះបញ្ជីសៀវភៅអាពាហ៍ពិពាហ៍ គឺមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ ប៉ុន្តែប្រសិនបើសាមីភាគីប្តីនិងប្រពន្ធដើម មិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទេ នោះគ្មានចំណងអាពាហ៍ពិពាហ៍តាមច្បាប់ឡើយ[១០០]។ ការរៀបអាពាហ៍ពិពាហ៍ដែលត្រឹមត្រូវស្របតាមច្បាប់ តម្រូវឲ្យភាគីប្តីប្រពន្ធ ត្រូវតែទៅចុះបញ្ជីសៀវភៅអាពាហ៍ពិពាហ៍ គឺមានសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវ បើមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ទេ មិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយចាត់ទុកថាជាអនីតិសង្វាស ។

នៅពេលដែលភាគីបុរស ឬស្ត្រីបានទៅរៀបអាពាហ៍ពិពាហ៍ជាថ្មី ជាមួយប្តីឬប្រពន្ធផ្សេងទៀត បើភាគីប្តីឬប្រពន្ធក្រោយនេះ បានទៅចុះសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍ នៅមន្ត្រីអត្រានុកូលដ្ឋាន ភាគីប្តីឬប្រពន្ធក្រោយនោះ ត្រូវចាត់ជាអាពាហ៍ពិពាហ៍ស្របតាមច្បាប់ ចំណែកឯបុរសនិងស្ត្រី ដែលជាភាគីប្តីឬប្រពន្ធដើម ដែលមិនចុះបញ្ជីសៀវភៅអាពាហ៍ពិពាហ៍នោះ ចាត់ទុកថាជាអាពាហ៍ពិពាហ៍មិនស្រប់ច្បាប់ ។ ភាគីប្តីឬប្រពន្ធដើម ក៏គ្មានសិទ្ធិប្តឹងដល់ភាគីណាមួយដែលបានទៅរៀបអាពាហ៍ពិពាហ៍ជាថ្មីជាមួយបុរសឬស្ត្រីផ្សេងៗនោះឡើយ ។

---

[៩៩]មាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[១០០]មាត្រា ៣០ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន

## គ.បញ្ហាការបែងចែកទ្រព្យ

ភាគីដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ត្រឹមត្រូវ វាមានភាពងាយស្រួលក្នុងការបែងចែកទ្រព្យសម្បត្តិរវាងប្តីនិងប្រពន្ធ ថាទ្រព្យដែលមាននេះជាទ្រព្យសម្បត្តិរបស់ប្តីឬជារបស់ប្រពន្ធ ពីព្រោះទ្រព្យខ្លះមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ចំណែកទ្រព្យខ្លះទៀត មាននៅក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍ ។

យោងតាមមាត្រា ៩៧២ និងមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណីថ្មីបានបែងចែកទ្រព្យសម្បត្តិដែលកាន់កាប់ក្នុង រយៈពេលមានចំណងអាពាហ៍ពិពាហ៍ជាពីរបែបគឺទ្រព្យសម្បត្តិដោយឡែក និងទ្រព្យសម្បត្តិរួម ។

### +.ទ្រព្យសម្បត្តិដោយឡែក

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលសហព័ទ្ធម្ខាងមាននៅមុខពេលរៀបអាពាហ៍ពិពាហ៍និងបានទទួលដោយ ប្រទានកម្ម សន្តតិកម្ម អច្ច័យទាន នៅក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍[១០១] ។

ទ្រព្យសម្បត្តិដោយឡែក គឺជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់សហព័ទ្ធមួយ ហើយមិនមែនជាកម្មសិទ្ធិរបស់ហាព័ទ្ធមួយទៀត [១០២]។

មាត្រា ៩៧២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា ទ្រព្យសម្បត្តិដែលកំណត់ដូចខាងក្រោមនេះ គឺជាទ្រព្យសម្បត្តិដោយឡែក ដែលស្ថិតនៅក្រោមកម្មសិទ្ធិរបស់សហព័ទ្ធណាម្នាក់៖

ក-ទ្រព្យសម្បត្តិដែលសហព័ទ្ធមាន នៅមុនពេលរៀបអាពាហ៍ពិពាហ៍ ។ សំដៅលើទ្រព្យសម្បត្តិដែលសហព័ទ្ធណាម្នាក់ មាននៅក្នុងបេតិកភណ្ឌរបស់ខ្លួន នៅខណៈពេលដែលខ្លួនរៀបអាពាហ៍ពិពាហ៍ ។

[១០១]សទ្ទានុក្រម នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[១០២]ឥន យឿន នីតិគ្រួសារនិងអាពាហ៍ពិពាហ៍

ខ.ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម[១០៣] សន្តតិកម្ម[១០៤] អច្ច័យទាន[១០៥] នៅក្នុងអំឡុងពេលចំណងអាពាហ៍ពិពាហ៍។ នៅត្រង់ចំនុច ក និងខ គឺខុសគ្នានៅត្រង់ ពេលវេលា ។

សហព័ទ្ធណាម្នាក់ គឺជាអ្នកទទួលផលប្រយោជន៍ ដូចនេះ ទ្រព្យដែលទទួលបាននឹងក្លាយជាទ្រព្យដោយឡែករបស់សហព័ទ្ធនោះ ។ ផ្ទុយទៅវិញ បើអ្នកធ្វើប្រទានកម្ម ឬសន្តតិកម្ម ឬអច្ច័យទានបានផ្តល់ឆន្ទៈឱ្យសហព័ទ្ធទាំងពីរ ជាជនទទួលផលប្រយោជន៍ ទ្រព្យសម្បត្តិដែលទទួលបាននឹងក្លាយជាទ្រព្យរួម។

គ.ទ្រព្យសម្បត្តិជាតម្លៃតបដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិខាងលើ ។ សំដៅលើទ្រព្យសម្បត្តិដែលទទួលបានក្នុងពេលរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពីអំពើដែលមានមុនពេលរៀបអាពាហ៍ពិពាហ៍ ដូចគ្នាដែរ ចំពោះទ្រព្យសម្បត្តិទទួលបាន ក្នុងពេលរៀបអាពាហ៍ពិពាហ៍ដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌកំណត់ ។

ត្រូវចាត់ទុកជាទ្រព្យដោយឡែក ចំពោះទ្រព្យដែលទទួលបាន ក្នុងពេលរៀបអាពាហ៍ពិពាហ៍ដោយសារជាបណ្តឹងជាសិទ្ធិរបស់សហព័ទ្ធម្ខាង មុនពេលរៀបអាពាហ៍ពិពាហ៍ ។

**+.ទ្រព្យសម្បត្តិរួម**

**ទ្រព្យសម្បត្តិរួម** គឺជាទ្រព្យសម្បត្តិដែលប្តីប្រពន្ធជាម្ចាស់កម្មសិទ្ធិរួមគ្នា ។ ម្យ៉ាងទៀត គឺជាទ្រព្យសម្បត្តិទាំងឡាយ ដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាង ទទួលបានក្នុងពេលអាពាហ៍ពិពាហ៍ លើកលែងតែង ទ្រព្យសម្បត្តិដែលកំណត់ចំនុច ខ និងគ នៃមាត្រា ៩៧២ ទ្រព្យដោយឡែក ។

ទ្រព្យសម្បត្តិទទួលបានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ ដោយការងាររបស់សហព័ទ្ធចំពោះការងាររបស់សហព័ទ្ធ រាល់សកម្មភាពទាំងអស់ ទោះជាសកម្មភាពម្តងម្កាល សកម្មភាពវិជ្ជាជីវៈ ហត្ថកម្ម ឬបញ្ញា ។ ប្រាក់ខែជាទ្រព្យរួម ប្រាក់បំណាច់បានពីការងារ ប្រាក់បំណាច់បំណ្តេញចេញពីការងារ ប្រាក់ សម្រាប់គ្រោះថ្នាក់ការងារ ។

---

[១០៣]**ប្រទានកម្ម ឬអំណោយ** សំដៅដល់ កិច្ចសន្យាដែលភាគីម្ខាងសន្យាឲ្យភាគីម្ខាងទៀតនូវទ្រព្យសម្បត្តិដោយមិនយកកម្រៃ ជាកិច្ចសន្យាផ្ទេរកម្មសិទ្ធិដោយមុធា ។

[១០៤]**សន្តតិកម្ម** សំដៅដល់ ការផ្ទេរនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនទៅឲ្យជនម្នាក់ឬច្រើននាក់ ដូចជា មនុស្សម្នាក់ទទួលផ្ទះ និងដីធ្លីជាមរតក ម្យ៉ាងទៀត គឺជាការផ្ទេរនូវទ្រព្យសម្បត្តិរបស់អ្នកស្លាប់ ដែលហៅថា មតកជន ទៅឲ្យទាយាទ ដែលហៅថា សន្តតិជន តាមការកំណត់របស់ច្បាប់ ឬតាមបណ្តាំ ។

[១០៥]**អច្ច័យទាន** សំដៅដល់ ប្រទានកម្មដែលម្ចាស់បណ្តាំធ្វើទៅឲ្យមនុស្សម្នាក់ ឬច្រើននាក់នូវទ្រព្យសម្បត្តិរបស់ខ្លួនតាមរយៈមរតកសាសន៍ ជាទ្រព្យដែលទទួលបានតាមរយៈមតកសាសន៍ (បណ្តាំមរតក) ។

រាល់ទ្រព្យសម្បត្តិដែលទទួលបានដោយមូលា (ប្រាក់កម្រៃ) ក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវសន្មតថាជាទ្រព្យរួម ។ សហាព័ទ្ធដែលអះអាងថាជាទ្រព្យដោយឡែករបស់ខ្លួនត្រូវទទួលក្នុងការបញ្ជាក់ បង្ហាញភស្តុតាង[១០៦]។

ចំពោះបញ្ហាទ្រព្យសម្បត្តិ អាចនឹងកើតមានឡើងក្នុងករណីដែលសហាព័ទ្ធភាគីប្ដីឬប្រពន្ធបានរៀបអាពាហ៍ពិពាហ៍ហើយ ប៉ុន្តែមិនបានទៅចុះបញ្ជីសៀវភៅអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុដ្ឋាន ពីព្រោះថានៅពេលណាដែលសហាព័ទ្ធប្ដីឬប្រពន្ធ លួចលាក់ទៅរៀបអាពាហ៍ពិពាហ៍ថ្មី ហើយបានចុះបញ្ជីសៀវភៅអាពាហ៍ពិពាហ៍ជាមួយសហាព័ទ្ធប្ដីឬប្រពន្ធផ្សេងទៀតនោះ នៅពេលមានបញ្ហាប្ដឹងផ្ដល់កើតឡើងនាំឲ្យមានបញ្ហាស្មុគស្មាញក្នុងការដោះស្រាយ អំពីការបែងទ្រព្យសម្បត្តិរបស់ប្ដីប្រពន្ធដើមដែលគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ជាមួយនឹងប្ដីប្រពន្ធចុងដែលមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ។

### ឃ.បញ្ហាមោឃៈឬការលុបចោល

ចំពោះអាពាហ៍ពិពាហ៍ ដែលធ្វើឡើងដោយគ្រាន់តែមានវិធីរៀបមង្គលការតាមទំនៀមទម្លាប់របស់អ្នកស្រុកអ្នកភូមិ ដោយមានការចូលរួមពីញាតិមិត្តបងប្អូនភ្ញៀវកត្តិយសច្រើនកុះករយ៉ាងនេះក៏ដោយ ប៉ុន្តែបើការរៀបអាពាហ៍ពិពាហ៍របស់ពួកគេមិនបានធ្វើទៅតាមនីតិវិធីនៃច្បាប់ដូចជា **ការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន និងមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍** ដូចនេះអាពាហ៍ពិពាហ៍នោះ **ចាត់ទុកថាជាអាពាហ៍ពិពាហ៍មិនស្រប់ច្បាប់ ។** សម្រាប់អាពាហ៍ពិពាហ៍ដែលមិនបានបំពេញតាមលក្ខខណ្ឌច្បាប់តម្រូវ ហេតុដូចនេះនាំឱ្យមានផលវិបាកមួយចំនួនចំពោះអាពាហ៍ពិពាហ៍ពោល គឺអាពាហ៍ពិពាហ៍ទុកជាមោឃៈ ឬការលុបអាពាហ៍ពិពាហ៍ ។

#### +.បញ្ហាមោឃៈ

ដោយយោងតាមមាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានចែងអំពីមោឃភាពនៃអាពាហ៍ពិពាហ៍ដែលមិនបានបំពេញតាមលក្ខខណ្ឌច្បាប់ដោយច្បាប់បានចែងថា៖

ប្រសិនបើភាគី មិនបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ អាពាហ៍នឹងត្រូវចាត់ទុកជាមោឃៈ ។

---

[១០៦]សាស្ត្រាចារ្យ ខៀវ សុផានី នីតិបេតិកភ័ណ្ឌគ្រួសារ ឆ្នាំ ២០១៩

ហេតុនេះចំពោះភាគីសហព័ទ្ធប្តីប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ត្រូវតែទៅដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ទើបអាពាហ៍ពិពាហ៍ចាត់ទុកថាត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់ ។

ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណីក៏បានកំណត់ដែរថា ប្រសិនបើគ្រាន់តែមានវិការៈតែបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះទេ អានុភាពនៃអាពាហ៍ពិពាហ៍ពិពាហ៍នេះ មិនត្រូវបានរារាំងដោយសារហេតុនេះឡើយ[១០៧]។ មានន័យថា ភាគីដែលបានរៀបអាពាហ៍ពិពាហ៍ មិនបានបំពេញតាមទម្រង់ច្បាប់មួយចំនួន នាំឱ្យអាពាហ៍ពិពាហ៍ចាត់ទុកជាមោឃៈក៏បាន ឬអាចបន្តអនុវត្តក៏បាន ហៅថា មោឃភាពមិនដាច់ខាតនៃ អាពាហ៍ពិពាហ៍ ដោយសារតែកំហុសមិនមានលក្ខណធ្ងន់ធ្ងរ ពីព្រោះនៅក្នុងសង្គមកម្ពុជាជាក់ស្តែង ភាគីប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ហើយ តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍មានច្រើន ទាំងនេះហើយជាហេតុនាំឱ្យបញ្ហាប្រឈមកើតមាន ។

ដូចនេះចំពោះភាគីសហព័ទ្ធឬប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍ ត្រូវតែទៅដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ទើបអាពាហ៍ពិពាហ៍មិនមានបញ្ហាប្រឈមផ្ទុយនឹងច្បាប់ ។

**+.បញ្ហាការលុបចោល**

ក្នុងមាត្រា ៩៥៩-៩៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងអំពីការលុបចោលអាពាហ៍ពិពាហ៍ដែលមិនបានបំពេញតាមលក្ខខណ្ឌច្បាប់ដោយច្បាប់បានចែងថាៈ

អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិច្បាប់ ញាតិសន្តានរបស់នោះ ឬតំណាងអយ្យការអាចទាមទារទៅតុលាការឲ្យលុបចោលបាន ។ អាពាហ៍ពិពាហ៍ដែលបានធ្វើផ្ទុយនឹងបញ្ញត្តិច្បាប់នោះមានដូចជាៈ អាពាហ៍ពិពាហ៍មិនគ្រប់អាយុ (មាត្រា៩៤៨),ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងលោហិតឬញាតិពន្ធ (មាត្រា៩៥២),ការមានទ្វេពន្ធភាព (មាត្រា៩៤៩), អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី (មាត្រា៩៥០),អាពាហ៍ពិពាហ៍ដោយការឆបោកឬការគំរាម (មាត្រា៩៦៣), ។

ការមានទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធពីរ ឯស្ត្រីមានប្តីពីរ នៅក្នុងច្បាប់ស្តីពីឯកពន្ធភាពឆ្នាំ ២០០៦ ចែងថា ទ្វេពន្ធភាពជាចំណងអាពាហ៍ពិពាហ៍ដែលបុរសមានប្រពន្ធ

[១០៧] មាត្រា ៩៥៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ពីរ ឯស្ត្រីមានប្តីពីរ[១០៨]។ មានន័យថា ប្តីប្រពន្ធបានរៀបអាពាហ៍ពិពាហ៍តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍តាមនីតិវិធីច្បាប់ទេ ដូចនេះមិនមានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ឡើយ ហើយបុគ្គលជាប្តីឬប្រពន្ធ ឬញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ មិនអាចទាមទារទៅតុលាការឱ្យលុបចោលនូវអាពាហ៍ពិពាហ៍នោះបានឡើយ ។

ប៉ុន្តែចំពោះភាគីសហព័ទ្ធប្តីប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍ហើយបានទៅដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ ឬមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ទើបអាពាហ៍ពិពាហ៍ចាត់ទុកថាត្រឹមត្រូវតាមលក្ខខណ្ឌច្បាប់ ។

អាពាហ៍ពិពាហ៍ដែលបានធ្វើឡើងទៅតាមនីតិវិធីច្បាប់ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍រួចហើយបែបនេះ ចាត់ទុកថាជាអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ក្នុងករណីដែលសហព័ទ្ធប្តីឬប្រពន្ធណាម្នាក់ បានទៅរៀបអាពាហ៍ពិពាហ៍ថ្មីជាមួយនឹងភាគីប្តីឬប្រពន្ធផ្សេងទៀត ដោយមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់អស់សុពលភាពលនៅឡើយ (មិនទាន់លែងលះគ្នា) ដូចនេះបុគ្គលជាប្តីឬប្រពន្ធដើម ឬញាតិសន្តានរបស់ជននោះ ឬតំណាងអយ្យការ អាចទាមទារទៅតុលាការឲ្យលុបចោលនូវអាពាហ៍ពិពាហ៍នោះបាន ។

ទាំងនេះហើយជាបញ្ហាប្រឈម ចំពោះបុគ្គលដែលបានរៀបអាពាហ៍ពិពាហ៍ហើយតែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍តាមនីតិវិធីច្បាប់ ។

## កថាខណ្ឌទី៦៖ បញ្ហាចូលសញ្ជាតិដោយអាពាហ៍ពិពាហ៍

### ១.និយមន័យ

**សញ្ជាតិខ្មែរ** សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា ។

**ការទាមទារសញ្ជាតិខ្មែរ** សំដៅដល់សិទ្ធិក្នុងការស្នើសុំសញ្ជាតិខ្មែរ ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍រវាងជនជាតិបរទេសនិងប្រជាពលរដ្ឋខ្មែរ[១០៩] ។

### ២.បញ្ហាចង់បានសញ្ជាតិខ្មែរ

នៅក្នុងច្បាប់របស់ព្រះរាជាណាកម្ពុជា ក៏បានអនុញ្ញាតិឱ្យប្រជាពលរដ្ឋខ្មែរនិងជនបរទេសអាចរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នាបានដែរ ចំពោះនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ យើងខ្ញុំបានធ្វើ

[១០៨]មាត្រា ៤ ច្បាប់ស្តីពី ឯកពន្ធភាព ២០០៦

[១០៩] មាត្រា ១១ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨

ការបកស្រាយរួចហើយក្នុងជំពូកទី១ ត្រង់ផ្នែកទី៣ ។ ចំពោះការរៀបអាពាហ៍ពិពាហ៍នៃជនបរទេសខ្លះមានសុចរិតត្រឹមត្រូវគឺស្រឡាញ់ស្មោះត្រង់ជាមួយនឹងប្រជាពលរដ្ឋខ្មែរពិតប្រាកដ ប៉ុន្តែសម្រាប់ជនបរទេសមួយចំនួន ដែលរៀបអាពាហ៍ពិពាហ៍ជាមួយប្រជាពលរដ្ឋខ្មែរ ដើម្បីចង់បានសញ្ជាតិខ្មែរប៉ុណ្ណោះ លុះដល់ការកំណត់នៃទាមទារសិទ្ធិ ដើម្បីចូលសញ្ជាតិខ្មែរ ជនបរទេសនោះក៏បានលែងលះភាគីប្តីឬប្រពន្ធជាប្រជាពលរដ្ឋខ្មែរ ។ ច្បាប់ក៏បានចែងដែរថា ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ត្រូវធ្វើសម្បថ[១១០] នៅចំពោះមុខតុលាការកំពូល[១១១] ។ ប៉ុន្តែច្បាប់មិនបានចែងហាមឃាត់មិនឱ្យធ្វើការលែងលះគ្នានោះឡើយ ។ ហេតុនេះការចូលសញ្ជាតិដោយអាពាហ៍ពិពាហ៍ក៏ជាបញ្ហាប្រឈមមួយដែរ នៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ។

ប្រជាពលរដ្ឋខ្មែរនិងជនបរទេសជាបុរសឬស្ត្រី ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងគ្នារួចហើយនោះ ចំពោះជនបរទេសក៏អាចអាចទាមទារសញ្ជាតិខ្មែរបានផងដែរ ក្នុងករណីស្ត្រីឬបុរសនោះរស់នៅជាមួយគ្នាអស់រយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយយោងតាមច្បាប់ស្តីពីសញ្ជាតិត្រង់ជំពូកទី៥ សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ចែងថាស្ត្រីឬបុរស បរទេសដែលយកប្តី ឬប្រពន្ធពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រីឬបុរសនោះរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា[១១២] ។ ក្នុងន័យនេះចង់បញ្ជាក់ថា ជនបរទេសជាស្ត្រីឬបុរសដែលយកប្តី ឬប្រពន្ធជាពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន ក្នុងករណីដែលស្ត្រីឬបុរសនោះរស់

[១១០] ខ្លឹមសារនៃសម្បថក្នុងមាត្រា ៩ នៃអនុក្រឹត្យស្តីពីបែបបទ-និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរមានដូចតទៅៈ
-ខ្ញុំសូមសច្ចាជាឱឡារិកថា ខ្ញុំមានភក្តីភាពនិងស្នេហាចំពោះមាតុភូមិកម្ពុជារបស់ខ្ញុំ ហើយប្តេជ្ញាធ្វើពលីកម្មគ្រប់បែបយ៉ាងដើម្បីការពារនិងគោរពរដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត ។
-ខ្ញុំសូមប្តេជ្ញាជាឱឡារិកថានឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់យ៉ាង ដើម្បីចូលរួមចំណែកក្នុងការការពារ ខឿនឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត ។
[១១១] មាត្រា ១៦ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨
[១១២] មាត្រា ១១ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨

នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់ក៏បានអនុញ្ញាតផងដែរថា អាចឲ្យជនបរទេសសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្ដាយ ឬឪពុកដែលមានកូនជាអនីតិជន[១១៣] ។

ចំពោះករណីដែលភាគីប្ដីនិងប្រពន្ធបានរៀបអាពាហ៍ពិពាហ៍រួចហើយ ថែមទាំងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់រួចហើយផងដែរ ប៉ុន្តែនៅក្រោយពេលភាគីប្ដីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍រួចនោះ បានស្នាក់នៅក្នុងប្រទេសកម្ពុជារយៈពេលតែ ១ ឆ្នាំប៉ុណ្ណោះ ភាគីប្ដីប្រពន្ធនោះក៏បានទៅរស់នៅឯបរទេស ហេតុនេះជនបរទេសជាបុរសឬស្ត្រីនោះ ពុំមានសិទ្ធិទាមទារសញ្ជាតិខ្មែរបានឡើយ ។

### ៣.លក្ខខណ្ឌចូលសញ្ជាតិដោយអាពាហ៍ពិពាហ៍

ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

-មានគំនិតមារយាទនិងសីលធម៌ល្អ

-ពុំដែលមានទោសពីបទឧក្រិដ្ឋឬមជ្ឈិមណាមួយ

-មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ។

-ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិខ្មែរខ្លះៗ

-មានបញ្ញានិកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ[១១៤] ។

### ៤.ការបាត់សញ្ជាតិខ្មែរ

ចំពោះបុគ្គលដែលមានសញ្ជាតិខ្មែរហើយ ពុំមែនបាត់បង់សញ្ជាតិដោយសារការទៅរស់នៅឯបរទេសនោះឡើយ ព្រោះច្បាប់បានចែងថា ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារគ្រប់មធ្យោបាយការទូត មិនអាចបាត់សញ្ជាតិដោយឯកឯងទេ[១១៥] ឬម្យ៉ាងទៀត ពុំមែន

---

[១១៣] មាត្រា ១១ នៃច្បាប់ស្ដីពីសញ្ជាតិ ឆ្នាំ ២០១៨

[១១៤] មាត្រា ១២ នៃច្បាប់ស្ដីពីសញ្ជាតិ ឆ្នាំ ២០១៨

[១១៥] មាត្រា ៨ នៃច្បាប់ស្ដីពីសញ្ជាតិ ឆ្នាំ ២០១៨

បាត់បង់សញ្ជាតិដោយសារការរៀបអាពាហ៍ពិពាហ៍ ជាមួយនឹងជនបរទេសទេឬ មានការលែងលះផ្តាច់ចំណងអាពាហ៍ពិពាហ៍ក៏មិនបាត់បង់សញ្ជាតិនោះដែរ[១១៦]។

ការបាត់បង់សញ្ជាតិក្នុងករណីដែលជននោះ **សុំលះបង់សញ្ជាតិខ្មែរដោយខ្លួនឯង** ដោយពុំមានការបង្ខិតបង្ខំពីជនណាមួយឡើយ ។ យោងតាមច្បាប់ស្តីពីសញ្ជាតិចែងថា ជនណាដែលមានសញ្ជាតិខ្មែរហើយ មានអាយុ ១៨ឆ្នាំ យ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតនិងដោយគ្មានដោយការបង្ខិតបង្ខំ ។ ត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ពលរដ្ឋខ្មែរជាម្តាយ ឬឪពុកដែលមានកូនជាអនីតិ-ជន[១១៧]។

ការរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសជាមួយនឹងប្រជាពលរដ្ឋខ្មែរ ដើម្បីចង់ទទួលបានសញ្ជាតិខ្មែរទាំងនេះហើយ ដែលជាបញ្ហាប្រឈមនៃអាពាហ៍ពិពាហ៍នៅកម្ពុជាបច្ចុប្បន្ន ។

[១១៦] មាត្រា ១៧ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨

[១១៧] មាត្រា ២៨ នៃច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាននិងអនុសាសន៍

## ១-សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី អាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន រួចមកយើងអាចសន្និដ្ឋានបានថា អាពាហ៍ពិពាហ៍ គឺជាកិច្ចសន្យាដ៏ឧឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញតាមទំនើងចិត្តរបស់ខ្លួនឡើយ ។ អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍ធ្វើឡើងស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ ។ មានន័យថាចំណងអាពាហ៍ពិពាហ៍ពិពាហ៍ដែលត្រឹមត្រូវតាមច្បាប់ នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន ភាគីដែលរៀបអាពាហ៍ពិពាហ៍ត្រូវធ្វើឡើង ទៅតាមគោលការណ៍នីតិវិធីស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ មិនមែនរៀបអាពាហ៍ពិពាហ៍ទៅតាមប្រពៃទំនៀមទម្លាប់ដោយគ្រាន់តែមានរៀបចំពិធីជប់លៀងអញ្ជើញភ្ញៀវចូលរួមក្នុងពីធីប៉ុណ្ណោះទេ ។ ដោយយោងតាមក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចែងថា អាពាហ៍ពិពាហ៍នឹងមានអានុភាព ដោយការដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ។ នៅច្បាប់ក៏បានចែងទៀតថា ចំពោះភាគីបុរស និងស្ត្រី ដែលដល់នីតិភាពមានអាយុពេញវ័យគ្រប់ការតាមច្បាប់កំណត់ ហើយមានបំណងចង់រៀបអាពាហ៍ពិពាហ៍ ភាគីបុរសនិងស្ត្រីអាចជ្រើសរើសយកបុរសជាប្តី ឬស្ត្រីជាប្រពន្ធដោយគោលការណ៍ស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំពីអ្នកដទៃឡើយ គឺមានសេរីភាពគ្រប់គ្រាន់ក្នុងការជ្រើសរើសគូស្រករបាន ។

ទោះបីជាច្បាប់អនុញ្ញាតឲ្យភាគីបុរសនិងស្ត្រីអាចជ្រើសរើសយកប្តី ឬប្រពន្ធដោយគោលការណ៍ស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំពីអ្នកដទៃ ដោយមានសេរីភាពគ្រប់គ្រាន់ក្នុងការបង្ហាញឆន្ទៈជ្រើសរើសគូស្រករក៏ដោយ ប៉ុន្តែចំពោះការរៀបអាពាហ៍ពិពាហ៍មួយចំនួនត្រូវច្បាប់ហាមឃាត់ដូចជាអាពាហ៍ពិពាហ៍មានភេទដូចគ្នា ជនវិកលចរិតមិនដឹងខុសត្រូវ បុគ្គលមានចំណងអាពាហ៍ពិពាហ៍ពីមុនមិនទាន់រលាយ អាពាហ៍ពិពាហ៍រវាងចំណងញាតិលោហិតឬញាតិពន្ធ អាពាហ៍ពិពាហ៍ដោយការឆបោកបន្លំ ។

ក្នុងសង្គមកម្ពុជាបច្ចុប្បន្ននីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍របស់ប្រជាពលរដ្ឋមួយចំនួន មិនបានធ្វើទៅតាមនីតិវិធីដែលច្បាប់បានកំណត់ឡើយ ដោយសារពួកគាត់ពុំសូវបានយល់ដឹងអំពីច្បាប់ផង ណាមួយការរៀបអាពាហ៍ពិពាហ៍នោះច្រើនតែធ្វើទៅតាមប្រពៃណីទំនៀមទម្លាប់ ដោយការរៀបចំជាកម្មវិធីអញ្ជើញភ្ញៀវចូលរួមប៉ុណ្ណោះ ពួកគាត់ពុំបានចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខ

មន្ត្រីអត្រានុកូលដ្ឋានទេ អាពាហ៍ពិពាហ៍បែបនេះពុំមានអានុភាពឡើយ ។ម្យ៉ាងទៀតការរៀបអាពាហ៍ពិពាហ៍ខ្លះ កើតឡើងដោយការបង្ខិតបង្ខំពីអ្នកដទៃឬឪពុកម្តាយឬអាណាព្យាបាល អាពាហ៍ពិពាហ៍រវាងចំណងញាតិលោហិតឬញាតិពន្ធ អាពាហ៍ពិពាហ៍ភេទដូចគ្នាជាដើម ក្នុងការរៀបអាពាហ៍ពិពាហ៍ដោយមានការរៀបចំពិធីអធិកអធមចំណាយទ្រព្យសម្បត្តិអស់ច្រើន និងមានភ្ញៀវចូលរួមហើយមានញាតិមិត្តបងប្អូនទទួលស្គាល់ថាជាប្តីប្រពន្ធ ដែលបានរៀបអាពាហ៍ពិពាហ៍យ៉ាងនេះក៏ដោយ ប៉ុន្តែសម្រាប់គោលការណ៍ច្បាប់មិនទទួលស្គាល់ថាជាអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ទេ នៅក្នុងករណីដែលភាគីបុរសជាប្តីនិងស្ត្រីជាប្រពន្ធទៅសុំចុះបញ្ជីអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន អាជ្ញាធរឃុំឬសង្កាត់មិនចុះបញ្ជីអាពាហ៍ពិពាហ៍និងចេញសំបុត្រអាពាហ៍-ពិពាហ៍ឱ្យសាមីភាគីប្តីនិងប្រពន្ធឡើយ ។

ចំពោះអាពាហ៍ពិពាហ៍ដែលបង្កើតឡើងដោយមិនបាន ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍ អាពាហ៍ពិពាហ៍ដោយការបង្ខិតបង្ខំពីអ្នកដទៃឬឪពុកម្តាយឬអាណាព្យាបាល អាពាហ៍ពិពាហ៍រវាងចំណងញាតិលោហិតឬញាតិពន្ធ អាពាហ៍ពិពាហ៍ភេទដូចគ្នា ទាំងនេះហើយដែលជាបញ្ហាប្រឈមក្នុងសង្គមកម្ពុជាបច្ចុប្បន្ន ។

សរុបសេចក្តីមក ប្រធានបទមួយនេះយើងខ្ញុំបានសិក្សាស្វែងយល់អំពីអាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្ន ព្រោះថាមានអាពាហ៍ពិពាហ៍មួយចំនួនកំពុងតែមានបញ្ហាប្រឈមកើតឡើង ដោយសារខ្វះការយលដឹង និងការអនុវត្តច្បាប់នៅមានភាពខ្វះចន្លោះ ដើម្បីឲ្យការរៀបអាពាហ៍ពិពាហ៍មួយមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងឲ្យស្របតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ មានលក្ខខណ្ឌទម្រង់ត្រឹមត្រូវនៃអាពាហ៍ពិពាហ៍ ។

# អនុសាសន៍

## ២-អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវទៅលើប្រធានស្តីពី អាពាហ៍ពិពាហ៍និងបញ្ហាប្រឈមនៅកម្ពុជាបច្ចុប្បន្នរួចមកយើងខ្ញុំឃើញថា ការរៀបអាពាហ៍ពិពាហ៍និងការអនុវត្តច្បាប់ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នគឺមានភាពខ្វះចន្លោះនៅឡើយ ដែលជាមូលហេតុនាំឲ្យមានបញ្ហាប្រឈមនៃការរៀបអាពាហ៍ពិពាហ៍កើតឡើង ដូចនេះយើងខ្ញុំសូមធ្វើការផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីចូលរួមផ្តល់ជាគំនិតក្នុងការសិក្សាឈ្វេងយល់បន្ថែមដូចតទៅៈ

-ពង្រឹងការអនុវត្តច្បាប់នានាជាពិសេសក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ និងអនុក្រឹត្យស្តីពីអាត្រានុកូលដ្ឋានឲ្យបានរឹងមាំ នៅតាមមូលដ្ឋានថ្នាក់ឃុំសង្កាត់ ឬស្រុក ខណ្ឌ ឬ ខេត្ត រាជធានី ។

-ត្រូវផ្សព្វផ្សាយ អំពីបញ្ហានៃការរៀបអាពាហ៍ពិពាហ៍និងអំពីលក្ខខណ្ឌក្នុងរៀបអាពាហ៍ពិពាហ៍ឲ្យបានច្រើន ។

-ប្រជាពលរដ្ឋគ្រប់រូបជាពិសេសភាគីបុរសនិងស្ត្រី ដែលមានបំណងចង់រៀបអាពាហ៍ពិពាហ៍ជាមួយគ្នា មិនត្រូវរៀបអាពាហ៍ពិពាហ៍ដោយគ្រាន់តែមានពិធីតាមប្រពៃណីទំនៀមទម្លាប់តែមួយមុខប៉ុណ្ណោះទេ គឺត្រូវតែអនុវត្តទៅតាមនីតិវិធីច្បាប់បន្ថែមមួយទៀត មានន័យថាភាគីបុរសនិងនារីត្រូវតែ **ដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ការជូនដំណឹងជាសាធារណៈ ការចុះកិច្ចសន្យាអាពាហ៍ពិពាហ៍ និងការចុះបញ្ជីអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ពីព្រោះដើម្បីឱ្យអាពាហ៍ពិពាហ៍នោះត្រឹមត្រូវតាមការកំណត់របស់ច្បាប់។**

-ចំពោះឪពុកម្តាយគ្រប់រូប ឬអាណាព្យាបាល មិនត្រូវបង្ខិតបង្ខំឬគំរាមកំហែងកូន ដើម្បីឱ្យរៀបអាពាហ៍ពិពាហ៍ដោយគ្មានការស្ម័គ្រចិត្តឬបង្ហាញឆន្ទៈយល់ព្រមពីកូនឡើយ ត្រូវតែមានការបង្ហាញឆន្ទៈយល់ព្រមពីកូនសិនទើបអាពាហ៍ពិពាហ៍ត្រឹមត្រូវស្របតាមច្បាប់ ហើយគ្រួសារអាចរស់នៅជាមួយគ្នាដោយមានសុភមង្គលព្រោះមានការស្រឡាញ់គ្នាទៅវិញទៅមក។

-មុននឹងរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុគ្គលណាម្នាក់ភាគីបុរសឬស្ត្រី ត្រូវសិក្សាឱ្យបានច្បាស់លាស់អំពីជីវប្រវត្តិ អត្តចរិត ការយល់ដឹងរបស់ភាគី និងត្រូវសិក្សាឈ្វេងយល់ឱ្យបានច្បាស់អំពីបញ្ហាច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងអនុក្រឹត្យស្តីពីអាត្រានុកូលដ្ឋាន ព្រមទាំងបទដ្ឋានគតិយុត្តនានាផ្សេងទៀតដែលមានចែងធរមាន។

# ឯកសារយោង

# ឯកសារយោង

## ក.លិខិតបទដ្ឋានគតិយុត្ត

### ១.រដ្ឋធម្មនុញ្ញ

-រដ្ឋធម្មនុញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣ ។

### ២.លិខិតបទដ្ឋានអន្តរជាតិ

១.អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ របស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៦៩ ។

២. ច្បាប់សិទ្ធិមនុស្សកម្ពុជា ឆ្នាំ២០១២

៣.កតិកាសញ្ញាអន្តរជាតិ ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយ

៤.អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ១៩៧៩ របស់មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ចូលជាធរមាននៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៨១ ។

### ៣.ក្រម

១.ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

២.ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

៣.ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។

### ៤.ច្បាប់

១.ច្បាប់ស្តីពី ឯកពន្ធភាព ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១០០៦/០២៦ ចុះថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៦ ។

២.ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ៥៦ ក្រ ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៨៩ ។

៣.ច្បាប់ស្តីពី សញ្ជាតិ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨ ។

**៥.បទបញ្ញា**

១.អនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ។

២.អនុក្រឹត្យលេខ ១០៣ អនក្រ.បក, ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន ដែលត្រូវបានកែសម្រួលដោយអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ និងអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៤ ។

៣.អនុក្រឹត្យលេខ ២៨៦ អនក្រ.បក, ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីបែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ។

**ខ.ឯកសារស្រាវជ្រាវ**

១.ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីភាគទី២ សមិទ្ធផលរបស់ប្រព័ន្ធគម្រោងអភិវឌ្ឍន៍ប្រពន្ធច្បាប់និងតុលាការ ។

២.ក្រសួងមហាផ្ទៃ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម កម្រងឯកសារស្តីពីរបៀបកត់ត្រាការងារអត្រានុកូលដ្ឋាន ឆ្នាំ២០១២ ។

៣.លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងលោកស្រីសាស្ត្រាចារ្យ ចាង ស៊ីណាត "នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ" ឆ្នាំ២០១៧ ។

៤.ឯកឧត្តម ឥន យឿន "នីតិគ្រួសារនិងអាពាហ៍ពិពាហ៍ភាគទី០១" ឆ្នាំ២០១៣ ។

៥.លោកសាស្ត្រាចារ្យ អម សុផាណារ៉ាត "សៀវភៅនីតិរដ្ឋប្បវេណី" ឆ្នាំ២០១៤-២០១៥ ។

៦.សាស្ត្រាចារ្យ ខៀវ សុផានី នីតិបេតិកភ័ណ្ឌគ្រួសារ ឆ្នាំ២០១៩

៧. https://khmer.voanews.com/a/cambodian

៨. http://cambodia.ohchr.org/kh

៩. http://RFI KHMER.COM

១០.សម្តេចព្រះសង្ឃរាជ ជួន ណាត វចនានុក្រមខ្មែរ បោះពុម្ពលើកទី៥ ឆ្នាំ១៩៦៧

១១.សៀវភៅ "អរិយធម៌ខ្មែរ" ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកវិទ្យាស្ថានភាសាបរទេស សម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឆ្នាំ២០១៣ ។

# ឧបសម្ពន្ធ

# បញ្ជីឧបសម្ព័ន្ធ

| ល.រ. | ឈ្មោះឯកសារ |
|---|---|
| ១. | អត្រានុកូលដ្ឋានស្តីពីកំណើត ឆ្នាំ២០១២ |
| ២. | អត្រានុកូលដ្ឋានស្តីពីអាពាហ៍ពិពាហ៍ ឆ្នាំ២០១២ |
| ៣. | អត្រានុកូលដ្ឋានស្តីពីមរណភាព ឆ្នាំ២០១២ |
| ៤. | សាលក្រម |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានី ខេត្ត ៖---------------
ក្រុង ស្រុក ខណ្ឌ ៖---------------
ឃុំ សង្កាត់ ៖----------------
ភូមិ ៖----------------

ថ្ងៃទី------ ខែ---------- ឆ្នាំ-------

## លិខិតបញ្ជាក់ទទួលស្គាល់កំណើត

យើង-------------------- ជាមេភូមិ-------------------- នៃឃុំ សង្កាត់-------------------- ក្រុង ស្រុក ខណ្ឌ--------------- រាជធានី ខេត្ត ------------ សូមបញ្ជាក់ថា (នាមត្រកូល-នាមខ្លួនទារក)---------------------- ភេទ----- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ នៅផ្ទះលេខ-------- ផ្លូវលេខ--------- ក្រុមទី------- ភូមិ-------- ឃុំ សង្កាត់----------- ក្រុង ស្រុក ខណ្ឌ------------ រាជធានី ខេត្ត ------------- ឪពុកឈ្មោះ--------------------- កើតនៅថ្ងៃទី----- ខែ--------- ឆ្នាំ------ ម្ដាយឈ្មោះ----------------- កើតនៅថ្ងៃទី------ ខែ---------ឆ្នាំ--------- មានទីលំនៅបច្ចុប្បន្ននៅភូមិ---------------- ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ--------------------- រាជធានី ខេត្ត ------------- ពិតជាបានកើតនៅផ្ទះ ប្រាកដមែន ដែលមានឆ្មបបង្កើតឈ្មោះ------------------------ ភេទ------- ឆ្នាំកំណើត--------- មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ---------- ផ្លូវលេខ ---------- ក្រុមទី ---------- ភូមិ------------------ឃុំ សង្កាត់------------------ ក្រុង ស្រុក ខណ្ឌ------------------ រាជធានី ខេត្ត ---------។

"លិខិតបញ្ជាក់ទទួលស្គាល់កំណើតនេះ ចេញឱ្យប្រើប្រាស់សម្រាប់ចុះសៀវភៅអត្រានុកូលដ្ឋានកំណើត"

**មេភូមិ**

ខេត្ត ក្រុង (១).......... កណ្ដាល ............ | លេខ (៤)........... ២៥ ..............................

ស្រុក ខណ្ឌ (២)........ កណ្ដាលស្ទឹង ......... | សៀវភៅកំណើតលេខ (៥)....០១/២០១២....

ឃុំ សង្កាត់ (៣)......... គោកត្រប់ ............ | ឆ្នាំ (៦)....... ២០១២...................................

# បញ្ជីកំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | | ភេទ (៩) | សញ្ជាតិ (១០) |
| នាមខ្លួនទារក (៨) | | | ប្រុស | ខ្មែរ |
| ជាអក្សរឡាតាំង (១១) | នាមត្រកូល | | កូនទី (១២) | មាន ឬឥតខាន់ស្លា (១៣) |
| | នាមខ្លួនទារក | | មួយ | មានខាន់ស្លា |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៤) | | ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០១២ | | |
| ទីកន្លែងកំណើត (១៥) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | | ........... ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា ................ ............................................................................................ | | |

| | | | | |
|---|---|---|---|---|
| **ឪពុក ម្ដាយទារក** | **ឪពុក** | | **ម្ដាយ** | |
| នាមត្រកូល និងនាមខ្លួន (១៦) | (១៧) | រស់ ឬ ស្លាប់ | | រស់ ឬ ស្លាប់ |
| ជាអក្សរឡាតាំង (១៨) | | | | |
| សញ្ជាតិ (១៩) | ខ្មែរ | | ខ្មែរ | |
| ថ្ងៃ ខែ ឆ្នាំកំណើត (២០) | ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥ | | ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០ | |
| ទីកន្លែងកំណើត (២១) ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង ប្រទេស | .........ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា ....................... | | ....... ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា ..... | |
| មុខរបរពេលទារកកើត (២២) | គ្រូបង្រៀន | | ជាងកាត់ដេរ | |
| ទីលំនៅពេលទារកកើត (២៣) | ....... ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា ..... | | ....... ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា ..... | |
| លេខអត្តសញ្ញាណប័ណ្ណ (២៤) | | | | |

| | | | | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួនអ្នករាយការណ៍កំណើតទារក (២៥) | | ភេទ (២៦) ប្រុស | ឆ្នាំកំណើត (២៧) ១៩៧៥ | សញ្ជាតិ (២៨) ខ្មែរ |
| ត្រូវជាអ្វីនឹងទារក (២៩) | ឪពុកបង្កើត | | | |
| មុខរបរបច្ចុប្បន្ន (៣០) | គ្រូបង្រៀន | | | |
| ទីលំនៅបច្ចុប្បន្ន (៣១) | ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា | | | |
| លេខអត្តសញ្ញាណប័ណ្ណ (៣២) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋាន ឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣៤) ធ្វើនៅ..... គោកត្រប់ ..... ថ្ងៃទី១២ ខែ មករា ឆ្នាំ ២០១២

(៣៣) **ស្នាមមេដៃស្ដាំអ្នករាយការណ៍**

(៣៥) **មន្ត្រីអត្រានុកូលដ្ឋាន**

មេឃុំ

(៣៦) ហត្ថលេខា និងត្រា

សម សោភ័ណ

ទ្រី ហៀង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង (១) ---- *កណ្ដ ល* ------

ស្រុក ខណ្ឌ (២) ---- *កណ្ដាលស្ទឹង* ---

ឃុំ សង្កាត់ (៣) ---- *គោកត្រប់* -----

លេខ (៤)------ *២៥* ------------------

សៀវភៅកំណើតលេខ (៥)--០១/២០១២--

ឆ្នាំ (៦)-------- *២០១២*-----------------

# សំបុត្រកំណើត

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | | ភេទ (៩) |
| នាមខ្លួនទារក (៨) | | | *ប្រុស* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | | |
| | នាមខ្លួនទារក | | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំ កំណើត (១២) | | *ថ្ងៃ ច័ន្ទ ទ ០ ែ មក ្ន ំ ២ ១* | |
| ទីកន្លែងកំណើត (១៣) ភូមិ ឃុំសង្កាត់ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដ ល ប្រទេសកម្ពុជា* ........................................................................ | |

| **ឪពុក ម្ដ យទារក** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | | |
| ជាអក្សរឡាតាំង (១៥) | | |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំ កំណើត (១៧) | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨(* |
| ទីកន្លែងកំណើត (១៨) ភូមិ ឃុំសង្កាត់ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ...*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដ ល ប្រទេសកម្ពុជា*... | ...*ភូមិពោធិ ឃុំសា ស្រ ំ រ៉ុវេស ខេត្តតាកែវ ប្រទេសកម្ពុជា*... |
| ទីលំនៅពេលទារកកើត (១៩) | .......*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដ ល ស្ទឹង ខេត្តកណ្ដ ល ប្រទេសកម្ពុជា* | |

(២០) ធ្វើនៅ.... *គោកត្រប់* ..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០១២*

(២១) **មន្ត្រីអត្រានុកូលដ្ឋ ន**

**មេឃុំ**

(២២) *ហត្ថលេខា និងត្រា*

*ទ្រី ហៀង*

~~ខេត្ត~~ ក្រុង (១)....... *រាជធានីភ្នំពេញ*............ លេខ (៤)............. *១០*...............................

~~ស្រុក~~ ខណ្ឌ (២)...... *សែនសុខ*................... សៀវភៅកំណើតលេខ (៥)... *០១/២០១២* ....

~~ឃុំ~~ សង្កាត់ (៣)....... *ព្រែកពៅ* .............. ឆ្នាំ (៦)............ *២០១២*................................

# បញ្ជីបញ្ជាក់កំណើត

| | | | | |
|---|---|---|---|---|
| នាមត្រកូល (៧) | | ភេទ (៩) | សញ្ជាតិ (១០) | កូនទី (១១) |
| នាមខ្លួនអ្នកកើត (៨) | | *ប្រុស* | *ខ្មែរ* | *បី* |
| ជាអក្សរឡាតាំង (១២) នាមត្រកូល | | | | |
| ជាអក្សរឡាតាំង (១២) នាមខ្លួនអ្នកកើត | | | | |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៣) | *ថ្ងៃ សុក្រ ទ ២ ែ សីប ំ១៩៦៩* | | | |
| ទីកន្លែងកំណើត (១៤) ភូមិ ឃុំសង្កាត់ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ..... *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ........................... | | | |

| ឪពុក ម្ដាយ | ឪពុក | ម្ដាយ |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៥) | (១៦) រស់ ឬស្លាប់ | រស់ ឬស្លាប់ |
| ជាអក្សរឡាតាំង (១៧) | | |
| សញ្ជាតិ (១៨) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត (១៩) | *ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ១៩៣៩* | *ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ១៩៤៣* |
| ទីកន្លែងកំណើត (២០) ភូមិ ឃុំសង្កាត់ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ......*ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រទេសកម្ពុជា* ..................... | ........ *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... |
| មុខរបរបច្ចុប្បន្ន (២១) | | |
| ទីលំនៅបច្ចុប្បន្ន (២២) | | |

| អំពីសាក្សី | សាក្សី | | សាក្សី | |
|---|---|---|---|---|
| នាមត្រកូល និង នាមខ្លួន (២៣) | (២៤) | ភេទ *ប្រុស* | | ភេទ *ស្រី* |
| ថ្ងៃ ខែ ឆ្នាំកំណើត (២៥) | *ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៦១* (២៦) | សញ្ជាតិ *ខ្មែរ* | *ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៦៩* | សញ្ជាតិ *ខ្មែរ* |
| ទីកន្លែងកំណើត (២៧) ភូមិ ឃុំសង្កាត់ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ........ *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | | .....*ភូមិខ្ពប ឃុំកោះឧញ៉ាតី ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| មុខរបរបច្ចុប្បន្ន (២៨) | *កសិករ* | | *កសិករ* | |
| ទីលំនៅបច្ចុប្បន្ន (២៩) | ........ *ភូមិដូង ឃុំព្រែកពៅ ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | | ........ *ភូមិដង ឃុំព្រែក ស្រុកពញាឮ ខេត្តកណ្ដាល ប្រទេសកម្ពុជា* ..................... | |
| លេខអត្តសញ្ញាណប័ណ្ណ (៣០) | | | | |

ជនណាបានរាយការណ៍មិនពិតអំពីអត្រានុកូលដ្ឋាន មន្ត្រីអត្រានុកូលដ្ឋានណាបានសមគំនិត ឃុបឃិត ក្លែងបន្លំ ចុះសៀវភៅអត្រានុកូលដ្ឋានឱ្យប្រជាពលរដ្ឋដែលមកសុំ ជននោះ និងមន្ត្រីអត្រានុកូលដ្ឋាននោះនឹងត្រូវទទួលទោសតាមបញ្ញត្តិច្បាប់ ។

(៣២) ធ្វើនៅ..... *ព្រែកពៅ* ....... ថ្ងៃទី *១១* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(៣១) **ស្នាមមេដៃស្ដាំ**

សាមីខ្លួន សាក្សី សាក្សី

*ឃឹម សុផល* *គីម សុខ* *នោម វ៉ាឌី*

(៣៣) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(៣៤) *ហត្ថលេខា និងត្រា*

*ពេជ ណាំ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** (១) ----*រាជធានីភ្នំពេញ*----

**ស្រុក ខណ្ឌ** (២) ---- *សែនសុខ* -------

**ឃុំ សង្កាត់** (៣) ---- *ព្រែកព្នៅ* -----

**លេខ** (៤)------ *១០* ------------------

**សៀវភៅកំណើតលេខ** (៥)--០១/២០១២--

**ឆ្នាំ** (៦)-------- *២០១២*------------------

## សំបុត្របញ្ជាក់កំណើត

| | | | |
|---|---|---|---|
| នាមត្រកូល (៧) | | | ភេទ (៩) |
| នាមខ្លួនអ្នកកើត (៨) | | | *ប្រុស* |
| ជាអក្សរឡាតាំង (១០) | នាមត្រកូល | | |
| | នាមខ្លួនអ្នកកើត | | |
| សញ្ជាតិ (១១) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំ កំណើត (១២) | | *ថ្ងៃ សុក្រ ទ ២ ែ សីប ្ន ១៩៦៩* | |
| ទីកន្លែងកំណើត (១៣)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ ខេត្តក្រុ<br>ប្រទេស | | ... *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល ប្រទេសកម្ពុជា* ....<br>.ង............................................................................ | |

| ឪពុក ម្ដាយ | ឪពុក | ម្ដាយ |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៤) | | |
| ជាអក្សរឡាតាំង (១៥) | | |
| សញ្ជាតិ (១៦) | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំ កំណើត (១៧) | *ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៣៩* | *ថ្ងៃទី៣០ ខែកក្កដា ្ន ំ ១៩៤៧* |
| ទីកន្លែងកំណើត (១៨)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង<br>ប្រទេស | *ភូមិអំពិល ឃុំលាយបូរ ស្រុកត្រាំកក់<br>ខេត្តតាកែវ ប្រទេសកម្ពុជា* | *ភូមិព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម<br>ខេត្តកណ្ដាល ប្រទេសកម្ពុជា* |

(១៩) ធ្វើនៅ..... *ព្រែកព្នៅ* ....... ថ្ងៃទី *១១* ខែ *កុម្ភៈ* ឆ្នាំ *២០១២*

(២០) **មន្ត្រីអត្រានុកូលដ្ឋាន**

**មេឃុំ**

(២១) *ហត្ថលេខា និងត្រា*

*ពេជ ណុំ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ខេត្ត ក្រុង** (១) ---- *កណ្ដា ល* ------
**ស្រុក ខណ្ឌ** (២) ---- *កណ្ដា លស្ទឹ* ---
**ឃុំ សង្កាត់** (៣) ---- *គោកត្រប* ' -----

## សេចក្ដីចម្លងសំបុត្រកំណើត

| ចម្លងសំបុត្រកំណើតចេញពី | | (៤) សៀវភៅកំណើត<br>លេខ ៖ *០១/២០១២* | (៥) សំបុត្រកំណើត<br>លេខ *២៥* ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ |
|---|---|---|---|
| នាមត្រកូល (៦) | | | ភេទ (៨) |
| នាមខ្លួនទារក (៧) | | | *ប្រុស* |
| ជាអក្សរឡាតាំង (៩) | នាមត្រកូល | | |
| | នាមខ្លួនទារក | | |
| សញ្ជាតិ (១០) | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំ កំណើត (១១) | | *ថ្ងៃ ច័ន្ទ ទ ០ ែ មក ្ន ំ ២ ១* | |
| ទីកន្លែងកំណើត (១២)<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | .... *ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដា ល ប្រទេសកម្ពុជា* ........................................................................ | |

| **ឪពុក ម្ដាយទារក** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន (១៣) | | |
| ជាអក្សរឡាតាំង (១៤) | | |
| សញ្ជាតិ (១៥) | *ខ្មែរ* | *ខ្មែរ* |
